លេខ ១១ - ១២

ទស្សនាវដ្ដី

# កម្ពុជសុរិយា

D-205

ព.ស. ២៤៩៩

គ.ស. ១៩៥៥

១ វិច្ឆិកា - ធ្នូ



ទេសភាពវត្តភ្នំ ដែលតាំងនៅកណ្ដាលរាជធានីភ្នំពេញ ជាដំណែលព្រះពុទ្ធសាសនាប្រទេសកម្ពុជា

[illegible] ភ្នំពេញ បណ្ណាគារ [illegible]

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ | ....... | វិចារណកថា | ទំព័រទី ១ |
| | ....... | ពុទ្ធទស្សនៈ | — ៤ |
| ហ.អ. | ....... | ខ្មែរនឹងចិន | — ៩ |
| ភិក្ខុ-ប៊ូជ្រី | ....... | ប្រវត្តិពាហិរសាសនាសង្ខេប | — ១៤ |
| ព្រះមហាព្រហ្ម-ម៉ុន ហៅកើត-សារ៉ែន | ....... | វិទ្យុធម្មទេសនា | — ២០ |
| ព្រះគ្រូ អ៊ូចេវ | ....... | រឿងធនញ្ជ័យ | — ២៥ |
| | ....... | សមាគមមិត្តសាលាបាលីសូមថ្វាយសេចក្តីកតញ្ញូចំពោះ-សម្តេចព្រះឧបយុវរាជ | — ២៩ |
| ភិក្ខុ ម-ប៊ូជ្រី | ....... | ពុទ្ធឃោសប្រវត្តិសង្ខេប | — ៣៣ |
| ព្រះសមុហ-សៅទេស | ....... | ពុទ្ធសាសនាក្នុងប្រទេសជប៉ុន | — ៣៧ |
| ភិក្ខុ-ប៊ូជ្រី | ....... | ព្រះពុទ្ធសាសនាក្នុងដែនកម្ពុជា | — ៣៨ |
| | ....... | ប្រវត្តិក្មេងកំព្រា | — ៣៩ |
| ហ.ហ. | ....... | គួរស្គាល់រូបភាពកញ្ញាកម្ពុជា | — ៤១ |
| សួន.ស៊ុរិន្ទ | ....... | បុណ្ណកុមារ | — ៤៩ |


## ថ្លៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ខែ | ១ឆ្នាំ | ១ក្បាល | ៦ខែ | ១ឆ្នាំ | ១ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

អ្នកណាទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

**ADRESSE**: Monsieur **MAO-MEY** Ministère de L'Intérieur P.Penh

R- 6 11-3-56



# ជំហានព្រះពុទ្ធសាសនា
## នឹង
## អក្សរសាស្ត្រ

នៅចុងឆ្នាំ ១៩៥៥ នេះ ប្រទេសកម្ពុជាត្រូវទទួល ជម្រះពីដំណើរសាសនានឹងអក្សរសាស្ត្រ ដែលជាថ្មើម ប្រមាត់របស់ពលរដ្ឋរួមសញ្ជាតិ ។

តើយើងបានដឹងខ្លះហើយដែរ ! ថាពលរដ្ឋយើង និយមរាប់អានសាសនាណាខ្លះ ក្រៅពីពុទ្ធសាសនា ដែលជាសាសនាមានចារឹកក្នុងផ្ទៃនៃរដ្ឋធម្មនុញ្ញ , យើងគង់ឃើញតាមចក្ខុនិងតាមសោតទ្វារជាច្រើនឆ្នាំមក ហើយ ចំពោះជនអ្នកមានជំនឿលើសាសនាដទៃដែល មានក្នុងរដ្ឋយើងនេះ ហើយសាសនានោះក៏គង់មាន សិទ្ធិដោយពេញលេញក្នុងការឃោសនា , ពន្យល់ , ដឹកនាំ , ឲ្យប្រយោជន៍ដល់សាធារណជនទូទៅ ប៉ុន រីសថានៈ

យើងចាំមិនភ្លេចទេថា ខ្មែរត្រូវក្រលំបាកជិះជាន់ មកជាច្រើនឆ្នាំហើយ ៗ យើងចាំមិនភ្លេចទៀតថា ខ្មែរ ត្រូវការរស់នៅជាមួយនឹងអ្នកដែលផ្តល់ប្រយោជន៍ដល់ ខ្លួន ៗ ចុះបើមានសាសនាជំពូកខ្លះហ៊ានចំណាយធន ធានដើម្បីអ្នកប្រតិបត្តិតាមនោះប្រហែលជាខ្មែរជាតិ យើងឆ្លៀតឱកាសនេះ នឹងលះបង់ជំនឿសាសនា ខ្លះ ហើយចាប់យកជំនឿថ្មីវិញខ្លះដឹង ? បើសិនជាខ្មែរ តូចតាច ខ្មែរទន់ខ្សោយរត់ទៅរកជំនឿបែបនោះ តើ យើងជាខ្មែរធំដុំ មានគំនិតបែបណាដែរ ?

សព្វថ្ងៃព្រះពុទ្ធសាសនាមានកម្លាំងមែន ! អ្នក ជឿកាន់តាមមានច្រើនមែន ! តែត្រឹមជំនឿដែល ប្រតិបត្តិទៅតាមទំនៀមទម្លាប់នឹងបវេណី ពុំសូវមាន ជំនឿ ដែលប្រកបទៅតាមញាណឡើយ ៗ សាសនា ក៏កាន់តែលឿនទៅមុខ អ្នកកាន់តាមក៏ចេះតែមានច្រើន

តែតាមហូតាមហែនឹងគេនឹងឯង ។

កាន់ស្មើរ កាន់មិនជិតមិនដល់ក៏មិនខុសគ្នាពីការចំអិនអាហារឆៅប៉ុន្មានដែរ, ហើយអាហារឆៅនេះហើយដែលនាំឲ្យអ្នកបរិភោគទៅ ហើមពោះ នោះនឹងមានពាក្យបន្ទោសថា អាហារសម្រាប់ផ្គត់ផ្គង់ជីវិភាពរបស់មនុស្សលោក ចុះម្ដេចក៏អាហារនេះនាំឲ្យអ្នកបរិភោគបណ្ដាលឲ្យទៅជាមានរោគឈឺខ្លួនប្រាណទៅវិញ ? គួរពិចារណា ?

ព្រះពុទ្ធសាសនាមានមនុស្សកាន់អានច្រើន សាសនាដទៃក៏គង់មានគេកាន់អានគួរសមដែរ...!!!

ក្នុងសមាជជាតិថ្មីៗ នេះ ដែលមានការស្នើសុំបំបាត់ការពិឃាតសត្វ , បំបិទសុរា , នឹងឲ្យឈប់សំរាកថ្ងៃសីលតាមសេចក្ដីស្នើពីក្រុមពុទ្ធជននឹងគណៈកម្មការពុទ្ធិកសមាគម ដែលស្របទៅតាមច្បាប់ព្រះពុទ្ធ-សាសនាសុទ្ធសាតនោះ តែការនេះទៅជាមិនបានសម្រេចតាមបំណងទៅវិញ គ្រាន់តែបានសម្រួលខ្លះៗ ដោយមតិភាគច្រើនមិនយល់ស្រប, ដូចនេះយើងជឿច្បាស់ថាខ្មែរមិនទាន់មានជំនឿច្បាស់ក្នុងព្រះពុទ្ធសាសនានៅឡើយ គឺគ្រាន់តែជឿតាមដូនតាបតាប៉ុណ្ណោះ ។ អំពីការជឿប៉ុណ្ណោះនេះក៏យើងគួរសរសើរដែរ ព្រោះខ្មែរបេះរគក្ប គេក្ដីដំណាល, តែថាបើខ្មែរបេះជឿឲ្យប្លែកពីនេះទៅទៀតប្រហែលជាព្រះពុទ្ធសាសនា ប្រទេសយើងនឹងមានរស្មីគ្រាន់បើបន្តិចទៀតដែរ ។

ចំណែកអក្សរសាស្ត្រវិញដែលធ្លាប់តែមានជីវិតរស់នៅជាមួយនឹងព្រះសង្ឃក្នុងអារាមមួយ ៗ នោះ ក៏ហាក់ឈានជើងសន្សឹមៗចូលជិតនឹងគេខ្លះហើយ តែនៅញញើតញញើមណាស់ហាក់ដូចជាខ្លាចមុខខ្លាចក្រោយទំនងដូចជាបាវព្រៃដែលចៅហ្វាយនាយគេហៅខ្លួនឲ្យ-ចូល បែបស្ទាក់ស្ទើរ ចង់ទៅមុខបន្តិច ថយក្រោយបន្តិច !...

យើងចាំច្បាស់ណាស់ថា កាលសមាជជាតិលើកទី ១ សម្ដេចឧបយុវរាជទ្រង់មានបន្ទូលថានឹងទុកឲ្យប្រើអក្សរបរទេស ១ ឆ្នាំ ទើបនឹងមានអង្គុលីលេខជាអក្សរខ្មែរ ហើយដល់សមាជជាតិលើកទីពីរទៀតថាត្រូវដាក់កំរិតឲ្យប្រើភ្លាម ៗ ជាផ្លូវការតាំងពីរាជការតាំងអ្នកជំនួញ ព្រោះអង្គុលីលេខអក្សរខ្មែរមានហើយ ។ តែធ្វើដូចម្ដេចហ្ន៎ ! បើសិនជាព្រះឱង្ការនោះមិនមានខ្លឹមសារទៅវិញ?... សេចក្ដីត្រង់នេះ ខ្ញុំមិនគួរនឹងនាំហេតុសោះ ព្រោះនៅជំពាក់ដល់ជនច្រើនរូប ដោយគេមិនសូវពេញចិត្តប៉ុន្មាន ។ ហេតុម្ដេចក៏ខ្ញុំហ៊ានថាគេមិនពេញចិត្ត, ថាឃើញច្បាស់ហើយ សព្វបើលិខិតឆ្លើយឆ្លងពីក្រសួងមួយទៅមួយដែលសុទ្ធតែមន្ត្រីជាតិខ្មែរមើលបានទាំងអស់នោះ ក៏គង់គេធ្វើជាអក្សរបរទេសដែរ ។ ចុះបើយើងសរសេរជាអក្សរជាតិទៅនឹងនឿយហត់ប៉ុណ្ណា ខូចប្រយោជន៍បែបណាខ្លះ ចំពោះពាក្យឆ្លើយឆ្លងបន្តិចបន្តួចនោះ ?

ខ្ញុំដឹងហើយថា សំដីប៉ុន្មានឃ្លាខាងលើនេះមិន

រួចពីជនអ្នកត្រូវតិះដៀលខ្ញុំទេ គេមុខតែថា “ នោះជាសំដីក្មេងវត្តទេ មានមាត់ចាំតែថាគេ ព្រោះតែវាមិនចេះអក្សរបរទេសប៉ុណ្ណោះ បើវាពូកែណាស់ម្តេចក៏វាមិនមកចាត់ការជំនួសគេទៅ ” ខ្ញុំមុខតែឡើបប្រាប់គ្នាខ្ញុំវិញថា “ ក្មេងវត្តមិនខុសពីសត្វប៉ុន្មានទេ បើអ្នកណាចូលវត្តខុសទំនងសត្វនោះនឹងត្រូវសបើចង់ក្បត់សត្វនឹងចាំ បើគេហុចចំណីឲ្យសត្វ នឹងទទួលសំដែងសេចក្តីកោតតាមឋានៈខ្លួនជាសត្វមែន ” ។

ឱ ! មិត្តជាទីគោរពរបស់ខ្ញុំទាំងឡាយ សូមមិត្តមេត្តាចេះស្រឡាញ់អក្សរសាស្ត្រជាតិខ្លះទៅ បើមិត្តមិនបានស្រឡាញ់ជាតិក៏ត្រូវតែគោរពអក្សរសាស្ត្រទៅចុះ ហើយទុកដូចជាមិត្តបានគោរពព្រះរាជឱង្ការសម្តេចព្រះឧបយុវរាជជាទីស្រឡាញ់របស់យើងផង ។ ចុងឆ្នាំ១៩៥៥ជិតផុតហើយ គួរហាត់ការនហាត់សរសេរអក្សរសាស្ត្រឲ្យបានម៉ត់ចត់បន្តិចឡើង , គួរកុំប្រកាន់អស្មិមានៈខ្លាំងពេក គួររៀបខ្ចប់ពេល ទៅកុំទទេរមគ្គុទ្ទេសខ្លះទៅៗ ក្មេងវត្តសូមអង្វរព្រោះក្មេងវត្តចង់ឲ្យអក្សរសាស្ត្រជាតិដើបមុខស្មើនឹងគេ, សូមអស់លោកជាដំណាងយើងខ្ញុំ កុំចូលចិត្តសរសេរអក្សរបរទេសពេក ! ខ្ញុំជឿហើយ ជឿច្បាស់ថា អស់លោកចេះអក្សរបរទេស មានជំរះពេញខ្លួន ល្មមដឹកនាំយើងខ្ញុំដែលជាអ្នកល្ងង់ទៅឲ្យទៅកាន់សេចក្តីចំរើនបាន តែកុំឲ្យការចំរើននោះធ្លាក់ទៅលើឯកជនឬជនបរទេស ដែលប្រាសចាកយុត្តិធម៌នៃសង្គមជាតិ !....

ទីបំផុតខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធិគ្រប់យ៉ាង ដើម្បីឲ្យពាក្យអំពាវនាវនេះក្លាយជាបញ្ហាមួយ ដែលមិត្តរាល់រូបគ្រប់ឋានៈ គាប់ចិត្តយកមកពិចារណាទៅអនាគត ។

ជយោ ! ពាក្យសច្ច !

★

★ ★



ពុទ្ធទស្សនៈ

## "ព្រះពុទ្ធជាម្ចាស់ត្រាស់ដឹងអ្វី?"

សេចក្តីចំពោះអត្ថន័យនេះ បើយើងមិនបានពិនិត្យដោយច្បាស់លាស់ទេ ក៏នឹងឃើញថា: មិនសូវលំបាកណាស់ណាប៉ុន្មាន, ប៉ុន្តែមានអ្នកខ្លះក្រៅអំពីសាសនបណ្ឌិត្យពិតប្រាកដនឹងឆ្លើយបាន តែមានភាគតិច ៗ លុះត្រាតែអ្នកនោះធ្លាប់បួសរៀន ហើយនៅចាំសព្ទនោះ ៗ ផង ទើបអាចឆ្លើយថា: "ចាក់ធ្លុះនូវអនុត្តរសម្មាសម្ពោធិញាណ", ចំណែកអ្នកដែលមិនធ្លាប់បានស្តាប់-រៀន-និងមិនធ្លាប់ចេះដឹងសព្ទនោះ ៗ ក៏ប្រហែលជាមិនអាចនឹងទទួលចម្លើយនោះបានឡើយ ៗ បើនឹងឆ្លើយថា: "ព្រះអង្គផ្ចាញ់ស្តេចនៃមារបាន" ដូច្នេះក៏សមគួរដែរ, ព្រោះចម្លើយនេះមិនសូវបានលទ្ធផលក៏ពិត ប៉ុន្តែអាចធ្វើឲ្យអ្នកស្តាប់នឹកឃើញថា "ព្រះពុទ្ធជាម្ចាស់ជាបុគ្គលអស្ចារ្យប្លែកអំពីមនុស្សទាំងឡាយ" ៗ ឯការឆ្លើយដោយប្រើសព្ទសាសន៍នាំឲ្យអ្នកស្តាប់មិនចូលចិត្តដូច្នេះអាចឲ្យផលអាក្រក់ គឺថាអ្នកដែលមិនចូលចិត្តជាក់ស្តែងក្នុងការពិតនោះ កាលបើបានទទួលចម្លើយដែលមិនយល់ដូចនេះ ក៏អាចនឹកថា: ទុកជានឹងសួរតទៅទៀតក៏គង់នឹងបានទទួលសេចក្តីអធិប្បាយ ដែលពេញដោយភាសាដែលមិនចូលចិត្តថែមទៀត, អ្នកនោះក៏កើតចិត្តអាធុញទ្រាន់នឿយណាយ ត្រឡប់ទៅជាស្ងប់ស្ងាត់ បណ្តោយតាម មិនអើពើនឹងសួរតទៅទៀត ហើយក្លាយទៅជាបុគ្គលមួយបែប ដែលហៅថា "អ្នកបៀមអណ្តាត" សូម្បីអ្នកស្តាប់ បើមិនចូលចិត្តសោះក៏ពន្យល់ដកបដល់ចូលចិត្តបាន ព្រោះខ្លាចក្រែងត្រូវគេនិន្ទាថា: "ចេះដឹងព្រាល ៗ ស្បើ ៗ" ដូច្នោះកាលបើមិនអធិប្បាយតទៅ គេក៏គង់មិនអាចដឹងដូចខាងដើមនោះឯង ៗ ក្រៅពីនេះ នៅមានបុគ្គលមួយផ្នែកទៀត ដែលគិតឃើញថា: អ្នកឆ្លើយត្រូវលើកសព្ទយកមកជាសំអាង តែចម្លើយនោះឯង ក៏មិនចូលចិត្តពាក្យប្រែនៃសព្ទនោះ ៗ ដែរ គឺគ្រាន់តែធ្លាប់ចេះដឹងព្ទមកប៉ុណ្ណោះ ម្ល៉ោះហើយអ្នកស្តាប់នោះក៏ត្រឡប់កើតសេចក្តីមើលងាយ ហើយមិនជឿក្នុងសេចក្តីដឹងរបស់អ្នកឆ្លើយ ការមិនជឿនេះសឹងជាផលអាក្រក់ដល់អ្នកទាំងពីរផ្នែក ៗ

កាលបើដូច្នេះខ្ញុំក៏លើកយកអត្ថបទខាងលើនេះ មកពិនិត្យពិសោធមើល ហើយតាំងចិត្តថា: នឹងព្យាយាមដោះបញ្ហានេះដរាបដល់គួរសន្និដ្ឋានចូលចិត្តយល់បាន ចំពោះអ្នកដែលបានសិក្សាក្នុងវិជ្ជាសាមញ្ញហើយផង និងអ្នកដែលចូលចិត្តចង់ចេះដឹងក្នុងផ្លូវព្រះពុទ្ធសាសនាផង លោកអ្នកទេសនាឬអ្នកដែលធ្លាប់បានស្តាប់លោកទេសនាមកច្រើន ៗ ហើយ, កាលបើអ្នកបានជួបប្រទះនឹងសំនួរចំហារដែលខ្ញុំសរសេរក្នុងសៀវភៅនេះ ទោះបីភាំងភ្លាត់អំពីសំនួរលោកទេសនាឬសៀវភៅដទៃ ៗ ក៏សូមមេត្តាយល់ថា: ខ្ញុំជាអ្នកមិនសូវឈ្លាសវៃប៉ុន្មានដែរ ប៉ុន្តែដែលរៀបរៀងសៀវភៅនេះឡើង ព្រោះមានបំណងដល់មនុស្សធម្មតាអានមើលប៉ុណ្ណោះ ។

តែបើទុកជាខ្ញុំឆ្លើយបញ្ហានោះ ដោយសង្ខេបយ៉ាងណា ? ខ្ញុំក៏គង់នឹងឆ្លើយថា:

“ព្រះពុទ្ធជាម្ចាស់បានត្រាស់ដឹងនូវសេចក្តីពិតដ៏ប្រសើរ ៤ ប្រការដែលហៅថា ចតុរារិយសច្ច”

បើឆ្លើយយ៉ាងនេះ ក៏គង់ជាពាក្យចម្លើយដ៏ខ្លីបំផុតផង ជាពាក្យសរុបអត្ថដទៃ ៗ ផង ។ ព្រោះខ្ញុំយល់ថា: ចម្លើយប៉ុណ្ណេះ នៅមិនទាន់ច្បាស់លាស់ល្មមនឹងធ្វើឲ្យអ្នកដែលសួរចូលចិត្តយល់បានដោយសព្វគ្រប់ឡើយ, សួរថាយ៉ាងនេះក៏ដោយចុះ ខ្ញុំក៏មានសង្ឃឹមថា: ចម្លើយដូចនេះ នឹងអាចជួយឲ្យលោកអ្នកដែលចង់ដឹងនូវ - សេចក្តីពិតនោះ កើតសេចក្តីប្រាថ្នានឹងចង់ចេះដឹងយ៉ាងក្រៃលែងឡើងទៀត ហើយខ្ញុំនឹងព្យាយាមស្វះស្វែងរកសេចក្តីដឹងនោះ ៗ យកមកតម្រៀបជាកម្រងទុកក្នុងសៀវភៅនេះ ។ តែពេលនេះ បើទុកជាខ្ញុំមិនមានវេលាអធិប្បាយឲ្យពិស្តារជូនអ្នកសិក្សានោះ ៗ ឲ្យគ្រប់គ្រាន់គង់លោកអ្នកដែលធ្លាប់ដឹងស្រាប់ ក៏អាចជួបប្រទះសៀវភៅណាទីមួយថា “ចតុរារិយសច្ច” នោះគឺអ្វីខ្លះ? អត្ថបទនេះ បើលោកអ្នករលឹកដឹងទាន់ ក៏គង់សេចក្តីចេះដឹងច្រើនប្លែក តាមសេចក្តីឈ្លាសវៃរបស់លោកអ្នកនោះឯង ៗ បើលោកអ្នកធ្លាប់ចេះវិជ្ជាបែបនោះខ្លះហើយនឹងមិនលំបាកស្វែងរកសេចក្តីចេះដឹងក្នុងទីដទៃ ៗ ជាហេតុនាំឲ្យខូចវេលា ។

ន័យនេះ បើយើងនិយាយឲ្យឆ្ងាយដល់ការចេះចាំនោះ, ខ្ញុំសូមដកស្រង់យកអត្ថបទនោះ ៗ មកអធិប្បាយជាសេចក្តីកក់ ៗ ឆ្ងាយ ៗ, តែមុននឹងពោលដល់ធម៌ដ៏ប្រសើរដែលព្រះសម្ពុទ្ធជាម្ចាស់របស់យើងត្រាស់ដឹងឬឃើញពិតនោះ គួរពិនិត្យគិតពិចារណាមើលថា: “ហេតុអ្វីទើបទ្រង់ត្រាស់ដឹងដូច្នោះ ?” បើសួរមនុស្សបុរាណសម័យ គង់នឹងឆ្លើយក្នុងផ្លូវបាដិហារិយ៍ថា: ព្រះអង្គជាបុគ្គលអស្ចារ្យបំផុតក្នុងលោក, ដោយទ្រង់បានទទួលពាក្យអារាធនានៃទេវតាថា: សូមស្តេចយាងចុះមកសោយព្រះជាតិក្នុងស្ថានមនុស្សលោកគ្រាទីបំផុត, ស្តេចចុះចាប់បដិសន្ធិក្នុងព្រះគភ៌ព្រះនាងសិរីមហាមាយា ជាអគ្គមហេសីរបស់ព្រះបាទសិរីសុទ្ធោទនសាក្យរាជក្នុងក្រុងកបិលពស្តុ, លុះប្រសូតចាកព្រះគភ៌ព្រះវរមាតា ទ្រង់យាងទៅបាន ៧ ជំហាន ធ្វើឲ្យជាទី

ប្រាមោទ្យដល់ពួកទេវតានិងមនុស្សដែលនៅជួបជុំក្នុងសួនលុម្ពិនីជាទីប្រសូតិនោះ ។ កាលដើមឡើយ ទ្រង់នៅជាព្រះរាជកុមារ ទ្រង់មិនបានសិក្សាសិល្បសាស្ត្រទេ តែព្រះអង្គអាចសំដែងព្រះប្រាជ្ញាញាណ អង់អាចជាងអ្នកទាំងអស់បាន ។ កាលស្តេចចេញបព្វជ្ជាទ្រង់គង់សេះកណ្ឋកចេញចាកក្រុងកបិលពស្តុ នោះ មានទេវតាមកទ្រទ្រង់ជើងសេះទាំង៤ មានព្រះឥន្ទព្រះព្រហ្មមកកាន់ឆត្រត្រៃត្រឹងបាត្រតាមស្តេច, កាលព្រះអង្គត្រាស់ដឹង ស្តេចមារបានលើកទ័ពយ៉ាងធំមកច្បាំង នាងព្រះធរណី (ដី) ក៏ផុសឡើងមកបង្ហូតទឹកឲ្យហូរចេញអំពីសក់ ធ្វើឲ្យស្តេចនៃមារនិងពួកពលចាលចាញ់បាក់បប ខ្ទបខ្ចាបព្រះអង្គ ។ រឿងបាដិហារិយ៍ផ្សេងៗ ដែលបានលើកយកមកសំដែងជាតួយ៉ាងខាងលើនេះ មិនមែនតែត្រឹមប៉ុណ្ណោះទេ នៅតែមានទៀតជាច្រើន ប៉ុន្តែមិនអាចនឹងនាំមកតម្រៀបទុកក្នុងទីនេះឲ្យអស់បានឡើយ ។ មនុស្សបូរាណ កាលបើបានស្តាប់ដល់ការពោលនូវបាដិហារិយ៍ផ្សេងៗ របស់ព្រះពុទ្ធជាម្ចាស់ដូច្នេះហើយ ក៏កើតសេចក្តីជ្រះថ្លាចំពោះព្រះអង្គ ហើយមិនបានរិះគិតពិចារណាត្រិះរិះដល់សេចក្តីអស្ចារ្យដ៏ពិតក្រៅពីបាដិហារិយ៍ទាំងពួងដែលកើតប្រតិស្ឋឡើង ពោលគឺសេចក្តីពិតក្នុងព្រះព្រឹត្តិការណ៍របស់ព្រះពុទ្ធជាម្ចាស់ឡើយ ។ ចំណែកខាងបុគ្គលសម័យថ្មី ក៏មែនយល់ដូចគ្នាដែរ គឺយល់ថាបណ្តាបាដិហារិយ៍ទាំងឡាយចាត់ជា ជារបស់ជោកជាប មិនគួរជឿកាន់រាប់អានឡើយ, តែនឹងយកតែណាមួយក្នុងបាដិហារិយ៍ ដែលគួរជឿនោះមកជាទីតាំងគ្មានឡើយ ហើយក៏រឹតតែមិនជឿនូវសេចក្តីអស្ចារ្យរបស់ព្រះពុទ្ធជាម្ចាស់នោះទៀត ។ បើតាមពិត សូម្បីនឹងកាត់បាដិហារិយ៍ដូចជាមនុស្សបូរាណ ធ្លាប់ពោលមកនោះចេញ ព្រះពុទ្ធជាម្ចាស់របស់យើងក៏នៅជាបុគ្គលអស្ចារ្យក្នុងលោកដដែល ។

ក្នុងទីនេះមិនគួរនឹងសំដែងដល់ពុទ្ធប្បវត្តិ ដោយពិស្តារឡើយ, ព្រោះហេតុតែងនោះ ខ្ញុំមិនពោលដល់ទេ, នឹងពោល ចំពោះចំពោះករណីយខ្លះៗ ដែលខ្ញុំគប្បីពោលនោះថា " ព្រះពុទ្ធជាម្ចាស់របស់យើងជាបុគ្គលអស្ចារ្យនោះពិត ព្រោះថា: ដោយជាតិរបស់ព្រះអង្គជាខត្តិយ គឺជាតិអ្នកចំបាំង, ការសិក្សាកានអប់រំរបស់ព្រះអង្គខាងផ្លូវយុទ្ធសាស្ត្រ និងវេជ្ជប្រសាសនសាស្ត្រ, ឬ ពោលដោយខ្លីថា: ទ្រង់រៀបចំព្រះអង្គទុក ជាអ្នកគ្រប់គ្រងផែនដីស្នងព្រះវររាជបិតា ដូច្នេះ សេចក្តីពិតជាតួយ៉ាង ៖ (ក) ដោយអាស្រ័យហេតុព្រាហ្មណ៍ដែលចេះដឹង ក្នុងផ្លូវទំនាយលក្ខណៈរបស់មនុស្ស បានទាយទុកថា: បើទ្រង់នៅគ្រប់គ្រងជាយកាក់សវិស័យ នឹងបានជាស្តេចក្រពត្តិរាជាធិរាជ , បើស្តេចយាងចេញសាងបព្វជ្ជានឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដោយហេតុដូច្នេះ ទើបព្រះវររាជបិតា នឹងរាជមាត្យ រៀបចំទ្រង់ផ្សាអភិសេកនឹងព្រះនាងពិម្ពាយសោធរា តាំងពីព្រះអង្គមានព្រះជន្មាយុ ១៦ ឆ្នាំ ។

១) ដោយបានចាត់ចែងសាងប្រាសាទ សម្រាប់

ប្រដាប់នោះទុកយ៉ាងវិចិត្រ ដ៏បរិបូណ៌ដោយស្រីស្ត្រីបរិវារ មានគណនារីប្រតិបត្តិចោមរោម ជាប្រក្រតី សោយលោកិយកាមទាំងថ្ងៃ-យប់, តែបើទុកជាដូច្នោះ ក៏ព្រះអង្គមានព្រះហឫទ័យ លុះបោលនូវរបស់ទាំងនោះ ព្រោះរបស់ទាំងនោះហើយ ដែលធ្វើឲ្យព្រះអង្គស្រវឹងគ្រប់ឋានៈ ហើយព្រះអង្គស្ដេចចេញទៅសាងបព្វជ្ជា ដើម្បីស្វែងរកលោកុត្តរសុខ, ព្រោះទ្រង់ធ្លាប់ជ្រាបច្បាស់ថា: ជារបស់ប្រសើរជាងលោកិយសុខ ។

គ ) អ្នកដែលលះបង់កាមវិស័យចេញទៅបព្វជ្ជា ក៏មានច្រើនក្នុងកាលនោះនិងកាលជាខាងក្រោយមក តែមិនមានបុគ្គលណាប្រៀបស្មើនឹងព្រះអង្គបានឡើយ, ព្រោះការដែលព្រះអង្គចេញបួសមិនមានបុគ្គលណា ឬ របស់ណាមកបង្គាប់ដូចបុគ្គលដទៃឡើយ ។ តាមពិត អ្នកដែលបួស ច្រើនតែមានបុគ្គល ដែលគួរគោរពរាប់អាន និងមានមហិទ្ធិឫទ្ធិដោយគុណ ដូចជាមាតាបិតាជាដើម បង្គាប់ ឬ សំដែងសេចក្ដីប្រាថ្នាបួស ព្រោះការនៅគ្រប់គ្រងយកកាមវិស័យនេះ មិនបានទទួលសេចក្ដីសុខសម្រាន្តគ្រប់គ្រាន់, ក៏កើតការបង្គាប់ចិត្តទើបចេញបួស ។ មួយវិញទៀតថា: មានអ្នកខ្លះបានស្ដាប់បុគ្គលដទៃពោលពណ៌នាសរសើរសេចក្ដីសុខសម្រាន្តនៃការបួស ទើបកើតសេចក្ដីចង់បួសឡើង តាមវិស័យរបស់អ្នកមានគតិផ្សេងៗ គ្នាដូច្នេះ ។

រីឯព្រះពុទ្ធជាម្ចាស់របស់យើង ព្រះអង្គមិនបានចុះក្នុងហេតុ ៣ ពួកខាងលើនេះឡើយ ៖

ប្រការទី ១ ព្រះរាជបិតាទ្រង់មិនមាន ព្រះរាជបំណងឲ្យទ្រង់ឡើយ ។

ប្រការទី ២ ព្រះអង្គមិនគួរមានហេតុណាមួយធ្វើឲ្យព្រះអង្គនឿយណាយ ក្នុងការនៅជាគ្រហស្ថឡើយ ។

ប្រការទី ៣ មិនមានបុគ្គលណាបបួលព្រះអង្គឲ្យចេញបួសឡើយ ។ ព្រះជន្មាយុរបស់ព្រះអង្គបាន២៩ វស្សាហើយ ក៏ទ្រង់ចេញព្រះផ្នួស ។

យើងទាំងឡាយគួរជឿឬទេថា: ព្រះពុទ្ធជាម្ចាស់មិនធ្លាប់ទ្រង់ជ្រាបដល់ការឈឺ, ចាស់ និងស្លាប់ ដែលជាសភាវៈមាននៅជាធម្មតា ? ខ្ញុំយល់ថា បើហេតុដែលមិនគួរដូច្នោះ និងមិនគួរជឿថា: ព្រះបាទសុទ្ធោទនៈ ឬអ្នកណាមួយ ដែលប្រាថ្នាបិទបាំងមិនឲ្យទ្រង់ជ្រាបនៅហេតុជាធម្មតានោះ ។ ? បើដូច្នោះមែន ក៏គង់តែប្រុងប្រយ័ត្នរាំងមិនឲ្យប្រទះប៉ះពាល់ព្រះនេត្ររបស់ព្រះអង្គតាំងពីមិនទាន់ដឹង ទើបគាប់សម្បើមបានថា: សូម្បីទ្រង់ជ្រាបក៏មិនគួរយកព្រះហឫទ័យទុកដាក់ដែរ, ដោយហេតុតែព្រះអង្គវង្វេងស្រវឹងនៅក្នុងសុខនៃកាមភោគី ( អ្នកបរិភោគកាម ) ។

ន័យនេះ គួរជ្រាបថា: ព្រះពុទ្ធជាម្ចាស់របស់យើងទ្រង់មានព្រះនិស្ស័យក្នុងការសិក្សាដោយពិត ទ្រង់ក៏សិក្សាមកជាច្រើន ដូចមានភស្តុតាងនៅក្នុងទីផ្សេងៗ នៅក្នុងផ្លូវធម៌ដែលបានរៀនប្រដាប់ដោយសៃយសាស្ត្រ ( គឺសាសនាព្រាហ្មណ៍ ) នោះព្រះអង្គទ្រង់ជ្រាបជា

ច្រើន ល្មមនឹងទ្រង់ប្រឹក្សាជាមួយនឹងពួកព្រាហ្មណ៍បាន ដោយមិនត្រូវចុះចាញ់ ។ សាសនាព្រាហ្មណ៍នោះ ដ៏បរិបូណ៌ទៅដោយពាក្យប្រៀនប្រដៅ ហើយជាលទ្ធិ ពោលដោយសេចក្ដីចាស់, ឈឺ, ស្លាប់, ហេតុម្ដេចក៏ព្រះអង្គមិនទ្រង់ជ្រាបហេតុនោះ ៗ ?

ន័យគួរកំណត់មួយយ៉ាងទៀតថា: សម័យដែលព្រះពុទ្ធជាម្ចាស់របស់យើង ទ្រង់ជាក់ព្រះជន្មាយុនោះ ក្រៅអំពីសាសនាព្រាហ្មណ៍ដែលជារបស់បុរាណនៅក្នុងមជ្ឈិមប្រទេស (ឥណ្ឌា) មានពួកអ្នកកាន់លទ្ធិមួយពួកទៀត "ហៅថានិគ្រន្ថ" ដែលមាននៅក្នុងមជ្ឈិមប្រទេសដែរសឹងមានដរាបដល់សព្វថ្ងៃនេះ ហើយសម័យនេះដែលច្រើនហៅថា "ជេន" (JAIN) ។ អ្នកបួសនេះថាអ្នកកាន់លទ្ធិរបស់សាស្ដា ឈ្មោះមហាវីរៈ ជាកូនម្ចាស់ប្រទេសនោះ ដែលបានសិក្សាក្នុងវិស័យសាស្ត្រយ៉ាងស្ទាត់ជំនាញហើយកើតសេចក្ដីភ្ញាក់រលឹកដឹងខ្លួនឡើងថា: ការនៅច្រឡូកច្រឡំក្នុងកាមភោគី មិនមែនជាផ្លូវនាំទៅដល់នៃព្រហ្មលោកឡើយ ទើបលះបង់នូវទ្រព្យស្រីគ្នាផ្ទះសំបែងក្រុមគ្រួសារចេញទៅបួស—ជាយោគី ប្រើបំសុកូលចរ (គឺសំពត់ដែលគេលះចោល) ជាគ្រឿងស្លៀកដណ្ដប់ បរិភោគភត្តាហារចំពោះតែរបស់ដែលសូមគេបានមក ហើយបំពេញទុក្ក-រកិរិយា គឺទរមានខ្លួនដោយវិធីផ្សេង ៗ ដោយការមិនយកចិត្តទុកដាក់ដល់រាងកាយនឹងសេចក្ដីសុខនៃរាងកាយ ហើយសង្ឃឹមទុកថា: កាលបើធ្វើរាងកាយឲ្យទ្រុឌទ្រោម ហើយនឹងនៅសល់ត្រឹមតែមនោ (ចិត្ត) ដែលរួចស្រឡះចាកកាយដ៏លាមក ហើយមនោដ៏បរិសុទ្ធនោះនឹងទៅកាន់ស្ថានព្រហ្ម គឺសេចក្ដីសុខយ៉ាងប្រសើរ មិនមានវេលានឹងត្រូវវិលត្រាយមកកើតតទៅទៀត ៗ ដូចនេះ ក៏ល្មមនឹងឃើញបានថា: សេចក្ដីបំណងរបស់មហាវីរៈ នោះក៏ស្រដៀងគ្នានឹងព្រះពុទ្ធជាម្ចាស់ខ្លះដែរ គឺបំណងនឹងលះសេចក្ដីស្រវឹងក្នុងកាមគុណារម្មណ៍ដែលពួកព្រាហ្មណ៍មិនប្រដៅឲ្យគាត់បង់ឡើយ, ព្រោះបើតាមលទ្ធិរបស់ព្រាហ្មណ៍ប្រកាន់ថា: បុរសណាមិនមានបុត្រលុះស្លាប់ទៅហើយត្រូវធ្លាក់ទៅក្នុងនរក

មួយបែបហៅថា "បុត្រ" កូនជាអ្នកជួយឲ្យរួចផុតអំពីនរកនេះបាន ទើបហៅថា "បុត្រ" ។ លទ្ធិនេះ ពួកព្រាហ្មណ៍ប្រកាន់យ៉ាងម៉ឺងម៉ាត់ហើយទូន្មាន—ប្រៀនប្រដៅផងគ្នានឹងគ្នាជាដរាបទាល់តែកើតសេចក្ដីជឿប្រកាន់ថា: ស្ត្រីណាបានព្រមខ្លួនសម្ពន្ធនឹងព្រាហ្ម—ណ៍ហើយ មានកូនរាប់ថាជាបុញ្ញកិរិយាម្យ៉ាង ។

មហាវីរៈនឹងព្រះពុទ្ធជាម្ចាស់មានសេចក្ដីយល់ត្រូវគ្នាថា: លទ្ធិដូចបានពោលមកនេះ មិនមែនជាប្រយោ-ជន៍ចារក្នុងផ្លូវវិសមាធិឡើយ, គ្រាន់តែជាគ្រឿងចំលាយព្រហ្មចរិយធម៌ ទើបទ្រង់ហាមឃាត់ជាដាច់ខាត , ហើយសង្ឃឹមថា: បើកចាត់បង់របស់ដែលជាសត្រូវដ៏សំខាន់ដល់ព្រហ្មចរិយធម៌បានហើយ ទើបអាចនឹងបំ-ពេញតបៈឲ្យមានផលចាក់ធ្លុះដល់សេចក្ដីសុខដ៏ខ្ពស់បំផុតបាន ៗ តែមហាវីរៈចូលចិត្តយល់ខុសថា. នឹងស-

សម្រេចសេចក្ដីប្រាថ្នាក្នុងការរំលត់ឲ្យស្ងួនឲ្យស្ងប់រម្ងាប់ទៅបាន ដោយវិធីទុក្ករកិរិយា ទើបមិនយឺតយូរ ពួកសិស្សរបស់គេមានដំណើរលឿនជាងសាស្ដា តំយល់ថា៖ អ្នកដែលតាំងចិត្តខ្ជាប់ខ្ជួនមិនអើពើនឹងកាយ មិនគួរមានសេចក្ដីអៀនខ្មាសឡើយ ។

★ ★ ★

## ខ្មែរ និង ចិន

ជនជាម្ចាស់នៃកម្ពុជរដ្ឋ គឺប្រជាជនខ្មែរ ដែលមានព្រះមហាក្សត្រិយ៍ សោយរាជសម្បត្តិជាព្រះប្រមុខរដ្ឋ និងព្រះរាជរដ្ឋាភិបាលជាអ្នកគ្រប់គ្រងរាស្ត្ររដ្ឋ ។ ប្រទេសកម្ពុជាក៏ជារដ្ឋមួយមានមុខមាត់ ស្មើនឹងប្រទេសឯទៀតក្នុងសាកលលោក ដោយទើបនឹងបានឯករាជ្យសម្បូណ៌ ក្រោយពីការស្ថិតនៅក្រោមនឹមដែកនៃអាណានិគមនិយមបារាំងសែសអស់ជិត ១ សតវត្សរ៍ ។ នៅក្នុងប្រទេសនេះ មានជនបរទេសជាច្រើន ដែលចូលមកប្រកបការងាររកស៊ីចិញ្ចឹមអាជីពក្រុមគ្រួសារ ហើយច្រើនតែមានសម្បត្តិស្ដុកស្ដម្ភជាងប្រជាជនខ្មែរ ដោយបំពោះគឺជាតិចិន ។ របររកស៊ីរបស់ខ្មែរច្រើនខាងកសិកម្ម ចិនច្រើនខាងពាណិជ្ជកម្ម ។ ចិនជាជនបរទេសមិនមែនជាម្ចាស់រដ្ឋទេ ។

រឿងពិសេសមួយ ដែលគួរភ្ញាក់ខ្លួន គឺខ្មែរទន្ទឹងឲ្យមានថ្ងៃបុណ្យមកដល់ នឹងបានឧបបួលគ្នាស្លៀកពាក់យ៉ាកុំជាន់តែងខ្លួនប្រាណ ដើរលេងសប្បាយហ៊ុំហាខ្លះ ស្កាត់ទៅជួបអ្នកនេះ នាងនោះឯទីឯណោះក៏មាន ខ្លះដើរអឺតអើតដោយហាងទំនិញចិន ដើម្បីពិនិត្យមើលរបស់ដែលខ្លួនត្រូវការចាប់តាំងពីអ្នកក្រុង ឡើងភ្ញាក់អស់ទាំងអ្នកស្រែចំការ សុខចិត្តបញ្ឈប់ការងាររបស់ខ្លួនចំណាយវេលាបបួលគ្នាទៅលេងបុណ្យ ។ សំលៀកបំពាក់នៃអ្នកទាំងនោះបើប្រសិនជាចាំឈរពិនិត្យមើលពេលដែលដើរចេញទៅតាំងហ្លួង ។ មុខជាភាគច្រើនសុទ្ធតែប្រើពណ៌ខៅរំយគន់មើលទៅដូចជាក្អែកទឹកចុះបឹង ហើយគេមិនចោលសង្វាដ៏ (ក្រមា) គេទេ ព្រោះខ្លាចត្រូវអាបត្តិ ។ គឺអ្នកស្រែចំការស្លៀកពាក់តែងខ្លួនប្រាណមិនបានដូចអ្នកក្រុងទេ តែគួរណាស់តែកុំនិយមប្រើពណ៌ខ្មៅឲ្យសោះ ព្រោះពណ៌ខ្មៅ ជាគ្រឿងសំគាល់មនុស្សខ្ជិល ហើយគួរកុំប្រើសង្វាដ៏ (ក្រមា) បង់កដើរផ្សារជាប់ជានិច្ច មិនហ៊ានឲ្យឃ្លាតមើលតែលោកសង្ឃពេក ។

ថ្ងៃបុណ្យកន្លងទៅ ៗ ប្រាក់កាសត្រូវចំណាយចេញនេះចេញនោះ ។ ប្រាក់ដែលខំរកស៊ីបែកញើសហូរដូចទឹក គេត្រូវយកមកចំណាយចោលយ៉ាងហ៊ឺហា ពេលបុណ្យនោះ ។ ចុះប្រាក់ធ្លាក់លើអ្នកណា? លើអ្នកលក់ទំនិញ ។ អ្នកណាលក់ទំនិញ? ចិន-យួន... ។

ឯចិនក៏ទន្ទឹងចាំថ្ងៃបុណ្យបានយូរថ្ងៃហើយ វា

ត្រេកអរណាស់ ព្រោះវាសង្ឃឹមថា នឹងបានរៀបចំ ចំណីចំណុកភោជនាហារប្រដាប់ប្រដាផ្សេងៗទុកជំរាបសួរសុខទុក្ខខ្មែរ ដែលគេសប្បាយមកលេងបុណ្យ ៗ អ្នកណាជាអ្នកទិញ? ខ្មែរភាគច្រើនតាំងអ្នកក្រតាំងអ្នកស្រែចំការ, ប្រាក់ខ្មែរត្រូវធ្លាក់ទៅនៅក្នុងដៃចិន តាំងអស់ ៗ ចិនវាមិនដើរច្រើនដូចខ្មែរទេ ពេលបុណ្យរបស់ខ្មែរ គេណាយកិច្ចរបស់វាយ៉ាងណា វានៅតែប្រតិបត្តិជានិច្ច ដូចជាការលក់ដូរគោរៀនសូត្រ សូម្បីខ្មែរឈប់ វាក៏មិនឈប់ ព្រោះវាថាមិនមែនជាបុណ្យសម្រាប់ជាតិវា, វាមិនត្រូវចំណាយវេលាដើរឥតប្រយោជន៍ទេ ៗ កាលណាបុណ្យចូលឆ្នាំ បុណ្យផែអ្នកតាវាមកដល់ភ្លាម ចិនបិទទ្វារផ្ទះគ្រប់ ៣ ថ្ងៃ ដើម្បីដើរលេងកំសាន្តសប្បាយក្នុងបុណ្យនក្ខត្តឫក្សសម្រាប់ជាតិវា ៗ តើពេលនោះខ្មែរយើងយ៉ាងណា? ខ្មែរមិនចាំបាច់តែបុណ្យខ្មែរទេ ទោះបីបុណ្យជាតិណាក៏ខ្មែរនៅតែសប្បាយជាដរាប ដូចជាចូលឆ្នាំចិន-យួនខ្មែរក៏ចូល ដល់ចូលឆ្នាំបារាំងខ្មែរក៏ចូលដល់ពេលផែអ្នកតាខ្មែរក៏ផែ ម៉្លោះហើយក្នុងមួយខួប ៗ ខ្មែរត្រូវមានឆ្នាំ ៣ ដង ហើយបានបំរើនអាយុច្រើនជាងចិន-យួន-បារាំងទៅទៀត ៗ

មានការណ៍ដ៏ចំឡែក គឺបើថ្ងៃផែអ្នកតាចិន-យួនពានទៅលើថ្ងៃមាឃបូជាដែលកម្មវិធីរដ្ឋាភិបាល បានតម្រូវឲ្យបុគ្គលិករាជការគ្រប់ប្រភេទបានឈប់ នោះនៅតាមវត្តអារាមក្នុងលាចថ្ងៃមាឃបូជានោះ គេមិនសូវឃើញចូលទៅធ្វើបុណ្យក្នុងវត្តទេ ច្រើនតែឃើញដើរផែអ្នកតាចិនទៅវិញ ៗ ក្នុងករណីយនេះឃើញថាប្លែកពីជាតិគេ សាសនាគេឯទៀតណាស់ ព្រោះខ្មែរសុខចិត្តយកកិត្តិយសទៅប្រគល់ឲ្យជាតិគេ ប្រពៃណីជាតិគេ ហើយលះបង់ចោលនូវកិត្តិយស សម្រាប់ប្រទេសសម្រាប់សាសនារបស់ខ្លួន ៗ សង្ឃឹមថាកំផែលដ៏លាមកបែបនេះប្រហែលជាជ្រះស្រឡះ ពីសង្គមខ្មែរហើយ ព្រោះប្រទេសជាតិសាសនាក្នុងកម្ពុជរដ្ឋក៏បានទទួលនូវសិទ្ធិសេរីភាពល្មមឲ្យខ្មែរសម័យឯករាជ្យ កក់ក្តៅជ្រះថ្លាដែរហើយ ៗ

អូ! ក្មួយ, ចុះជនជាតិខ្មែរក្នុងពេលមានបុណ្យសម្រាប់ប្រទេសម្តងៗ ម្តេចក៏មិនសូវឃើញមានចាត់ចែងអីវ៉ាន់លក់ដូរនឹងគេ? ខ្ញុំខ្មាសគេណាស់ ព្រោះការលក់ដូរជាកិច្ចថោកទាប ហើយខ្មែរភាគច្រើនមិនសូវនិយមទិញអីវ៉ាន់ខ្មែរគ្នាឯងផង (នេះជាគំនិតរបស់ខ្មែរខ្លះ) ៗ បុរសជាតិអាមេរិកាំងម្នាក់ឈ្មោះលោកជ័រ្ក-អលខុត ( gcorge olcott ) ជាអតីតចាងហ្វាំងមន្ទីរឃោសនាអាមេរិកាំងនៅភ្នំពេញ បានពោលសរសើរសុភាពនឹងវិរិយភាពនៃស្ត្រីខ្មែរថា គួរឲ្យស្ងើចសរសើរ ដល់សេចក្តីអត់អាចក្លាហាន នឹងសេចក្តីព្យាយាមនៃស្ត្រីខ្មែរណាស់ តែពាស់ខ្លាំងត្រង់សម្បូណ៌ទៅដោយមន្ទក្ខូត សេចក្តីអៀនមុខមូរ) អង់គ្លេសថា Timid (ថៃមីដ) ច្រើនពេក ៗ

បើពិនិត្យតាមសំដីលោកចាងហ្វាំងនេះ ឃើញថាពិតដោយច្រើនមែន ៗ តើនារីខ្មែរសម័យនេះ នៅតែ

សុខចិត្តឲ្យគេថា មានមន្ទកូតច្រើនតទៅទៀតឬ?

បំពោះសំលៀកបំពាក់នៃប្រជារាស្ត្រ បើប្រសិនជាអាចចាត់ការបាន សូមរកការតម្រូវបែបផែនឲ្យប្រជារាស្ត្រវិញស្លៀកពាក់ឲ្យបានសមឋានៈ ជាអារ្យជននៅក្នុងអារ្យប្រទេស ដូចប្រទេសដែលមានអារ្យធម៌វឌ្ឍនធម៌ឯទៀត ៗ កុំទុកឲ្យនៅប្រើសំលៀកបំពាក់តាមទំនើងចិត្តចង់ដូចសព្វថ្ងៃ មើលទៅមិនប្រាកដជាសំលៀកបំពាក់បែបជាតិណានោះ ។ គួរតម្រូវឲ្យវិញស្លៀកពាក់ឲ្យដូច ៗ គ្នា តាមបែបប្រុសស្រី (វៀរចាកពណ៌ទៅ) ។ សម័យមហាបដិវត្តនៅប្រទេសជប៉ុន រាជការគេបានតម្រូវឲ្យពលរដ្ឋជាតិគេ ស្លៀកពាក់ជាឯកសណ្ឋាន បើមានជនជាតិណាមួយស្លៀកពាក់ដូចគេ ត្រូវសំគាល់ថាជាតិជប៉ុនទាំងអស់ បើមានទុក្ខធុរៈត្រូវជួយគ្នាពប់អានគ្នា កុំមើលបណ្តាំ ។ នេះជាលទ្ធផលនៃសំលៀកបំពាក់ឯកសណ្ឋាន ។ ក្នុងបច្ចុប្បន្ននេះ ប្រទេសភូមាគេក៏បានរៀបសំលៀកបំពាក់ពលរដ្ឋគេ ឲ្យបានសមរម្យរួចទៅហើយដែរ ។

ឯប្រទេសយើងវិញក៏មិនមែនជាលំបាកដល់ថ្នាក់ដែកមិនបាននោះទេ ។

កតិព័ន្ធ

ខ្មែរជាន់នេះ ត្រូវតែបេះ ក្អាក់ក្អករើ
ខំប្រឹងប្រែង ប្រកបការ ទាំងប្រុសស្រី
កុំគប្បី ឃ្លានសប្បាយ ហួសមាត្រា ។
ខំរៀនលក់ ដូរទំនិញ ពេញទាំងរដ្ឋ
ឲ្យបានស្ទាត់ ដូចជាតិគេ ណាមិត្តណា
ដើម្បីស្ទួយ នូវប្រទេស ឲ្យថ្លៃថ្លា
បានវឌ្ឍនា មានកេរ្តិ៍ឈ្មោះ ល្បោះសំឡេង ។
គួរខ្មាសចិន ចិនជាជន ជាតិបរទេស
ខំរកស៊ី ឥតមានធ្វេស មិនដើរលេង
នៅផ្ទះចិន រង្គលត៍ខ្ទ តែខ្មែរឯង
ឲ្យចាត់ចែង ល្ហូល ប្រាសផ្ទះរ៉ា ។
គួរអាសូរ ដល់ជនជាតិ នៃយើងណាស់
មានឋានៈ ជាម្ចាស់ កម្ពុជា
ម្តេចសុខចិត្ត យកកំឡាំង បម្រើ
ជាតិផងគ្នា គួរតែខ្មែរ យើងប្រឹងជួយ ។
ទាំងនារី ត្រូវតែខំ កុំខ្ជិលប្រាណ
ខំស្ទុះស្ទា លុះតែបាន កុំព្រងើយ
ការអៀនខ្មាស របស់ចាស់ មកយូរហើយ
កុំកៀកកើយ លះចោលខ្ចុះ ទើបប្រពៃ ។
ហេតុមិនគួរ ឲ្យនាំខ្មាស គួរកុំខ្មាស
បើអៀនផ្តាស មុខជានាំ គ្មានសិរី
ហេតុគួរខ្មាស ទើបគួរខ្មាស បើគប្បី
ហេតុគួរស្តី ត្រូវតែស្តី ឲ្យពិស្តារ ។
មិនគួរឡើយ បានខាងតែ ក្រោមម្លប់
ដើរចុះទៅ ឲ្យគេគន់ តែកាយា
ការប្រពៃ របស់ស្រី គឺកិច្ចការ
គួរធីតា នាំខំប្រឹង កុំទំនេរ ។
ព្រោះប្រទេស របស់ជាតិ ឯករាជ្យហើយ

កុំធ្វេសឡើយ　កុំធ្វើខ្លួន　ឲ្យទទេ
បើនាងខ្ជិល　ចេះតែខិល　មិនដូចគេ
មិនយូរទេ　មុខជារដ្ឋ　លំខ្ទើ ៗ
ពេលនេះទៀត　ហេតុតែបុណ្យ នៃនារី
ព្រះភូមិ　ទ្រង់ប្រទាន　សិទ្ធិសេរី
ដល់កញ្ញា ឯករាជ្យ　សម័យថ្មី
ឲ្យកាន់កាប់ ការផែនដី　ដូចបុរស ៗ
ចូរខំប្រឹង　ប្រឹងឲ្យតឹង　ខំការពារ
សិទ្ធិសេរី　ដែលរាជា　ផ្ដល់មកនោះ
កុំឲ្យបាត់　រសាត់ក្ដាត់　វិញឲ្យសោះ
នារីអើយ　គួរស្រណោះ សិទ្ធិខ្លួន ៗ

## គុណធម៌ ៥ យ៉ាង

វិស្រុន វិកុសា វាចា　វិទ្យា　វិនយេន ច
វិត្តាវិ បញ្ចតិនោ　នរោ នាយាតិ គោរវំ ៗ
ជនណាប្រាសចាក　ចោលគុណធម៌
ទាំងប្រាំបវរ　សម្រាប់លោក
គឺ ១ ស្លៀកពាក់　ស្អាតមានរជោគ
ពីរមិនស្មោគគ្រោក　ស្អិតស្អាងកាយ ៗ
បីសំដីផ្អែម　ល្ហែមពិសេស
បួនវិជ្ជាចំណេះ　ចេះសព្វសាយ
ប្រាំវិន័យក្រឹត្យ　ក្រមទាំងឡាយ
ជននោះមិនអាយ　គេគោរព ៗ

ហ. អ.

★ ★ ★

## ប្រវត្តិ

# ពាហិរសាសនា សង្ខេប

សំដែងអំពីកំណើតសាសនា ( ពាក្យប្រៀនប្រដៅ ) ដែលកើតឡើងក្នុងលោកនេះ មានគតិជាពីរយ៉ាងគឺ:

១– កើតឡើងដោយគំនិតរបស់អ្នកដែលតាំងផ្ដើមប្រាថ្នារកសេចក្ដីសុខដល់មនុស្សជាតិដូចគ្នា ៗ ព្រោះថា ពួកមនុស្សនេះ ទោះជាគ្មានស្នែងស្រួចដូចគោក្របី, គ្មានក្រចកមុតដូចខ្លា ឬខ្លាំងដូចដំរីនឹងរមាស គ្មានពិសកំណាចកាចដូចពស់ គឺថាគ្មានវត្ថុ ដែលឲ្យគេគួរខ្លាចនៅជាប់នឹងរាងកាយនេះក៏ពិតមែន តែមនុស្សនេះមានពិសកំណាចអាក្រក់លើសពីពិសកំណាចសត្វនានាទៅទៀត ៗ នៅកណ្ដាលពួកមនុស្សឥតធម៌ឥតច្បាប់ បានទុកលំបាកអាចដល់ស្លាប់ លើសពីការនៅកណ្ដាលហ្វូងខ្លា, ដំរីឬសត្វសាហាវដទៃទៅទៀត ៗ

ហេតុនោះ បានជាមានអ្នកប្រាជ្ញមួយ ៗ គិតស្វែងរកឧបាយនឹងដឹកនាំមនុស្សឲ្យបានសុខ ទូន្មានប្រៀនប្រដៅបង្កើតឡើងជាច្បាប់ នាំឲ្យមនុស្សកាន់តាមហាមមិនឲ្យធ្វើអំពើអាក្រក់ដល់គ្នីគ្នាទៅវិញទៅមក ៗ មានមនុស្សនិយមជឿកាន់តាមជាច្រើនឡើង ៗ ពាក្យប្រៀនប្រដៅនេះ ហៅថា “សាសនា” ; សាសនាយ៉ាងនេះឈ្មោះថាកើតឡើងដោយគំនិតដើមល្អតែគំនិត

អ្នកកាន់សាសនាមួយ ៗ នោះផ្សេងគ្នាដោយប្រាជ្ញា គឺជាអ្នកណាមានប្រាជ្ញាតិច ក៏រកសេចក្ដីសុខមកប្រាប់មនុស្សបានតិច, អ្នកណាមានប្រាជ្ញាច្រើនក៏រកសេចក្ដីសុខមកប្រាប់មនុស្សបានច្រើន ។ ហេតុនេះ គួរដឹងថា: សាសនានីមួយ ៗ ក្នុងលោកនេះ សុទ្ធតែល្អគ្រប់តែសាសនា ចាញ់ឈ្នះគ្នាត្រង់ល្អតិចច្រើនប៉ុណ្ណោះ ។

២– សាសនាមួយបែបទៀត កើតដោយគំនិតអ្នកកាន់មិនបរិសុទ្ធ ប្រាថ្នានឹងយកសាសនាជាកម្លាំង ហើយធ្វើអំពើអាក្រក់ណាមួយ ឬដើម្បីនឹងចិញ្ចឹមជីវិតក៏សឹងមាន, ព្រោះគេឃើញថា មនុស្សដែលមានគំនិតតិចរមែងឆោតច្រើន ហើយច្រើនជឿប្រកាន់ផ្សេងៗ គេរកឧបាយអ្វីផ្សេងៗមកតម្រូវឲ្យត្រូវនឹងអ្នកត្រូវការនោះៗ សាសនានេះឈ្មោះថាកើតឡើងដោយគំនិតអាក្រក់ ។

ក្រៅពីសាសនាទាំង ២ នេះ នៅមានសាសនាមួយបែបទៀតសន្និដ្ឋានថា: កើតឡើងដោយគំនិតមនុស្សនឹកស្រមៃស្មានយកច្រើនប្រតិស្ឋយករបស់ដែលចាប់មិនបានស្មានមិនត្រូវ ដូចឃើញអ្វីឬឮអ្វីប្លែកសម្បើម ក៏ស្មានថាប្រហែលជាបានអ្វីវិសេសអស្ចារ្យនៅក្នុងទី-នោះៗ ហើយបបួលគ្នាគោរពបូជា ក៏កើតឡើងជាសាសនាមួយទៀត ។

ក្នុងទីនេះ នឹងលើកទុកសាសនាទាំង ២ ខាងចុងមិនបាច់នាំយកមកសំដែង, នឹងសំដែងតែសាសនាធំ ៗ ហើយមានមនុស្សនិយមកាន់ច្រើនផង ។

បើសំដែងដោយប្រភេទដំបូងមានតែពីរគឺ:

១– ពុទ្ធសាសនា សាសនារបស់ព្រះពុទ្ធជាម្ចាស់ ។

២– ពាហិរសាសនា សាសនាដទៃក្រៅពីពុទ្ធសាសនា ។

លំដាប់នេះខ្ញុំនឹងរៀបរៀងពាហិរសាសនាជាមុន ព្រោះជាសាសនាច្រើនស្ទាត់ក៏បាំងនឹងជួនចិត្តពុកពុទ្ធ-សាសនិកគ្រប់ៗគ្នាកម្រមានអ្នកណាដឹងដល់ ។ ឯព្រះពុទ្ធសាសនាវិញ ច្រើនមានអ្នកចេះដឹងគ្រប់ ៗ គ្នា បើមិនច្រើនក៏តិចតាមសតិបញ្ញាឬការរៀនសូត្រតិច-ច្រើនរៀង ៗ ខ្លួន ។ ឯពាហិរសាសនាដែលខ្ញុំរៀបរៀងតទៅនេះសោត ក៏សំដៅយកតែសាសនាធំ ៗ ហើយពោលល្បោល ៗ ជាសង្ខិត្តន័យ, រើសយកតែសេចក្ដីសំខាន់ ៗ មកពោលខ្លះ ៗ ក៏ពាហិរសាសនាដែលត្រូវពោលក្នុងទីនេះ បើជ្រើសតែសំខាន់ ៗ មកពោលមានតែត្រឹម ៤ គឺ.

១– សាសនាព្រាហ្មណ៍ ឬ ព្រហ្មញ្ញសាសនា

២– សាសនាជិន ឬ ជិនសាសនា

៣– សាសនាមហាម័ទ ឬ ឥស្លាមសាសនា

៤– សាសនាយេស៊ូ ឬ គ្រិស្តសាសនា ហៅថា កាតូលិក ក៏បាន ។

ក៏ការដែលរាប់សាសនាព្រាហ្មណ៍ជាទីមួយ ព្រោះសាសនានេះ កើតមុនសាសនាដទៃ ៗ ទាំងអស់ក្នុងលោក ។ ក្នុងបុរាណសម័យព្រាហ្មណសាសនា

ឧប្បត្តិឡើងក្នុងជម្ពូទ្វីប ជាសាសនាចាស់កើតឡើងក្នុងលោកនេះមុនគេទាំងអស់, ដែលហៅដូច្នេះ ដោយអធិប្បាយថា "សាសនារបស់ព្រះព្រហ្មឬសាសនាតមកពីព្រះព្រហ្ម" ។

ក្នុងលទ្ធិឬសាសនានេះ គេបានបញ្ញត្តយកទេវតាជាព្រះជាម្ចាស់ មាន ៣ អង្គ សឹងមានប្រាកដក្នុងសាស្ត្រាវេទព្រាហ្មណ៍ ។ ព្រះជាម្ចាស់ ៣ អង្គនោះគឺ:

១– បញ្ញត្តយកព្រះព្រហ្ម ជាព្រះមួយអង្គ
២– បញ្ញត្តយកព្រះសិវៈ ជាព្រះមួយអង្គ
៣– បញ្ញត្តយកព្រះវិស្ណុ ជាព្រះមួយអង្គ

## ព្រះព្រហ្ម

ព្រះជាម្ចាស់ឬទេវតាដែលពួកព្រាហ្មណ៍ តែងគោរពបូជាក្នុងសាសនារបស់គេមានច្រើនអង្គ, តែព្រះដែលធំបំផុតមាន ៣ អង្គគឺ: ព្រះព្រហ្ម, ព្រះសិវៈ, ព្រះវិស្ណុ ។ អំពីនេះនឹងពណ៌នាប្រវត្តិព្រះអម្បាលនោះដោយលំដាប់ជាធ្វើបតទៅ ។

ពាក្យថា "ព្រហ្ម" ក្នុងទីនេះជាសាធារណនាម ដែលពប់ថាជាព្រះក្នុងលទ្ធិនេះ គឺគេសំដៅយកព្រះមហាព្រហ្ម ដែលធំជាងគេទាំងអស់ នាមជាអ្វីមិនប្រាកដ, (ក្នុងរឿងពុទ្ធប្រវត្តិថាព្រហ្មឈ្មោះ សហម្បតី ជាធំក្នុងលោក, តែក្នុងរឿងរាមកេរ្តិ៍ហៅព្រះធាតា) មានព្រះជាយានាម "សរស្វតី" មានទេសចិតាដែលប្រាកដនាម ៣ អង្គគឺ: ព្រះទក្សៈ ១, ព្រះកប្បុត ១, ព្រះនាងសន្ធិយា ១, ។ ព្រះទក្សៈបានជាប្រជាបតីរបស់លោក, ព្រះកប្បុតបានជាអ្នកវិសេស ១ ក្នុងសម័យនោះ, នាងសន្ធិយាបានជាព្រះជាយាព្រះសិវៈ មុននាងឧមា ។ មានលក្ខណៈជាគ្រឿងសំគាល់ តាមរូបដែលគេសាងទុក គឺទ្រង់ហង្សជាពាហនៈ, ព្រះហស្តច្រើនកាន់ផ្កាឈូក, ព្រះភក្ត្រច្រើនធ្វើជា ៤ ព្រះភក្ត្រតែមួយក៏មានខ្លះដែរតែតិចៗ ហេតុដែលគេធ្វើព្រះភក្ត្រ ៤ ដូច្នេះ ដោយអនុមានមើលប្រហែលជា សំដៅយកត្រង់សេចក្ដីថា ព្រះព្រហ្មរមែងប្រកបដោយព្រហ្មវិហារធម៌ ៤ គឺ មេត្តា, ករុណា មុទិតា, ឧបេក្ខា, តែងផ្សាយព្រហ្មវិហារនេះ ដល់ពពួកសត្វគ្រប់ទិសទាំង ៤ ឲ្យបានប្រកបដោយសេចក្ដីសុខពល់ប្រាណពុំបានបើសមុខ ។ ហេតុនោះទើបគេសាងជាព្រះភក្ត្រ ៤ ជាគ្រឿងសំដែងព្រហ្មវិហាររបស់លោកនេះឯង ។ ជាអ្នកទ្រង់ញាណដ៏វិសេសអាចជ្រាបហេតុផល ក្នុងអតីតអនាគតបច្ចុប្បន្នបានមានព្រហ្មវិទ្យាដ៏ប្រសើរជានិយ្យានិកៈអាចញុំាងអ្នកប្រតិបត្តិតាមឲ្យរួចចាកសង្សារវដ្ដ ទំនងកាត់បង់នូវសេចក្ដីសន្ទិះសង្ស័យក្នុងហេតុផលទាំងពួងបាន ដោយមិនមានទេសទាស់ ដូចមានសំដែងក្នុងគម្ពីរ "ពួតរ យោបនិស័ទ" "មុក្តិកោបនិស័ទ" ថាជាអ្នកទ្រង់នៅគានុភាពដ៏សក្តិសិទ្ធិ, អ្នកណាមួយមានចិត្តភក្ដីបំពេញតបៈ ត្បោះព្រះអង្គដោយមុតមាំហើយ អាចប្រសិទ្ធិប្រទានពរឲ្យសម្រេចប្រយោជន៍តាមដែលត្រូវការ ។ ព្រះអង្គជាបិតា ឬជនករបស់លោក គឺទ្រង់មាននាងសរស្វតី

ជាទេពី មានព្រះចក្សុៈជាដើមជាព្រះទុរស ព្រះចក្សុៈលើកធិតា ២៧ ឲ្យទៅជាភរិយា របស់ព្រះសោមៈ ១៣ ទៀតឲ្យទៅជាភរិយាព្រះកាស្យបៈ អ្នកទាំងនេះមានកូនចៅដំណពូជពង្សជាមនុស្ស គឺគេៈជាដំបូងបង្អស់ ទើបរាប់ជាព្រះព្រហ្មជាបិតារបស់លោក ព្រះចក្សុៈ ជាប្រជាបតីរបស់លោក ដោយប្រការដូច្នេះ ។ តែក្នុងគម្ពីរ " ព្រហ្មាណ្ឌបុរាណម៍ " សំដែងផ្សេងអំពីនេះថាកាលនឹងកើតជាទឹកដីឡើង គឺព្រះមហាព្រហ្មទ្រង់និម្មិតប្ញុំបឲ្យកើតជាអណ្ឌជាតិ គឺជាពងមួយ ហៅថាពងព្រះព្រហ្ម, តមកទ្រង់បំបែកពងនោះឲ្យទៅជាលោក ហើយទ្រង់បែងភាគឲ្យមកកើតជាមនុស្សអាស្រ័យនៅក្នុងលោកនេះដំបូងតែ ២ នាក់ ប្រុស ២ ស្រី ២ ប្រុសហៅថា " បុម " ស្រីហៅថា " វិរជ្ជា " ។ បុមនិងវិរជ្ជានេះ រួមសង្វាសគ្នាទៅ ទើបកើតពូជតរពេញពាសទាំងលោក ដូចដែលយើងឃើញនៅសព្វថ្ងៃនេះស្រាប់ បំណែកឯគម្ពីរ "បទុមបុរាណម៍" សំដែងផ្សេងពីនេះទៅទៀតថា ដំបូងដែលនឹងកើតលោកនេះឡើង មានផ្កាឈូកមួយផុះឡើងឲ្យឃើញប្រាកដជាមុន ក្រោយនោះទើបកើតលោកនេះឡើង តែនៅមិនទាន់មានមនុស្សកើតឡើយ ទាល់តែពួកព្រហ្មនាំគ្នាចុះមកលេងនៅផែនដីថ្មីនោះធុំក្លិនគិញមដីថ្មីឈ្ងុយឈ្ងប់មុខគួរឲ្យឆ្ងាញ់ ក៏នាំគ្នាបរិភោគ ; លុះបរិភោគយូរទៅជាប់ឈានហោះទៅព្រហ្មលោកវិញមិនរួចក្លាយទៅជាមនុស្ស អាស្រ័យនៅ ក្នុងលោកដរាបដល់សព្វថ្ងៃនេះ ។ ដោយហេតុទាំងឡាយដែលបានបរិយាយមកនេះ ពួកព្រាហ្មណ៍ទើបរាប់អានព្រះព្រហ្ម និងសេចក្ដីប្រកាន់ត្រកូលរបស់គេជាត្រកូលខ្ពស់បំផុតជាងត្រកូលទាំងពួង មានក្សត្រជាដើម ដោយតំណត្រកូលមកពីព្រហ្មវង្ស ។

## ព្រះសិវៈ

សិវៈជាឈ្មោះព្រះជាម្ចាស់ របស់ព្រាហ្មណ៍១អង្គ ប្រែថា " ករុណា " ថា " កម្រមប្រាសចាកទុក្ខភ័យ ", នាមនេះដើមឡើយជានាមផ្កាយ ក្នុងពួកបញ្ចានាគក្នុងរឿងព្រះចន្ទ និងជានាមព្រះរាជាគ្រង់ក្រុងហៃហយបុរី ( ដូចមានពោលក្នុងលទ្ធិរាប់អានព្រះចន្ទ ) ។ ដើមកំណើតរបស់ព្រះសិវៈមានរឿងពោលថា កាលនោះព្រះព្រហ្មយកឈើគៀរញើស ត្រង់ប្រជុំចិញ្ចើម ស្បែកធរលាត់ លោហិតហូរចេញមកស្រក់ទៅក្នុងទឹកកើតឡើងជាទេវបុត្រ១អង្គនាម "រុទ្រៈ" តែញាយាមសុំនាមនេះ នឹងព្រះព្រហ្មដល់ទៅ៨ដង ទើបបាន វេលាក្រោយដែលបានជាព្រះហើយ ទើបមាននាមទាំង១០០០យ៉ាង មានសិវៈ, ឥស្វរ (ឥស្វរៈ) សយម្ភូ , ភវាធិបតី , នីលកណ្ឋ , និងភៃរវៈជាដើម , ទីលំនៅចិតៈនៅក្នុងប្រាសាទលើកំពូលភ្នំកៃលាស (ដែលតាំងនៅលើកំពូលភ្នំហិមាល័យ ជ្រុងខាងជើង មានសម្បុរសដូចប្រាក់ មានកំពូលខ្ពស់ត្រដួចជាប់នឹងមេឃ ) មានព្រះជាយានាមឧមា , តែន័យមួយថា មានព្រះជាយាដើម២អង្គគឺ នាងសន្ធិយា ជា

ពីតាព្រះព្រហ្ម១ , នាងគង្គាជាបងប្អូនរួមមាតាបិតាជាមួយនាងឧមា១ , ទាំងនាងឧមា១ទៀតត្រូវជាព អគ្គិ, តែនាងឧមាប្រាកដជា លើកជាភរិយាអគ្គម-ហេសីក្នុងជាន់ក្រោយមានឧរស ២ អង្គគឺ ព្រះវិឃ្នេស (ដែលយើងធ្លាប់ហៅថា ព្រះគណេស១), ព្រះកត្រិ-កេយ ឬហៅម្យ៉ាងទៀតថា ស្កន្ទកុមារ , មានគោឧសភ១ឈ្មោះ នន្ទិនៈជាពាហនៈ ។ លក្ខណៈព្រះអគ្គិគឺមានព្រះកេសីសម្បុរលឿងរលោងចង្កុំគ្នា នៅកណ្តាលព្រះសិរ, ជាព្រះត្រីនេត្រ គឺមានព្រះនេត្រ៣ ព្រះនេត្រ២នោះ តាំងនៅត្រង់កន្លែងដូចភ្នែកមនុស្សធម្មតា ព្រះនេត្រមួយទៀត តាំងនៅកណ្តាលព្រះនលាដ, ឯព្រះនេត្រទាំង៣នេះជាគ្រឿងសំគាល់ព្រះញាណដែលជ្រាបហេតុផល ក្នុងអតីតអនាគតបច្ចុប្បន្ន , លើព្រះនេត្រទី៣ មានពិណព្រះចន្ទ្របញ្ចេញរស្មីភ្លឺព្រាតៗ ជាគ្រឿងសំគាល់ភពទី១ មានពុកចង្កាវែងភាពយ៉ាងព្រាហ្មណ៍ តែបើតែងព្រះអគ្គិយ៉ាងមហាទេព រមែងគ្មានពុកចង្កា , ព្រះស្បូង បម្រើល មាននាគជាសង្វា ពាក់នៅព្រះស្បូវងជាគ្រឿងសំគាល់ភពទី២ មានឆ្អឹងលលាដ៍ក្បាល បន្ទោចជាផ្កាពាក់នៅស្បូវង ឬប្អូនកាលពាក់នេះព្រះហស្ត ជាគ្រឿងសំគាល់ភពកល្បភពយុគ, ទ្រង់ស្បែកជ័រជាព្រះភូសា, មានស្បែកខ្លាជាកម្រាលរងអង្គុយ របៀបតែងអង្គដូនកាលទ្រង់បែបឫសី ដោយភាវៈជាមហាយោគី , ទ្រង់កាន់ធ្នូឈ្មោះបញ្ញកៈ និងគទា (ដំបង) និងព្រះខ័នឬសរនិងត្រីសូល៍ មានគោមួយឈ្មោះឧមរូ ។

ព្រះសិវៈ ជាមហាទេពដ៏វៃក្រៃលែងជាងទេវតាទាំងឡាយជាអ្នកទ្រទ្រង់នូវបិល្បសាស្ត្រនិងនាដសាស្ត្រ គឺទ្រង់ចេះស្ទាត់ក្នុងក្បួនក្បាច់របាំច្រើនបែបច្រើនយ៉ាង ជាមហាយោគី គឺជាឫសីធំ ប្រកបសេចក្តីព្យាយាមបំពេញតបៈ ជាអ្នកសាងលោក ជាបិតារបស់លោក ជាអ្នកទ្រង់នូវអានុភាព ជាអ្នកទ្រទ្រង់នូវគុណ ។ ក្នុងគម្ពីរសិវបុរាណ៍ម និងគម្ពីរសិរកសាគរ សំដែងអំពីការសាងលោក របស់ព្រះសិវៈថាៈ ទ្រង់វះនូវសាច់ភ្លៅឲ្យឈាមមួយដំណក់ស្រក់ចុះក្នុងទឹកកើតជាពង ។ នោះបែកជាពីរចំហៀង មួយចំហៀងទ្រង់និម្មិតឲ្យទៅជាសួគ៌លោក , មួយចំហៀងឲ្យទៅជាមនុស្សលោក លំដាប់នោះកើតបាន "បុម" ជាតិបុរសគឺជីវៈ ( ជីវិត ) ឬវិញ្ញាណរបស់លោកឡើង„ បុមនោះទើបសាងប្រជា-បតី គឺបិតាលោកទាំងឡាយមួយតំណមកទៀត ប្រ-ជាបតីអម្បាលនោះ កសាងប្រជាជនតៗទៅ កើតជាផៅពង្សវង្ស មនុស្សនៅក្នុងលោកនេះច្រើនដោយលំដាប់ ដោយហេតុនោះទើបលោកហៅបុមនោះថា បិតាមហា ប្រែថា "បិតាធំ" ។

ក្នុងគម្ពីរឫគវេទ បុម បុរសដែលកើតឡើងអំពីពងជាយក្ខត្តដើមបង្អស់ ដែលព្រះជាម្ចាស់សម្លាប់បូជាស្រេចហើយ ទើបព្រះជាម្ចាស់យកកាយយក្ខនោះ មកសាងជាលោកនេះឡើង បានដឹងជីវិតត្រូយគឺតត្រូយដ៏មានជីវិត មិនមែនអវិញ្ញាណកសង្ខារ ទើបរាប់ថាជាបុរស

នេះឯង, ថាលោកនេះនឹងលោកខាងមុខ កាលសម្លាប់យក្សនោះហើយ ព្រះសិវៈទ្រង់ទឹកអាណិតដល់គាត់ ទើបយកលលាដ៍ក្បាលមកកាន់ទុកជានិច្ច, រឿងត្រង់នេះ សុំឲ្យមើលព្រះឥសូរ រូបខ្លះនឹងឃើញលលាដ៍ក្បាលខ្មោចនៅព្រះហស្តជួនកាលនៅក្រោមជង្គង់ជួនកាលដោតខ្សែពាក់ដូចផ្គាំ ។

ន័យមួយទៀតថា មានធម្មជាតិមួយយ៉ាង ហៅថា "ប្រក្ឫតិ" កើតអំពីបុរស' លោកប្រក្ឫតិនេះ ជាតួដើម ឬជាធម្មតាជាតួអំណាច ដែលបណ្ដាប់ឲ្យវត្ថុនានាកើតឡើងក្នុងលោក, នឹងបណ្ដាលវត្ថុទាំងពួងនោះឲ្យប្រព្រឹត្តទៅដោយប្រភេទផ្សេងគ្នា តាមប្រក្ឫតិនិយម ដូចយ៉ាងបណ្ដាប់ធាតុនានាៗឲ្យមករួមផ្សំគ្នា កើតឡើងជាព្រឹក្សជាតិជាដើមឲ្យមានលក្ខណៈផ្សេងគ្នាច្រើនប្រភេទជាអនេកប្បការ, កើតជាឈើយ៉ាងនេះហើយ នឹងប្រែទៅជាឈើដទៃមិនបាន អាស្រ័យអំណាចប្រក្ឫតិ ឲ្យប្រព្រឹត្តទៅឯងគ្រប់ប្រភេទ ។ កំរឿងបុរសនេះ មានន័យសំដែងផ្សេងគ្នា ក្នុងខ្លះថា: ជាភាគរបស់ព្រះឥសូរ ក្នុងខ្លះថា ជាភាគរបស់ព្រះនារាយណ៍, ដូច្នេះនឹងសម្រេចថាជាភាគរបស់ព្រះណាមួយក៏មិនងាយនឹងគិតៗ

ដោយសេចក្ដីជឿថា: ព្រះសិវៈជាបិតាលោក ជាអ្នកសាងលោក ពួកអ្នកកាន់សាសនានេះ ទើបប្រតិស្ឋសាងអនុស្សាវរីយ៍មួយយ៉ាង ទុកជាការរលឹកក្នុងកិច្ចសាងលោក គឺធ្វើជារូបសិវលិង្គ "លិង្គព្រះសិវៈ" នឹងរូបនាងឧមាយោនី "យោនីនាងឧមា" តាមដែលធ្លាប់ឃើញមក ច្រើនធ្វើដោយថ្ម ហើយបញ្ចុះភ្ជាប់គ្នា យកទៅដម្កល់ទុកនៅទីវិហារ ឬទីសម្រាប់គោរពបូជាឯណានីមួយ ( រូបនេះនៅទីបូកណស្ថាន ក្រុងនគរធំ មានច្រើនណាស់ ) តែខ្មែរយើងច្រើនហៅថាថ្ម "សយម្ភូ" ហេតុនេះ ទើបនាងឧមា មាននាមថា "គៅរី" ( នាងជាមាតារបស់គត ) ។ រូបនេះមិនមែនសាងទុកតែជាអនុស្សាវរីយ៍ប៉ុណ្ណោះទេ ទុកសម្រាប់ធ្វើពិធីសិវរាត្រីលាងបាបចង្រៃឧបទ្រពទាំងពួងផង ។

សំដែងអំពីភាគខាត នឹងព្រះគុណដទៃទៀតរបស់ព្រះ "រុទ្រៈ" ថាជាអ្នកមានអំណាចពន្លឹក អាចនឹងលាងបំផ្លាញលោកនេះ ឲ្យវិនាសទៅក៏បាន ទើបមាននាមថា "ភៃរវៈ" ប្រែថា "អ្នកហោងយ៉ាងសម្បើម មុខគួរស្ញែង" តែលាងដូច្នេះគេរាប់អានថាជាល្អ ព្រោះថាកាលទ្រង់លាងរលីងទៅហើយ អាស្រ័យព្រះមហាករុណា ក៏ទ្រង់ជប់ឬស្ថិតសាងលោកជាថ្មី ឲ្យស្អាតប្រាសចាកមន្ទិលឡើងវិញ, ព្រោះព្រះគុណនេះ ទើបគេហៅព្រះរុទ្រៈថា សិវៈករុណាឬជប់ឲ្យស្អាតមួយយ៉ាងទៀត ដោយហេតុទ្រង់ជាអធិបតីក្នុងសារពើគ្រប់យ៉ាង, ដូចយ៉ាងនឹងលាងឲ្យសូន្យទៅក៏បាន លាងហើយនឹងជប់ឲ្យកើតឡើងវិញក៏បាន, ទើបមាននាមថា ឥសូរព្រោះជាធំក្នុងការសាងសារពើនោះៗ ។ ព្រះសិវៈជាព្រះគុណក្ដីក្រាស់ទៅដោយគុណ មានព្រះហឫទ័យពេញទៅដោយករុណាសង្គ្រោះ ទេវតា, យក្ស, មារ មនុស្សខ្លះទៅ ទោះបីអាក្រក់ក្ដីល្អក្ដីមិនថា, តែអ្នកណា

មានចិត្តភក្តីបំពេញតបៈពិធីមាំទាំហើយ ក៏គាត់ប្រទានពរឲ្យអ្នកនោះជាដរាប ពរដែលទ្រង់ប្រទាននោះ ជាឲ្យទោសឬឲ្យគុណយ៉ាងណា មិនសូវអំពល់នឹងពិនិត្យ ចួនកាលត្រឡប់ឲ្យទោស ដល់ព្រះអង្គឯងវិញក៏មាន, ដូចជាពរដែលទ្រង់ប្រទានដល់អសុរម្នាក់ឈ្មោះ - "ព្រឹកាសូរ" ជាបុត្រកាស្យបាសូរ នឹងពរដែលប្រទានដល់យក្សជាទ្វារបាល ឈ្មោះនន្ទកៈ ជាដើម សុទ្ធតែឲ្យទោសដល់ព្រះអង្គ កុំតែបានព្រះវិស្ណុជួយកុំអីកុនខ្លួន ទ្រង់បានរួចអំពីស្នៀតខ្លួនឯង ក៏ដោយសារគំនិតព្រះវិស្ណុជួយ ។

រឿងនេះជាតួយ៉ាងនៃព្រះមហាករុណា របស់ព្រះសិវៈ

## ព្រះវិស្ណុ

នាមវិស្ណុនេះ ដើមឡើយជានាមព្រះអាទិត្យ តែវេលាក្រោយបានមកជានាមរបស់ព្រះអង្គនេះ នៅមាននាមឯទៀតជាច្រើន មាន ហរិ នារាយណ ជាដើមៗ លក្ខណៈរូបតាមព្រះវិស្ណុនេះ សម្បុរកាយខ្មៅ, ព្រះហស្តដោយប្រក្រតីមានតែពីរ តែអាចបែងភាគជាព្រះ-ហស្ត ៤ ឬ ៨ បាន ព្រះឧរាមានលាយលក្ខណ៍ធ្មត ១ ហៅស្រីវត្ស ទ្រង់អាភរណៈទិព្វពណ៌លឿងទ្រង់ស័ង្ខឈ្មោះបញ្ចជន្យជាអាវុធ ចក្រឈ្មោះ សុទស្សនៈ គទា (ដំបង) ឈ្មោះកោមោទកី ធ្នូឈ្មោះស្រាង្គ, ព្រះសែងខ័ន (សែងខរ) ឈ្មោះនន្ទកៈ នឹងកាន់ផ្កាឈូកជាគ្រឿងសំគាល់ មានគ្រុឌរាជបក្សីជាពាហនៈព្រះ ជាយានាមលក្ខ្មី តែគេថាមានជាយាដើម ២ អង្គ នាមអទិតិ ១ សិរីវលី ១, ឧរសឈ្មោះកាមទេព ទីដែលស្ថិតឈ្មោះកៃកុណ្ឋ ។ ក្នុងវេលាមួយកល្ប ឬមួយថ្ងៃរបស់ព្រះព្រហ្មដែលជាវេលាឈប់សាងលោក, ព្រះវិស្ណុទ្រង់ផ្ទុំលើផ្កាឈូក ចួនកាលផ្ទុំលើខ្នងនាគរាជមួយពាន់ឈ្មោះសេសៈ, តែក្នុងទីខ្លះហៅឈ្មោះស្តេចនាគនោះថា អនន្តនាគរាជ, វេលាផ្ទុំមានទឹកព្រះគង្គាចេញអំពីចុងព្រះបាទជាប្រក្រតី មាននាងលក្ខ្មីប្រចាំប៉ជាមួយផងជាអាចិណ្ណ ។

ក្នុងយុគបុរាណពោលថា ជាទេវតាជាន់រង វេ-លាក្រោយទើបបានជាព្រះមួយព្រះអង្គ ក្នុងចំនួន ៣ អង្គនោះ តែមុននឹងរួបសាមគ្គីគ្នាសិប់ តោងកើតសង្គ្រាមនឹងគ្នាជាញឹកញយ ដោយហេតុកាន់លទ្ធិផ្សេងគ្នា លុះរួមគ្នាហើយ គេញែកសំដែងព្រះគុណនៃព្រះទាំង ៣ នោះថា: ព្រះព្រហ្មជាអ្នកសាងលោក, ព្រះឥសូរជាអ្នកសាងលោកផង ជាអ្នកលាងលោកផង ព្រះវិស្ណុ ជាអ្នកស្រោចស្រង់លោក ក្នុងវេលាដែលដល់នូវសេចក្តីបះបោរចលាចល ឲ្យបាននូវសេចក្តីសុខសាន្តត្រាណផង ទើបមាននាមថា "ហរិ" ប្រែថា "អ្នកជួយ, អ្នកស្រោចស្រង់, អ្នកសាងលោកផង", មាននាមថា "នា-រាយណ៍" ប្រែថា "ជាដែនកើតនៃនរៈផង" ។

១ ដែលថាព្រះនារាយណ៍ ជាអ្នកសាងលោកផងនោះ ប្រហែលជាសំដៅយកត្រង់ ដែលលោកបែងភាគមកម្តង ១ ដូចមានប្រាកដក្នុងគម្ពីរ វិស្ណុបុរាណម

សំដែងអំពីអវតារ ១០ គ្រាក្នុងសត្យយុគៈ គឺយុគៈជាដំបូង ដូចយ៉ាងអវតារជាព្រះរាម (ក្នុងរឿងរាមកេរ្តិ៍) និងអវតារជាព្រះក្រឹស្ណ (ក្នុងរឿងហរិវង្ស) ជាដើម ។

ឯអវតារទាំង ១០ នេះ ខ្ញុំមិនបានអធិប្បាយក្នុងទីនេះទេ ព្រោះវែងពេកនាំឲ្យយឺតដំណើរទៅមុខ ។ ហេតុនោះខ្ញុំ (បូព្រឺ) គ្រាន់តែទាញគោល ៗ មកដាក់ចុះដូចតទៅនេះគឺ :

១ –. មត្ស្យាវតារ
២ –. កុមាវតារ
៣ –. វរាហាវតារ
៤ –. នរសិង្ហាវតារ
៥ –. វាមាវតារ
៦ –. បរសុរាមាវតារ
៧ –. រាមាវតារ
៨ –. ក្ឫស្ណាវតារ
៩ –. ពុទ្ធាវតារ
១០ –. កល្កិយាវតារ

(អវតារ ៩ ខាងដើមកន្លងទៅហើយ, ឯអវតារទី ១០ នឹងមានក្នុងអនាគតកាលក្នុងកលិយុគៈនេះ) ។

ព្រះនារាយណ៍ទ្រង់បែងភាគទាំង ១០ គ្រានេះ សុទ្ធតែមកជួយលោកដែលដល់នូវសេចក្តីទុក្ខ ឬចលាចលម្តង ៗ ឲ្យត្រឡប់សុខសាន្តត្រាណទៅវិញ ។ ក្រៅអំពីអវតារ ១០ គ្រានេះ ទ្រង់ធ្លាប់ទៅជួយក្រោមក ត្រូវដែរ ឲ្យបរាជ័យទៅជាច្រើនដង ដូចយ៉ាងទ្រង់ជួយព្រះឥន្ទ្រ ក្រោមបំគ្រាសូរជាដើម ទាល់តែបានសិទ្ធស្ថាលនឹងព្រះឥន្ទ្រ រហូតដល់ទៅបាននាមថា ឥន្ទ្រានុជ មានព្រះកិត្តិយស ជាឯកអគ្គមហាយោធិន ទ្រង់នូវតេជៈដ៏មហិមាទទួលសំពៅឆ្ពាំមកក្រោមពួកអរិរាជបច្ចាមិត្រឲ្យខ្ចប់ខ្ចាយទៅគ្រប់ទិស ហេតុដូច្នោះ ព្រះមហាក្សត្រ អំពីបុរាណ ទើបសព្វព្រះទ័យយកនាម វិស្ណុ, ហរិ, នារាយណ៍ អម្បាលនេះជាដើម មកជាព្រះបរមនាមាភិសេក របស់ព្រះអង្គនឹងតាំងជាឈ្មោះមន្ត្រីខាងក្រសួងការពារប្រទេស ។ មួយទៀតក្នុងគ្រឿងយុទ្ធភ័ណ្ឌ មានរបស់មួយយ៉ាងហៅ "គ្រុឌពាហៈ" គឺធ្វើជារូបគ្រុឌ មានដងវែងសម្រាប់កាន់ ជារបស់សម្រាប់នាំមុខ ប្រហែលគ្នានឹងទង់ជ័យ ដែលយកធ្វើដូច្នេះដោយសំគាល់ថា គ្រុឌជាទីនាំងរបស់ព្រះនារាយណ៍ ។

រូបគ្រុឌពាហៈនេះ បើអ្នកណាប្រាថ្នាចង់ឃើញ ក៏ចូលទៅមើលរូបភាពចម្លាក់ អំពីក្បួនទ័ពរបស់ព្រះបាទសូរ្យវរ្ម័នទី ២ ដែលឆ្លាក់នៅនគរវត្ត នាព្រះរបៀងថ្នាក់ទី ១ ពិតានខាងត្បូង ភាគខាងលិច ឬនឹងទៅមើលប្រាសាទបាយ័នក្រុងមហានគរ ក៏បាន ។

## ទេវីរបស់ព្រះទាំង៣

ព្រះសរស្វតី ជាទេវីរបស់ព្រះព្រហ្ម ជាទេវីប្រចាំវាចានឹងតម្រិះវិជ្ជា គឺជាអ្នកមានវាចាជាសិរី និងទ្រង់នូវសិល្បសាស្ត្រទាំងពួង យ៉ាងព្រះព្រហស្បតីដ៏ជាគ្រូ

តទៅទំព័រទី ២៤

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ

(ព្រមទាំងព្រះធម៌ និងព្រះសង្ឃ ដោយសេចក្ដីគោរព) ។

បន្ទាប់អំពីនេះ, អាត្មាភាព សូមលើកយកពុទ្ធភាសិតក្នុងគម្ពីរខុទ្ទកនិកាយ ជាយាបដកមកសំដែង ទុកជាសវនាការរបស់ពុទ្ធបរិស័ទទាំងឡាយ សមគួរដល់កាលវេលាដូចតទៅនេះ ៖

**កោសជ្ជំ ភយតោ ទិស្វា វីរិយារម្ភញ្ច ខេមតោ អារទ្ធវីរិយា ហោថ ឯសា ពុទ្ធានុសាសនី ។**

សេចក្ដីថា៖ អ្នកទាំងឡាយ ឃើញសេចក្ដីខ្ជិលជាភ័យ ទាំងឃើញការប្រារព្ធសេចក្ដីព្យាយាមថាជាធម៌ក្សេម (ចាកភ័យ) ចូរប្រារព្ធសេចក្ដីព្យាយាមចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

សេចក្ដីក្នុងផ្លូវនៃពុទ្ធភាសិតនេះ សូមស្រង់យកតែពាក្យពីរម៉ាត់គឺ "សេចក្ដីខ្ជិល និងសេចក្ដីព្យាយាម" មកអធិប្បាយដូចតទៅ ៖

ពាក្យថា "សេចក្ដីខ្ជិល" បានដល់ការទម្រន់ ការធុញទ្រាន់ ការមិនត្រេកអរក្នុងករណីយកិច្ចរបស់ខ្លួនៗ ពុទ្ធបណ្ឌិតទាំងឡាយ មិនដែលសរសើរសេចក្ដីខ្ជិលថាជាអំពើល្អ នាំឲ្យសម្រេចប្រយោជន៍ ផ្ដល់សេចក្ដីសុខចំរើនដល់បុគ្គលណាម្នាក់សោះ, មានតែគ្មះតិះដៀលបន្ទោសបង្អាប់ថា សេចក្ដីខ្ជិលជាអំពើលាមកថោកទាប នាំឲ្យវិនាសប្រយោជន៍សព្វយ៉ាងដល់បុគ្គលខ្ជិលច្រអូសៗ មិនបាច់និយាយត្រឹមតែរូបបុគ្គលម្នាក់ៗទេ, បើនៅក្នុងតំបន់ណា តាំងពីប្រទេសធំៗ ក្នុងសាកលលោករហូតដល់ប្រទេសតូចតាច ដល់សង្គមក្រុមគ្រួសារជាទីបំផុត ឲ្យតែសម្បូរដោយមនុស្សខ្ជិលហើយ ក្នុងប្រទេសនោះ សង្គមក្រុមគ្រួសារនោះ គង់នឹងធ្លាក់ខ្លួនដុនដាបទៅជាទាសភាព នៃជនដទៃទាំងស្រុងមិនខានហើយ មិនអាចរកសេចក្ដីសុខចំរើន ទ្រព្យសម្បត្តិយសសក្តិមកប្រគល់ឲ្យគ្នានឹងគ្នាបានឡើយ ពីព្រោះមនុស្សខ្ជិលរមែងជួបប្រទះសេចក្ដីក្រីក្រខាងទ្រព្យសម្បត្តិ ចំណេះវិជ្ជា, បើក្រហើយមុខតែលំបាក ដោយសារគ្មានអ្វីចិញ្ចឹមជីវិត ជាហេតុនាំឲ្យប្រព្រឹត្តអំពើអាក្រក់ច្រើនយ៉ាង មានការសម្លាប់មនុស្សសត្វដទៃ លួចប្លន់យកទ្រព្យសម្បត្តិគេជាដើម មកចិញ្ចឹមជីវិតរបស់ខ្លួន ឥតមានសេចក្ដីអាណិតអាសូរករុណាដល់គេបន្តិចឡើយ ។ ការចិញ្ចឹមជីវិតដោយកោសជ្ជភាពបែបនេះ មិនដែលបានសុខកាយសប្បាយចិត្តទេ រមែងទទួលទុក្ខទោសទណ្ឌកម្មក្នុងលោកនេះនិងលោកខាងមុខ, ក្នុងលោកនេះ មានគេចាប់ចងវាយដំប្រំធាក់ ដាក់គុកច្រវាក់ជាដើម, តាមច្បាប់ព្រះពុទ្ធសាសនាថា បុគ្គលបែបនេះ លុះស្លាប់ទៅ រងទុក្ខក្នុងនរក ប្រេត អសុរកាយ តិរច្ឆានទៀតៗ សូមលើកយកសុភាសិតជាពាក្យកាព្យ របស់អ្នកប្រាជ្ញសម័យបច្ចុប្បន្ន បាននិពន្ធទុកថា៖

## ខ្ជិលជាមេបាបធម៌គ្រប់យ៉ាង

ខ្ជិលបង្ហិនលោក ខ្ជិលបានទុក្ខសោក
ខ្ជិលអាប់ប្រាជ្ញា ខ្ជិលធ្លាក់នរក
ខ្ជិលឥតវិជ្ជា ខ្ជិលថោកសាសនា
ខ្ជិលជាតិលិចលង់ ។

សុភាសិតនេះ អាចគ្រោលបំភ្លឺឲ្យឃើញទោសនៃសេចក្តីខ្ជិលថា ចំហាយទោសនៃសេចក្តីខ្ជិល មិនមែនផ្តល់ឲ្យត្រឹមតែលំបាកខ្លួនម្តងម្កាលប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យជាតិសាសនា លិចលង់វិនាសសាបសូន្យទៅ ដោយសារតែសេចក្តីខ្ជិលនេះឯង ។

កាលបើដឹងថា សេចក្តីខ្ជិលជាអំពើថោកទាបទីបំផុតដូច្នេះ, គួរតែពួកពុទ្ធបរិស័ទទាំងឡាយ ទាំងគ្រហស្ថ ទាំងបព្វជិត ដែលជាអ្នកប្រាថ្នាសេចក្តីសុខចំរើនដល់ខ្លួន ដល់សាសនា ខំលះបង់សេចក្តីខ្ជិលនេះចោលចេញ, ពីព្រោះសេចក្តីខ្ជិលនេះប្រៀបដូចជាផ្សែងពុលដែលហុយចេញមកពីភ្នក់គំនិតអវិជ្ជា ។ កាលបើបណ្តោយផ្សែងនេះហុយមកគ្របសន្តានចិត្តរបស់យើង នោះយើងមុខតែងងឹតងងល់ច្រលច្របល់ មិនអាចរកសេចក្តីចំរើនឃើញបានឡើយ ។ ចំណែកខាងគ្រហស្ថ ដែលមានភារៈខាងឃរាសកម្ម ត្រូវតែខំបំពេញមុខរបររកទទួលទានរបស់ខ្លួនដោយសម្មាអាជីវឲ្យពេញទំហឹង ទើបបានសម្រេចប្រយោជន៍សមតាមសេចក្តីប្រាថ្នា ។ ទាំងសីល ទាន ភាវនាក៏គួរបំពេញ តាមកម្លាំងសទ្ធានិងទ្រព្យសម្បត្តិរបស់ខ្លួន ទុកជាស្បៀងយ៉ាងវិសេសវិសាលរបស់យើង, ក្នុងកាលដែលយើងលះបង់ខន្ធទៅកាន់លោកខាងនាយ ដោយគ្មានញាតិមិត្តណានាំយើងទៅបានក្រៅពីស្បៀងគឺ សីល ទាន ភាវនា ដែលយើងបានកសាងសន្សំទុកនោះឡើយ មានតែបុញ្ញកម្មទើបជូនដំណើរយើងឲ្យដល់សុគតិភព ។ ចំណែកអ្នកបួស ដែលមានឈ្មោះថាជាអ្នកកាន់សាសនាផ្ទាល់ជាងគ្រហស្ថ ត្រូវតែបំពេញករណីយកិច្ចរបស់ខ្លួន ក្នុងបព្វជិតភូមិឲ្យបានបរិបូណ៌តាមធុរៈទាំងពីរគឺ គន្ថធុរៈ និងវិបស្សនាធុរៈ ជៀសឲ្យស្រឡះអំពើណាដែលជាទំនាស់ដល់ ធម៌–វិន័យ ក្នុងសាសនា ។ កាលបើយើងជាអ្នកបួសខ្ជិលរៀនខ្ជិលប្រតិបត្តិ ម្តេចឡើយនឹងបានឈ្មោះថាជាអ្នកស្វែងរកសេចក្តីចំរើនដល់ព្រះពុទ្ធសាសនា, ដូចយ៉ាងការសិក្សា ធម៌វិន័យច្បាប់ផ្លូវលោកផ្លូវធម៌ ដែលជាស្នេហ៍មុខមួយ នាំឲ្យពុទ្ធបរិស័ទជ្រះថ្លា គោរព ប៉ុន្តែបើយើងខ្ជិលយកចិត្តទុកដាក់រៀនសូត្រ ធ្វើម្តេចនឹងបានចេះដឹង ។ ការមិនចេះមិនដឹងនេះ ជាសត្រូវដល់ជាតិ សាសនា ដោយសម្មាត់ដែលគួរខ្មាសគួរស្អប់ ។ ធម្មតាមនុស្សល្ងង់ គ្មាននរណាចង់ចូលទៅស្និទ្ធសមាគម យកធ្វើជាមិត្តភក្តិផងសោះ ពីព្រោះពាក្យសំដីរបស់មនុស្សល្ងង់ មិនអាចធ្វើឲ្យអ្នកដែលចូលគប់ប្រសប់ បានសម្រេចគុណវិសេសអ្វីឡើយ, មានតែដឹកនាំទៅរកសេចក្តីវិនាសតែម្យ៉ាង, សមដូចសុភាសិតពេចន៍មួយឃ្លារបស់សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈ—មហានិកាយថា.

" សេពគប់ពាលៗនាំទៅរកខុស

សេពគប់ប្រាជ្ញប្រុសប្រាជ្ញនាំទៅរកត្រូវ" ។

ពិតណាស់, មនុស្សពាល ធ្វើម្ដេចនឹងរកផ្លូវត្រូវឃើញ ពីព្រោះខ្លួនជាមនុស្សល្ងង់ មិនដឹងថានេះជាធម៌ នេះជាវិន័យ ចេះតែប្រតិបត្តិផ្ដេសផ្ដាសឲ្យល្អៀងឃ្លៀងឃ្លាតតាមគំនិតយល់ឃើញរបស់ខ្លួន ថែមទាំងការប្រៀនប្រដៅគេទៀត ក៏ទៅតាមតែភាពនៃខ្លួនជាមនុស្សល្ងង់ដូច្នោះ ។

ហេតុដូច្នេះ ពុទ្ធបរិស័ទទាំងឡាយ បើមានសេចក្ដីប្រាថ្នាការចំរើន ត្រូវតែប្រញាប់កំចាត់កំចាយសេចក្ដីខ្ជិលនេះឲ្យជ្រះស្រឡះចេញ ។ ពីព្រោះសេចក្ដីខ្ជិលនេះជាមេក្រុមមួយ យ៉ាងសម្បើមនាំឲ្យបិទសិរីធម៌របស់យើងគ្រប់ផ្លូវ, ហើយត្រូវតាំងសេចក្ដីខ្មីឃ្មាតស្រវាស្រទេញឲ្យមានក្នុងខន្ធសន្ដាន ជំនួសសេចក្ដីខ្ជិលវិញ ដែលលោកហៅថា " សេចក្ដីព្យាយាម " នោះទើបរកសេចក្ដីចំរើនឃើញ ។

ពាក្យថា " ព្យាយាម " នេះវាគូបដិបក្ខនឹងពាក្យថា " ខ្ជិល " ។ អ្នកប្រាជ្ញជំនាន់ណាក៏ដោយ តែងតែសរសើរសេចក្ដីព្យាយាមនេះ ថាជាកល្យាណធម៌មួយយ៉ាងវិសេស អាចធ្វើឲ្យមនុស្សក្លាយខ្លួនពីហីនភាពទៅកាន់ឧត្ដមភាព ពីមូឡ្ហភាព ទៅបណ្ឌិតភាព ពីទាសភាព ទៅកាន់កុដិស្សរភាពបាន ។ សេចក្ដីព្យាយាមនេះ បើចែកតាមប្រភេទមាន៤យ៉ាងគឺ៖

១–សំវរប្បធាន ព្យាយាមរាំងប្រយ័ត្នមិនឲ្យទោសកើតឡើង

២–បហានប្បធាន ព្យាយាមលះទោសដែលកើតឡើងហើយ

៣–ភាវនាប្បធាន ព្យាយាមញ៉ាំងកុសលឲ្យកើតក្នុងសន្ដាន

៤–អនុរក្ខនាប្បធាន ព្យាយាមរក្សាកុសលដែលកើតឡើងហើយ មិនឲ្យសាបសូន្យទៅវិញ ។

ព្យាយាមទាំង៤យ៉ាងនេះជាធម៌ប្រពៃ ដែលគួរតែប្រកបឲ្យមានក្នុងសន្ដាន ។

## អធិប្បាយថា

ក) សំវរប្បធាន ការសង្រួមរាំងប្រយ័ត្នមិនឲ្យបាបកើតឡើងបានដល់ការសង្រួម៥យ៉ាងគឺ បាដិមោក្ខសំវរៈ សង្រួមរក្សាសិក្ខាបទ ដែលមានក្នុងបាដិមោក្ខ មិនឲ្យធ្លុះធ្លាយ១, សតិសំវរៈ សង្រួមប្រយ័ត្នស្មារតីក្នុងឥន្ទ្រិយទាំងប្រាំមួយ មានចក្ខុន្ទ្រិយជាដើម មានមនិន្ទ្រិយជាទីបំផុត កុំឲ្យបាបកើតតាមផ្លូវឥន្ទ្រិយទាំងនោះបាន១, ញាណសំវរៈ សង្រួមប្រយ័ត្នដោយប្រាជ្ញា សម្រាប់បិទនូវខ្សែរបស់តណ្ហា ទិដ្ឋិ ទុច្ចរិត នឹងកិលេសដ៏សេស ឬប្រាជ្ញាដែលកំណត់ពិចារណានូវបច្ច័យ៤ ហើយទើបសេព១, ខន្តិសំវរៈ សង្រួមដោយការអត់ទ្រាំនូវកំដៅនៃត្រជាក់ជាដើម បានដល់អទោសៈ សេចក្ដីមិនប្រទូស្ដ១, វិរិយសំវរៈ សង្រួមប្រយ័ត្នដោយព្យាយាម ដើម្បី

បន្ទោបង់នូវកាមវិតក្កជាដើម ឬព្យាយាមចិញ្ចឹមជីវិតដោយប្រព្រឹត្តតាមផ្លូវអាជីវបារិសុទ្ធិសីល ១ ។

ខ) បហានប្បធាន ព្យាយាមលះបាបដែលកើតឡើងហើយ, អំពើបាបដែលកើតតាម កាយទ្វារ វចីទ្វារ មនោទ្វារ សូម្បីមានប្រមាណបន្តិចបន្តួចក៏ដោយ ក៏បុគ្គលមិនត្រូវមើលងាយថា “បាបមានប្រមាណតិចនឹងមិនឲ្យផល” ដូច្នេះឡើយ, ពីព្រោះអំពើបាប ប្រៀបដូចជាភ្លើងយ៉ាងតូចប៉ុនក្បាលគ្រាប់ឈើគូសមួយក៏ដោយ ឲ្យតែគេបោះភ្លើងនោះទៅបង្កាត់ នឹងក្លាយទៅជាភ្លើងសន្ធោសន្ធៅ អាចឆេះកំទេចផ្ទះសម្បែង ព្រៃភ្នំពេញក៏សឹងបាន ។ បាបដែលបុគ្គលមិនព្យាយាមលះបង់តាំងតែពីបន្តិចបន្តួចទៅ ក៏ក្លាយទៅជាបាបធំធំ អាចនឹងធ្វើឲ្យវិនាសប្រយោជន៍សព្វយ៉ាងបានដោយងាយដែរ ។

គ) ភាវនាប្បធាន ព្យាយាមញុំាងកុសលឲ្យកើតឡើងក្នុងសន្តាន, កុសលជាអំពើល្អ ឲ្យផលជាសុខក្នុងលោកនេះនិងលោកខាងមុខ, បើមិនទាន់មានក្នុងសន្តាន បុគ្គលគួរតែខំសន្សំ ខំបំពេញឲ្យមានឡើង ។ ឯការបំពេញកុសលមានច្រើនយ៉ាងគឺ ការមិនប្រព្រឹត្តធ្វើអំពើបាប ដោយកាយ វាចា ចិត្ត ធ្វើបុណ្យឲ្យទាន រក្សាសីល មានសីល៥ជាដើម តាមឋានៈដែលខ្លួនគួរបាន ។

ឃ) អនុរក្ខនាប្បធាន ព្យាយាមរក្សាទុកនូវអំពើល្អ ដែលខ្លួនបានអប់រំសន្សំហើយនោះ មិនឲ្យវិនាសទៅ ដោយមិនបណ្ដោយឲ្យបាបធម៌ ដែលជាកំពូលនៃអកុសលកម្មគ្រប់យ៉ាង ចូលមកលុកលុយ ។

ព្យាយាម៤យ៉ាងដូចបានអធិប្បាយមកនេះ, បើមានក្នុងបុគ្គលណា ទោះគ្រហស្ថឬបព្វជិត, បុគ្គលនោះឯងត្រូវនឹកសង្ឃឹមញញឹមទុកក្នុងចិត្តថា មុខតែបានគង់ផុតនូវទុក្ខភ័យទាំងពួង ហើយបានទទួលនូវសេចក្ដីសុខក្សេមក្សាន្ត ក្នុងលោកនេះនិងលោកខាងមុខដោយជាក់ច្បាស់, ទាំងជីវិតរបស់បុគ្គលនោះសោត ជាជីវិតមានខ្លឹមសារ, សមដូចពុទ្ធភាសិតក្នុងគម្ពីរ ខុទ្ទកនិកាយ ធម្មបទថា:

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។

អ្នកណាមួយមានព្យាយាមថោកទាប គប្បីរស់នៅអស់រយឆ្នាំ ក៏ពុំប្រសើរស្មើនឹងការរស់នៅមួយថ្ងៃ នៃអ្នកដែលប្រារព្ធនូវព្យាយាមមាំ ។

សេចក្ដីនៃពុទ្ធភាសិតនេះ បញ្ជាក់ឲ្យឃើញខុសគ្នាស្រឡះឥតមានការប្រឡំ, បុគ្គលខ្ជិលព្រះអង្គទ្រង់តិះដៀលជាអនេកបរិយាយ, ចំណែកបុគ្គលមានព្យាយាមមាំ ទ្រង់សរសើរជាតិយ្យោភាព ។

សាធុសប្បុរស ជាពុទ្ធបរិស័ទទាំងឡាយ ! កាលបើអស់លោកអ្នកឃើញទោសនៃសេចក្ដីខ្ជិលច្រអូស នឹងគុណនៃសេចក្ដីព្យាយាមហើយ ត្រូវខំលះសេចក្ដីខ្ជិលចោលចេញ ត្រូវបំពេញសេចក្ដីព្យាយាមឲ្យមាំមួនក្នុង

ករណីយកិច្ចរបស់ខ្លួន កុំមានសេចក្ដីធ្វេស ប្រហែសឡើយ ។ ដ្បិតសាសនារបស់ព្រះជិនស្រីបិតនៅដោយរុងរឿង ឬវិនាសសាបសូន្យ ក៏មកតែពីពុទ្ធបរិស័ទ ប្រតិបត្តិត្រឹមត្រូវនិងមិនត្រឹមត្រូវ , បើពុទ្ធបរិស័ទទាំងគ្រហស្ថទាំងបព្វជិត មានព្យាយាមរៀនសូត្រធម៌អាថ៌ សាស្ត្រាបាលី វិន័យ សិក្ខា ច្បាប់ព្រះពុទ្ធសាសនា ឲ្យចេះដឹងដូចៗគ្នា ទៅនោះ សាសនារបស់ព្រះជិនស្រីសមនឹងបាន ប្រតិស្ឋានទៅដរាបដល់លើសប្រាំពាន់ព្រះវស្សាទៀតមិនខាន យើងទៀតក៏សមនឹងទទួលបាននូវជាពុទ្ធបរិស័ទអ្នកប្រាជ្ញ សេចក្ដីបំរើនត្រូវតាមគោលបំណង ។

ធម្មទេសនាវិសាខេ ក្នុងទីបំផុតនៃធម្មទេសនានេះ សូមថ្វាយព្រះរាជកុសលចំពោះព្រះមហាក្សត្រនិងព្រះមហាក្សត្រិយានី, សូមព្រះអង្គគង់នៅក្នុងសិរី-រាជសម្បត្តិប្រកបដោយជោគជ័យសិរីមង្គលគ្រប់ប្រការ ព្រមទាំងខេមរជន ក្នុងក្របខណ្ឌនៃព្រះរាជអាណាចក្រកម្ពុជាទាំងមូល ក៏សូមឲ្យតែជួបប្រទះតែនឹងសេចក្ដីសុខចំរើនគ្រប់ប្រការកុំបីឃ្លាត !

សូមសន្មតថាចប់ធម្មទេសនានេះដោយសង្ខេបឯរំ រំឭឲ្យធម្មទេសនាព្រះមហាព្រហ្ម-អ៊ិន ហៅ កើតសាវ៉ន

★ ចប់ ★

★

## ប្រវត្តិ

## ពាហិរសាសនា សង្ខេប (ត)

នៃទេវតាទាំងឡាយ (តែខានកំណើតមកដូចម្ដេច ជាធីតារបស់អ្នកណាមិនប្រាកដ ខ្ញុំពុំរកមិនប្រទះ សូមស្ទះទុកតែប៉ុណ្ណោះ) ។

ព្រះឧមាជាទេវីរបស់ព្រះសិវៈ មាននាមឯទៀតដល់ទៅ ១០០០ យ៉ាង មាននាមថា: ឧមា , គគរី, ភវានី , គិរិជា , បាតី , ហៃមវតី , ទុគ៌ា , កាឡីជាដើម ។ នាមអម្បាលនេះ ជាគ្រឿងសរជាតិត្រកូលខ្លះ ជាគ្រឿងប្រកាសគុណសម្បត្តិខ្លះ ដូចយ៉ាងនាមថា ហៃមវតី បរិតី គិរិជា ជាគ្រឿងសរត្រកូល ព្រោះនាងជាធីតាភ្នំហេមវ័ត (គឺហេមពាន្ត) និងនាងមេនកា ។ នាមថា គគរី ព្រោះនាងជាអ្នកមានជោគលាភ, នាមថា ភវានី ព្រោះនាងជាមាតានៃទេពតានិងមនុស្សទាំងឡាយ ។ ទុគ៌ានិងកាឡីជានាមខាងអាក្រក់ ដែលបណ្ដាលឲ្យវិនាសហិនហោចទៅ សំដែងមកប៉ុណ្ណោះជាតួយ៉ាង ។ លក្ខណៈរបស់នាងនេះ ពីដើមមានសម្បុរកាយខ្មៅ វេលាក្រោយបានបំពេញតបៈ ភក្ដីដល់ព្រះជាម្ចាស់ ទើបមានសម្បុរកាយលឿង, មានខ្លាជាពាហនៈ ។ បានជាព្រះជាយាព្រះឥសូរគោល កាមទេពបាញ់ព្រះឥសូរ ដោយធ្នូផ្កាឲ្យកើតរាគៈឡើង , ជាអ្នកទ្រង់នូវអានុភាព អាចនឹងប្រទានពរ ឬដាក់បណ្ដាសារដល់អ្នកឯណានីមួយក៏បាន ព្រោះហ្ឫទ័យច្រើនធុរធៅក្រោធឆាប់ៗ សព្វព្រះហ្ឫទ័យតែដោយបូជា

ដោយឈាមមនុស្សឬសត្វ, បើអ្នកណាចង់បានពរអំពីនាង គប្បីបំពេញតបៈឲ្យមាំមួន ហើយមនុស្ស ឬសត្វ សម្លាប់នៅទេវាល័យ យកឈាមមកថ្វាយ នឹងឆាប់ប្រទានពរ ។

ព្រះលក្ស្មី ជាទេវីរបស់ព្រះវិស្ណុ មានកំណើតអំពីសមុទ្រទឹកដោះ គឺកើតព្រមគ្នានឹងថ្នាំអម្រឹតដែលទេវតា នឹងអសុរកូរទឹកដោះ (ក្នុងរឿងកុមារិការ រឿងនេះមានឆ្លាក់នូវបាឋនគរវត្ត នារបៀងទី ១ ពីខាងខាងកើត ភាគខាងត្បូង) ជាទេវីដ៏ល្អឯកខាងលំអរឆោម នឹងជោគលាភ ។ ទ្រង់អ្វីជាពាហនៈ ស្រាវជ្រាវរកមិនឃើញ ។ ពួកអ្នកកាន់សាសនានេះ មិនចំពោះរាប់អានតែព្រះ ៣ អង្គប៉ុណ្ណោះទេ រមែងគោរពរាប់អានព្រះជាយាទាំង ៣ អង្គនេះដែរ ។ (នៅមានត)

★ ★

# រឿងធនញ្ជ័យអ្នកប្រាជ្ញ

## គម្ពីរលោកនយ

ដំណើរដើមសេចក្តីថា សម័យមួយព្រះសម្ពុទ្ធជាបរមគ្រូទ្រង់គង់នៅក្នុងវត្តជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ។ គ្រានោះ ព្រះអានន្ទត្ថេរដ៏មានអាយុ ពោលសរសើរបុណ្យសម្ភារៈព្រះបារមីតេជា—នុភាព ព្រះអង្គជាកាចធ្វើមនុស្សដែលមានពុតកំណាចកាចអាក្រក់ ឲ្យទៅជាមនុស្សល្អត្រឹមត្រូវវិញបាន នេះចំជាអស្ចារ្យក្រៃពេកហោង ។

ព្រះមានព្រះភាគទ្រង់ត្រាស់តបនឹងពាក្យព្រះអានន្ទត្ថេរថា ម្នាលអានន្ទឥឡូវនេះតថាគតបានត្រាស់ជាព្រះពុទ្ធ ហើយមិនអស្ចារ្យប៉ុន្មានឡើយ បើកាលដែលតថាគតនៅជាធនញ្ជ័យបណ្ឌិតមិនទាន់បានត្រាស់នោះទើបបានអស្ចារ្យមែនទ្រង់បន្ទូលព្រះឱស្ឋតែប៉ុណ្ណោះក៏បញ្ចប់ស្ងៀមទៅ ។

ព្រះអានន្ទត្ថេរក៏សូមអារាធនាឲ្យព្រះអង្គទ្រង់ព្រះមេត្តាប្រោសនាំនិទាននោះមកជាសណ្តាប់តទៅ ។ គ្រានោះ ព្រះមានបុណ្យទ្រង់លើកព្រះហស្តចង្អុលអង្គុលិមាលត្ថេរថា ម្នាលភិក្ខុទាំងឡាយ អង្គុលិមាលភិក្ខុនេះកាលពីដើមកើតជាយក្ខកាចអាក្រក់ អាស្រ័យនៅដើមជ្រៃមួយ ក្នុងព្រៃស្ងាត់តែងចាប់មនុស្សស៊ីជាអាហារ ដោយបានអំណាចពីស្តេចវេស្សវណប្រគល់ឲ្យចាប់តែ—នរណាមិនបេះមលរធម៌បរិភោគជាចំណីទាំងអស់ ឲ្យតែចូលមកជ្រកក្រោមម្លប់ជ្រៃនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលនោះមានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាម ធន—ញ្ជ័យកោរព្យរាជ សោយរាជ្យក្នុងនគរឥន្ទបត្តបុរី, អគ្គ-មហេសីព្រះនាមអតុលាទេវី ជាចំបងលើស្ត្រីមួយហ្មឺន ៦ ពាន់, មានទុដុកព្រាហ្មណ៍បុរោហិតជាអ្នកទូន្មាននូវអត្ថនឹងធម៌របស់ព្រះរាជា ព្រះអង្គប្រកបដោយពួកពលសកលយោធាចតុរង្គសេនា ១ អក្ខោភិនី ។ មានស្រុកធំ ៤ គឺ បាចីនគ្រាម ១ ទក្សិណគ្រាម ១, បច្ចិមគ្រាម១ ឧត្តរគ្រាម ១, ទៀបទ្វារទាំង ៤ សម្រាប់នាំឡើងមានសេដ្ឋីធំៗ ៤ នាក់គឺ ធនញ្ជ័យសេដ្ឋីនៅទៀបទ្វារខាង

រកឹត ១, វិសាលសេដ្ឋីនៅទៀបទ្វារខាងត្បូង ១ សុចិសេដ្ឋីនៅទៀបទ្វារខាងលិច ១, សុទស្សនសេដ្ឋីនៅទៀបទ្វារខាងជើង ១; សេដ្ឋីធំ ៗ ទាំង ៤ នាក់នេះសុទ្ធតែមានអនុសេដ្ឋី ៥០០ ៗ ជាបរិវារដូចគ្នា ៗ លំដាប់នោះ ព្រះពោធិសត្វនៅជាទេវបុត្តបានច្យុតចាក–តាវតឹង្សទេវលោកមកចាប់បដិសន្ធិក្នុងផ្ទៃនៃនាងសុខុមាលីជាភរិយានៃធនញ្ជ័យសេដ្ឋី ជាស្ត្រីប្រកបដោយ – លក្ខណា មានទេវបុត្ត៥០០ច្យុតចុះមកចាប់បដិសន្ធិក្នុងផ្ទៃភរិយានៃអនុសេដ្ឋីទាំង ៥០០ ជាបរិវារដំណាលគ្នាក្នុងថ្ងៃមួយផង ៗ សម័យថ្ងៃមួយ ព្រះបាទធនញ្ជ័យកោរព្យ-រាជទ្រង់សុបិននិមិត្តឃើញថា ហាក់ដូចជាព្រះអង្គមានរាជបរិស័ទ្យជាច្រើនកុំពុងគាល់ចោមរោមជាបរិវារ ព្រះអង្គគង់នៅពន្លកលើសេយ្យាសនដ៏ប្រសើរស្រាប់តែឃើញគំនរភ្លើងធំប៉ុនដើមត្នោត តាំងឆេះឡើងចំមុខព្រះសាទ មានផ្កាក្រមុំ ១ ធំប៉ុនកង់រាជរថ ផុះឡើងចំពាក់កណ្ដាលគំនរភ្លើងធំនោះ អណ្ដាតភ្លើងរលត់ទៅ ផ្កាក្រមុំនោះមានពន្លឺភ្លឺរន្ទាលព្រោងព្រាលផ្សាយទៅពេញជម្ពូទ្វីបទាំងមូលជាអស្ចារ្យ លុះព្រះអង្គទ្រង់តើនចាកក្រឡាបន្ទំហើយត្រាស់ឲ្យហៅបុរោហិតមកទាយនិមិត្តភ្លាម ៗ ព្រាហ្មណ៍បុរោហិតក្រាបទូលតាមពិតថា ទេវ បពិត្រព្រះសម្មតិទេព ឯគំនរភ្លើងនោះគឺខ្ញុំទូលព្រះបង្គំជាអ្នកប្រាជ្ញសំពប់ព្រះអង្គ ឯផ្កាក្រមុំនោះគឺមានអ្នកប្រាជ្ញកើតឡើងទៀតហើយ អ្នកប្រាជ្ញនោះអាចធ្វើព្រះអង្គឲ្យរួចអំពីភ័យអន្តរាយបានគ្រប់ចំពូក ឯពន្លឺភ្លឺរន្ទាលព្រោងព្រាតគឺបញ្ញាអ្នកប្រាជ្ញនោះនឹងភ្លឺរុងរឿងផ្សាយទៅក្នុងជម្ពូ-ទ្វីបទាំងអស់ បពិត្រព្រះមហារាជអ្នកប្រាជ្ញនោះបានចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាគំរប់ ១០ មាសា នឹងប្រសូត្រក្នុងថ្ងៃនេះឯងហើយ សូមទ្រង់ជ្រាប ៗ ព្រះរាជាទ្រង់សណ្ដាប់ហោរទាយសុបិននិមិត្តដូច្នោះហើយទ្រង់មាន–ព្រះរាជហឫទ័យបីតិសោមនស្សក្រៃពេក ក៏ទ្រង់ប្រទានរង្វាន់ជាច្រើន ៗ វេលានោះ នាងសុខុមាលីជាភរិយានៃធនញ្ជ័យសេដ្ឋីប្រសូត្រកូនប្រុសសម័យថ្ងៃនោះ – ព្រមទាំងភរិយារបស់អនុសេដ្ឋីទាំង ៥០០ នាក់ក៏ប្រសូត្របុត្រក្នុងថ្ងៃនោះដំណាលគ្នា ៗ ស្រាប់តែស្គរនន្ទភេរីជ័យសំពប់ពង្យក៏លាន់ឮខ្ទរខ្ទារឡើងឯង សំឡេងឮផ្សាយទៅក្នុងក្រុងទ្វីបទាំងមូលជាអស្ចារ្យ ៗ ព្រះញាតិវង្ស–នុវង្សឲ្យនាមពោធិសត្វថា ធនញ្ជ័យកុមារ ៗ ព្រះរាជាឮសូរសំឡេងចំឡែកអស្ចារ្យដូច្នោះ ទ្រង់ត្រាស់បង្គាប់ឲ្យហៅបុរោហិតមកសួរទៀត ៗ ព្រាហ្មណ៍បុរោហិតក្រាបទូលថា បពិត្រមហារាជសូមព្រះអង្គកុំព្រួយព្រះ–អង្គអ្វីឡើយ អ្នកប្រាជ្ញកើតក្នុងថ្ងៃនេះហើយបានជាស្គរនន្ទភេរីជ័យលាន់កក្រើកដូច្នេះ សូមទ្រង់ជ្រាប ៗ ព្រះនរបតីទ្រង់ព្រះសណ្ដាប់ហោរទំនាយថ្វាយដូច្នោះ ក៏ចាត់អាមាត្យ ៤ នាក់ឲ្យចេញដើរស៊ើបមើលក្នុងទិសទាំង ៤ តើមានកូននរណាកើតក្នុងថ្ងៃនេះដែរ ? អាមាត្យដែលចេញទៅតាមទ្វារទិសខាងកើតបានស៊ើបដឹងថានាងសុខុមាលីជាភរិយាធនញ្ជ័យសេដ្ឋីទើបនឹងសម្រាលបុត្រប្រុសថ្មី ៗ ព្រមទាំងភរិយាអនុសេដ្ឋីទាំង ៥០០ ក៏សម្រាល

បុត្រព្រមគ្នាដូច្នោះ ទើបនាំពត៌មានទៅក្រាបទូលព្រះរាជា ព្រះរាជាធិបតីកោរព្យរាជទ្រង់សោយបីតិសោមនស្សរីករាយជាពន្លឹក ទ្រង់ព្រះរាជទានប្រាក់ ១ ពាន់កហាបណៈនិងមេនំ ៨ នាក់ព្រមទាំងគ្រឿងប្រដាប់សំរាប់កុមារដល់ធនញ្ជ័យសេដ្ឋី ទ្រង់ប្រទាន ៥០០ ។ កហាបណៈដល់មេនំម្នាក់ ៗ សម្រាប់ចិញ្ចឹមជីវិតកុមារទាំងអស់នោះទៀត ។ ព្រះបាទធនញ្ជ័យកោរព្យរាជទ្រង់បានតាំងព្រះទ័យទុកថា ដល់កុមារទាំងនោះចំរើនធំឡើងនឹងបានសួរបញ្ហាផ្សេង ៗ ល្បងមើលប្រាជ្ញា ។ លុះដល់ធនញ្ជ័យកុមារព្រមទាំងកុមារ ៥០០ នាក់ចំរើនវ័យវឌ្ឍនាការឡើង កុមារធនញ្ជ័យបរមពោធិសត្វប្រកបដោយរូបឆោមលោមពណ៌ល្អស្អាត ឯកុមារទាំង ៥០០ នាក់តែងដើរតាមហោមហែមពោធិសត្វជាធម្មតា ។ អថេកទិវសំ ក្នុងថ្ងៃមួយជាខាងក្រោយមក ព្រះបាទធនញ្ជ័យកោរព្យរាជ ទ្រង់មានព្រះទ័យនឹកក្នុងចង់ចេញប្រពាតព្រៃដើម្បីបរបាញ់ម្រឹគ ក៏លើកពពួកពលចតុរង្គសេនាយាត្រាចេញទៅ ទ្រង់ឲ្យព័ទ្ធព្រៃមួយធំ ដែលមានសត្វម្រឹគនៅនោះ មេម្រឹគឃើញចន្លោះត្រង់មុខស្ដេចវាក៏បោលចំលាយរួចទៅ ស្ដេចឃើញថាកំហុសទៅលើព្រះអង្គដូច្នោះ ក៏ឡើងគង់លើសេះបរបំដាយតាមយ៉ាងលឿន ប៉ុន្តែមិនទាន់សត្វម្រឹគ វារត់ចូលព្រៃបាត់ហើយ ស្ដេចក៏ចេះតែបរសេះទៅឆ្ងាយដាច់ពីពួកពលនិករទាំងអស់តែមួយព្រះអង្គឯងស្មោះ បានដល់ដើមជ្រៃមានមែកសាខាល្អ ក៏តាំងឈប់សម្រាកព្រះកាយពលក្រោមដើមជ្រៃនោះ យក្ខជាម្ចាស់ជ្រៃក៏ស្ទុះមកចាប់ព្រះហស្ដស្ដេចជាប់ ប្រុងនឹងស៊ីជាអាហារ តែគាំងសួរប្រស្នាដូច្នេះថាអ្នកជាអ្វី? អ្នកបានចេះមលគរធម៌ឬទេ? យើងបានអំណាចអំពីព្រះបាទវេស្សវ័ណប្រគល់ដើមជ្រៃមួយឲ្យយើងចាប់មនុស្សណាដែលមកជ្រក – ក្រោមម្លប់បរិភោគជាអាហារ លើកលែងតែនរណាចេះមលគរធម៌ប៉ុណ្ណោះ ចូរប្រាប់យើងឲ្យឆាប់នឹងអាលបរិភោគឥឡូវនេះ ។ ព្រះរាជាទ្រង់ភ័យញ័ររន្ធត់ស្ទើរបាត់ព្រះស្មារតី ទ្រង់ត្រាស់ទៅយក្ខថា ម្នាលយក្ខ យើងនេះជាស្ដេចសោយរាជ្យក្នុងនគរឥន្ទបត្តបុរី យើងមិនចេះមលគរធម៌ទេ ។ តែយើងសូមអង្វរអ្នកដូច្នេះថា សូមអ្នកកុំអាលស៊ីយើង ចាំយើងទៅស្វែងរកអ្នកចេះមលគរធម៌បញ្ជូនមកសំដែងឲ្យអ្នកស្ដាប់បានឬទេ? នន្ទិយក្ខឆ្លើយថា ក្រែងលោស្ដេចយាងទៅមិនមកឲ្យយើងស៊ីវិញ ព្រោះរត់រួចពីការស្លាប់ហើយនរណានឹងហ៊ានវិលមកឲ្យស្លាប់វិញកម្រណាស់ ធ្វើដូចម្ដេចយើងនឹងជឿផង? ព្រះរាជាតបថា ម្នាលយក្ខ យើងដែលសោយរាជ្យជាស្ដេចបានសឹងប្រកបដោយអង្គ ៥ គឺ ១– សុរោ ច ក្លៀវក្លាជានិច្ច ២– មហិទ្ធិកោ ច ជាបុគ្គលមានឥទ្ធានុភាពច្រើន ៣– បរមទ្ទនោ ច អាចញាំញីនូវសត្រូវដទៃបាន ៤– វចនសទ្ទហកោ ច ប្រាកដជាបុគ្គលមានសំដីគប្បីគេជឿ ៥– វចនមធុរោ ច ជាបុគ្គលមានសំដីថ្វីមាត់ពីរោះផ្អែមជាដរាប ។ យើងជាស្ដេចតែងប្រកបដោយអង្គទាំង ៥ នេះជាមិនខានទេ តែងកាន់សច្ច

ទៀងត្រង់ជានិច្ច ដូចស្រីសម្រាលកូនចេញពីផ្ទៃហើយ មិនដែលបញ្ចូលកូនទៅក្នុងផ្ទៃវិញឡើយ យើងជាស្តេចបានពោលពាក្យណាចេញពីមាត់ហើយ ពាក្យនោះមិនត្រឡប់ចូលទៅក្នុងមាត់វិញឡើយ ហេតុនេះយើងនឹងត្រឡប់មកវិញមិនបាន ។ អបរោ លំដាប់នោះយក្សពោលពាក្យប្រដៅថា បើដូច្នោះចូលយានទៅស្ថានរកអ្នកបេះមលតរាធម៌ បើបាន សូមបញ្ជូនតែអ្នកប្រាជ្ញនោះមកឲ្យខ្ញុំបានហើយ មិនចាំបាច់ស្តេចយាងមកឡើយ បើដល់ ៧ ថ្ងៃហើយ រកអ្នកប្រាជ្ញបេះមលតរាធម៌មិនបានទេ នោះត្រូវយាងមក ខ្ញុំនឹងបរិភោគតែព្រះអង្គមួយប៉ុណ្ណោះបើដល់ ៧ ថ្ងៃហើយបាត់មិនឃើញមកទេ ខ្ញុំនឹងលើកពលយក្សទៅចាប់ព្រះរាជ្យព្រមទាំងព្រះអគ្គមហេសី នឹងរាជបរិសទ្យក្នុងនគរស៊ីជាអាហារឲ្យអស់កុំឲ្យសល់ម្នាក់ឡើយ ។ ព្រះរាជាបានទទួលពាក្យប្រដៅនេះហើយទ្រង់បានយាងត្រឡប់ទៅនគរវិញ ។ រួចបានប្រជុំអស់នាហ៉ឺនសព្វមុខមន្ត្រី ឲ្យស៊ើបសួររកអ្នកប្រាជ្ញបេះមលតរាធម៌តាំងពីថ្ងៃទី ១ រហូតដល់ថ្ងៃទី ៦ ហើយក៏គ្មាន ព្រាហ្មណ៍ពិទូបណ្ឌិតអ្នកប្រាជ្ញ ណាបេះមលតរាធម៌ម្នាក់សោះ ទ្រង់ត្រាស់សួរបុរោហិតថា ចុះទៅធនញ្ជ័យកុមារអាចត្រិះរិះរកប្រស្នានេះបានឬទេ ? បុរោហិតក្រាបទូលថា បពិត្រព្រះសម្មតិទេព ធនញ្ជ័យកុមារនៅក្មេងណាស់រកបញ្ហានេះមិនបានយល់ទេ ប្រស្នានេះលុះតែព្រះពុទ្ធអង្គទើបជ្រាប ។ តស្មឹំ ខណេ

ក្នុងខណៈនោះព្រះបាទធនញ្ជ័យកោរព្យរាជទ្រង់ព្រះតម្រិះថា ឱហ្ន៎! ជីវិតអាត្មាអញនឹងសាបសូន្យក្នុងថ្ងៃស្អែកនេះពុំខានទើបព្រះអង្គប្រកាសអស់នាហ៉ឺនសព្វមុខមន្ត្រី មានមហាឧបរាជជាដើមថា ថ្ងៃស្អែកនេះជាថ្ងៃទី៧ ហើយ អញនឹងឲ្យយក្សវាបរិភោគខ្លួនអញម្នាក់ឯង អ្នកពល់គ្នាចូលនៅថែរក្សាក្នុងនគរ ឲ្យបានសុខសប្បាយទាំងអស់គ្នាចុះ លុះទ្រង់ព្រះរាជបណ្ដាំសព្វសេចក្តី សម្ដេចចក្រីឡើងគង់ខ្នងហត្ថីប្រសើរបរចេញទៅ ។ គ្រានោះ ប្រជាជនទាំងឡាយមាននាងអតុលាទេវីជាចំបងលើស្ត្រីស្នំ ១ ហ៉ឺន ៦ ពាន់នាក់ជាដើម អាណិតអាសូរព្រះករុណា គាននឹងទុក្ខខ្សឹកខ្សួលរំជួលអង្គប្រាណ អត់ទ្រាំពុំបានរំសាយសក់ខ្លួនយំជំទុំពិសម្រែកទឹកនេត្រាបំរះនទៀលអាត្មាលើផែនដីដើរតាមព្រះរាជាទៅតាមផ្លូវព្រះរាជវាំងខាងកើត ឮសូរសព្ទសំឡេងទួញយំនៃស្ត្រីទាំងអស់គ្នានោះគគ្រឹកគគ្រេងជាខ្លាំងបីដូចជាគ្រហឹមនៃមហាមេឃ ។ ចំណែកធនញ្ជ័យកុមារមានកុមារទាំង ៥០០ ជាបរិវារឮសូរសំឡេងទំនួញសន្ធឹកគឹកកងរំពងខ្ទរខ្ទារស្ទះម្នាតាមមើលឃើញហេតុដូច្នោះហើយ ទើបឈរស្ទាក់ពីមុខហត្ថីព្រះទីនាំង តាំងលើកហត្ថាឡើងប្រណម្យបង្គំទូលសួរថា បពិត្រព្រះករុណាថ្លៃវិសេសម្ចាស់ខ្ញុំអើយ ចុះព្រះអង្គមានភ័យអ្វីមកបៀតបៀនឬ ? កើតហេតុកេទយ៉ាងណាអេះ ? ព្រះរាជាមានព្រះរាជឧត្តរថា យើងនេះទៅឲ្យយក្សវាស៊ី ព្រោះយើងបានប្រដៅលាមករកអ្នកប្រាជ្ញ ៧ ថ្ងៃ ឥឡូវនេះរកមិនបានសោះ ទើបយើង

តទៅទំព័រទី ៣០

# សមាគមមិត្តសាលាបាលីសូមថ្វាយសេចក្ដី

# កតញ្ញូចំពោះសម្ដេចព្រះឧបយុវរាជ

សមាគមមិត្តសាលាបាលី សូមថ្វាយសេចក្ដីកតញ្ញូចំពោះ សម្ដេចព្រះឧបយុវរាជ ដោយទ្រង់ព្រះមេត្តាប្រោសសម្រេចក្នុងសន្និបាតរដ្ឋមន្ត្រីពីថ្ងៃទី ១៧–១២–៥៥ ស្ថាបនានៅមន្ទីរសង្គ្រោះសមណនិស្សិត នៅក្រោមក្រសួងធម្មការតាមសេចក្ដីសុំនៃលិខិតលេខ ៤៧ ចុះថ្ងៃទី ២១ តុលា ១៩៥៥ របស់សមាគមនេះ ។

ព្រះអាកប្បកិរិយាដ៏ប្រសើររបស់សម្ដេចនេះ សឲ្យឃើញថាទ្រង់ជាពុទ្ធសាសនូបត្ថម្ភក បានជួយឧបត្ថម្ភសមណនិស្សិតខ្មែរ ឲ្យបានចេញទៅសិក្សារៀនសូត្រព្រះពុទ្ធសាសនា នៅប្រទេសក្រៅជាផ្លូវការ ព្រមទាំងបើកអនាគតនៃព្រះសង្ឃខ្មែរឲ្យមានវឌ្ឍនភាព តាំងពីឆ្នាំ ១៩៥៦ នេះតទៅ ។

ពីមុនមក, សមណនិស្សិតខ្មែរដែលសម្ដេចសង្ឃនាយក ឬ ពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលកម្ពុជរដ្ឋ ឬ សមាគមមិត្តសាលាបាលីបញ្ជូនទៅសិក្សារៀនសូត្រនៅប្រទេសក្រៅ ច្រើនជួបប្រទះនឹងឧបសគ្គគ្រប់យ៉ាង ព្រោះនិមន្តទៅក្នុងឋានៈជាឯកជន មិនមែនជាផ្លូវការ, ម្ល៉ោះហើយច្រើនតែលំបាកគ្មានគ្រូបង្រៀន គ្មានសាលារៀន គ្មានអាហារូបករណ៍តែលតោល, គ្មានទីពឹងផ្អែក ។ល។

ដោយព្រះគុណូបការៈដ៏ជ្រាលជ្រៅនេះ សមាគមនិងព្រះសង្ឃក្នុងកម្ពុជរដ្ឋ សូមគុណានុភាពព្រះត្រៃរតន៍ និងទេវតាទាំងមួយម៉ឺនលោកធាតុប្រសិទ្ធពរជោគជ័យមង្គល សួស្ដីគ្រប់ជំពូក សូមព្រះអង្គទ្រង់គង់នៅជាសុខសប្បាយ ព្រមទាំងព្រះរាជវង្សានុវង្សប្រកបដោយអាយុ វណ្ណៈ សុខ ពល ដើម្បីនឹងបានឧបត្ថម្ភជាតិ សាសនា មហាក្សត្រិយ៍ភេយ្យភាពតទៅ

# រឿងធនញ្ជ័យអ្នកប្រាជ្ញ (ត)

ទៅខ្លួនឯងដើម្បីឲ្យជាអាហារយក្ខ, ចុះទៅមកសួរមានការអ្វី? ធនញ្ជយកុមារក្រាបទូលថា បើដូច្នោះខ្ញុំព្រះអង្គសូមទៅឲ្យយក្ខស៊ីជំនួស សូមព្រះអង្គទ្រង់គង់នៅជាសុខចុះ ។ ព្រះរាជាសួរថា ចុះឯងនេះមលតរធម៌ដែរឬ? បពិត្រព្រះសម្មតិទេព បុគ្គលក្នុងលោកទាំងមូល លើកតែខ្ញុំព្រះអង្គមួយចេញ ឥតមាននរណាម្នាក់ចេះឡើយ មានតែព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទើបព្រះអង្គជ្រាបសព្វគ្រប់បាន ដូច្នេះសូមព្រះរាជទានសំពត់សសុទ្ធស្លៀកនឹងពានាចេញទៅមុន ព្រះអង្គព្រមទាំងពពួកពលនិកាយទាំងឡាយគង់លើដំរីបរតាមក្រោយ ដល់ជិតល្មមមើលឃើញក្នុងយក្ខនោះ សូមព្រះអង្គនឹងពួកពលទាំងអស់ពួនសម្ងំចាំមើលខ្ញុំព្រះអង្គទៅតយុទ្ធនឹងយក្ខចុះ ។ ព្រះនរបតីទ្រង់មានព្រះទ័យបីតិសោមនស្សក្រៃលែងដូចបានកើតម្តងទៀត ត្រាស់ថា សាធុ សាធុ ប្រពៃហើយ ចៅអើយ អរណាស់ហើយ ។ ចំណែកធនញ្ជ័យសេដ្ឋីជាឪពុកនឹងនាងសុខុមាលីជាម្ដាយ ស្ទុះទាំងពីរទៅឃាត់ពោធិសត្វជាបុត្រថា ម្នាលកូនប្រុសសំឡាញ់អើយ បាឯងនៅក្មេងណាស់ យក្ខរូបធំសំបើមណាស់ មានសាច់នឹងឈាមជាប់នៅនឹងមាត់នឹងដៃរាល់ជាធម្មតា បាឯងទៅនឹងបាត់បង់ជីវិតនាសចោលយើងហើយ ណ្ហើយបាត្រូវសូមព្រះរាជានុញ្ញាតព្រះអង្គ ត្រឡប់ទៅផ្ទះវិញ កុំទៅឥតកូនប្រុសម្ដាយ ។

កាលនោះព្រះពោធិសត្វធនញ្ជយកុមារ សំដែងធម៌ល្អលោមមាតាបិតា ឲ្យសុខចិត្តយល់ព្រមដោយសេចក្ដីប្រៀបឧបមាខ្លួនលោកថា ដូចជាមហាសមុទ្រសាគរធំ ទុកណាជាមានខ្យល់ព្យុះបក់បោកដូចម្ដេចក្ដី ក៏មិនអាចរើឡើយពុំនោះសោតដូចជាព្រះអាទិត្យ ទុកណាជារាហូអសុរិន្ទមកបៀតបៀនដូចម្ដេចក៏ដោយ គង់មិនបញ្ឈប់ដំណើរដើរក្រឡឹងលោកជាធម្មតា យ៉ាងណាមិញ ខ្លួនធនញ្ជយពោធិសត្វលោកតែងប្រកបដោយមេត្តាព្រហ្មវិហារ ក៏យ៉ាងនោះដែរ ។ មាតាបិតាកាលបើមិនអាចដើម្បីឃាត់បុត្របាន ក៏ពោលជាបទព្រះគាថាឲ្យកូនថា ជយ បុត្តក សព្វសោត្ថិ សព្វសិទ្ធិ សព្វជយោ ភវតុ តេ ម្នាលកូនសម្លាញ់មាសម្ដាយមាសឪពុកអើយ សួស្ដីទាំងពួងក្ដី សេចក្ដីសម្រេចសម្រិទ្ធជោគទាំងពួងក្ដី ជ័យជំនះឈ្នះមារសត្រូវ ទាំងអស់ក្ដី ចូរឲ្យមានដល់កូនចុះ ។ លំដាប់នោះព្រះបាទជិនាធិបតីគោរព្យរាជទ្រង់កៀកព្រះពោធិសត្វលើកចញ្ចឹះលើខ្នងដំរី ហើយបរសំដៅទៅដើមជ្រៃដែលនន្ទិយក្ខនៅនោះ លុះដល់ល្មមមើលឃើញលឹម ៗ ហើយព្រះរាជាក៏ចុះពីព្រះទីនាំងហត្ថីព្រមទាំងពួកពលចតុរង្គសេនាទាំងឡាយពួនសម្ងំនៅកន្លែង ១ ទាំងអស់គ្នា នៅតែធនញ្ជយកុមារបរមពោធិសត្វជិះដំរីម្នាក់ឯងស្ទុះ ក្លៀវក្លាបីដូចជាស្ដេចកេសរសីហៈចេញពីគុហារមាស បរហត្ថីបានដល់ដើមជ្រៃហើយ តាំងស្រែកហៅយក្ខថា ភោ នន្ទិយក្ខ អើ នន្ទិយក្ខដ៏ចំរើន យើងមកដល់ហើយ យក្ខបានឮសំដី

ធនញ្ជយពោធិសត្វហៅដូច្នោះហើយ ស្រាប់តែគាត់ក្រើតកើតចិត្តមេត្តាករុណា ទោរទន់ស្រឡាញ់ដូចកូនដែលកើតពីសាច់ខ្លួន ក៏និម្មិតឲ្យឃើញច្បាស់ហើយសួរថា៖ គោ មាណវ ម្នាលមាណពដ៏ចំរើន អ្នកឈ្មោះអ្វី? ជាកូនអ្នកណា? នៅឯណា? មករកអ្វី? អ្នកណាឲ្យអ្នកមក? ព្រះធនញ្ជយកុមារតបថា យើងឈ្មោះធនញ្ជយកុមារ ជាបុត្រនៃធនញ្ជយសេដ្ឋី យើងជាទាសបុត្រនៃស្តេចព្រះនាមធនញ្ជយកោរព្យរាជ ព្រះអង្គបញ្ជូនឲ្យមក បានជាយើងមក ៗ នន្ទិយក្សសួរថា ចុះអ្នកចេះមលតរធម៌ឬទេ? ព្រះពោធិសត្វតបថា អ្នកឯងដឹងដែរឬទេ យើងនេះស្តេចបញ្ជូនមកឲ្យអ្នកបរិភោគជាអាហារ ៗ នន្ទិយក្សថា សាច់នឹងឈាមអ្នកនេះមិនស្កប់ដើងឆ្ញេញយើងទេ យើងមិនបរិភោគអ្នកឡើយ អ្នកចូលមកចុះ ៗ ពោធិសត្វក៏ចូលក្រោមម្លប់ជ្រៃ ហើយឈរនៅស្ងៀម ៗ នន្ទិយក្សសួរថា ម្តេចក៏មិនចូលឲ្យដល់យើងមក? តបថា យើងប្រព្រឹត្តសុចរិតធម៌ បានជាយើងមិនចូលឲ្យដល់ យក្សសួរថា ចុះសុចរិតធម៌នោះដូចម្តេច សំដែងទៅមើល? ឆ្លើយថា បើដូច្នោះចូរប្រុងស្តាប់ចុះ យើងសំដែងឥឡូវនេះ ហើយពោលជាបទព្រះគាថានេះថា

អនិមន្តិ ឃរំ គន្ត្វា អបុដ្ឋា បរិភាសតិ
អត្តានញ្ញ បសំសិយោ តំវេ ហីនលក្ខណំ ៗ

សេចក្តីថា កិរិយាខាតលក្ខណ៍មាន ៣ យ៉ាងគឺ គេមិននិមន្តឬអញ្ជើញឲ្យទៅផ្ទះគេ រមែងទៅកាន់ផ្ទះគេញឹក ៗ នេះ ១ ៗ គេមិនទាន់សួរឆ្លើយស្រេវ ១ ៗ គេពុំទាន់សរសើរ ពោលលើកខ្លួនអួតសរសើរខ្លួនឯងមុន-១ ៗ ម្នាលនន្ទិយក្សបុគ្គលណាលៃលះបង់ហីនលក្ខណៈថោកទាបទាំង ៣ យ៉ាងនេះចេញ ទើបបានពេញជាអ្នកកាន់សុចរិតពិត ៗ នន្ទិយក្សស្តាប់ហើយកើតសេចក្តីអស្ចារ្យនឹងធម៌ធនញ្ជយកុមារក៏គិតថា នេះជាបុរសអាជានេយ្យដោយពិត ជ្រះថ្លាណាស់បូជាគ្រឿងសក្ការដ៏ច្រើន តាំងរៀបគ្រែធម្មាសនៈ នឹងគ្រឿងសក្ការបូជានឹងស្វេតច្ឆត្រហើយហោះស្ទុះទៅដងទឹកអនោតត្តស្រះពីព្រៃហេមវន្តប្រទេសមកផ្ងូតជម្រះកាយពោធិសត្វ ហើយប្រោះព្រំគ្រឿងអលង្ការគន្ធពិដោរឈ្ងុយឈ្ងប់ជាអស្ចារ្យ ស្រេចកាលណា ក៏សូមអញ្ជើញធនញ្ជយបរមពោធិសត្វឡើងលើគ្រែធម្មាសនៈទេសនាមលតរធម៌ ឲ្យជាទីសវនាការ ៗ មហាបុរស ចាប់យកផ្ចិតបាំងបិទមុខហើយ តាំងប្រកាសសេចក្តីថា គោ យក្ខរាជ ម្នាលស្តេចយក្ខដ៏ចំរើន អ្នកប្រុងចាំស្តាប់ចុះ យើងនឹងលើកយកល្យាណធម៌មកសំដែង ឥឡូវនេះឯង ទើបឲ្យស័លជាបទគាថាដូច្នេះថា៖

បាណាតិបាតា ធនហារតាបិ
បរស្ស ទារំ វចនំ អសច្ចំ ៗ
មជ្ជំ បិវេ យោ ឥធ សោ នរោ ច
បមូលច្ចេទោ មុនិនា បវុត្តោ ៗ

សេចក្តីថា បុរសស្ត្រីណាក្នុងលោកនេះ សម្លាប់សត្វមានជីវិត១ លបលួចឆក់ដណ្តើមបោកបញ្ឆោតយកទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយគឺលួចប្រពន្ធ

កូនឬ ស្វាមីគេ ១ ៗ ពោលពាក្យកុហក ១ ផឹកស្រា
ឬមេរ័យគឺផឹកទឹកត្នោតជូរឬផឹកតាគៀន ផឹកកញ្ឆាជា-
ដើម ១ ៗ អ្នកណាប្រព្រឹត្តអំពើទាំង ៥ នេះ ឈ្មោះថាជីក
រំលើងឫសគល់ជាតិកំណើតខ្លួនឲ្យខានកើតជាមនុស្ស
បានទៀត នេះជាធម៌មន្ទិលធំបំផុត

តស្មា ភយំ វេរំ សរិត្វា
វេរំ ជហិត្វា ន រមេយ្យ សីលំ ៗ
អនន្តគុណញ្ច មហានិសំសំ
សម្បត្តបាវំ ជិនគោចរន្តិ ៗ

សេចក្ដីថា ព្រោះហេតុនោះ បុគ្គលជាសប្បុរស តែងរលឹកឃើញភ័យក្នុងបញ្ចវេរទាំង ៥ ថា ជាមន្ទិលខ្លាំងក្លាយ៉ាងនេះហើយ លោករមែងលះបង់ចោលស្រឡះ រួចលោកត្រេកអរក្នុងសីល ៥ ដែលជាសីលមានអានិសង្សច្រើនជាអនន្តគុណជាទីគោចរ នៃព្រះជិនស្រីជាទីតាំងនៃសម្បត្តិទ្រព្យឲ្យកើតឡើង ហើយតាំងនៅមាំមួនផង ៗ លុះចប់កល្យាណធម៌ហើយ នន្ទិយក្ខមានចិត្តជ្រះថ្លា ប្រណម្យអញ្ជលីទូនសិរសាក្រាបក្រោមបាទានៃព្រះពោធិសត្វហើយ បញ្ចេញនូវគាថាថា

គណ្ហាមិ បញ្ចសីលានិ បាលេយ្យន្តិ សុនិមលំ
ឯវំ សគ្គណ្ហិតុំ ធីរ សិទ្ធិវិហារគន្តិមំ ៗ

អធិប្បាយថា បពិត្រអ្នកប្រាជ្ញមានព្យាយាមដ៏ធំ ខ្ញុំសូមទទួលកាន់យកនូវសីលទាំង ៥ នេះហើយ សូមលោកអ្នកប្រាជ្ញសង្គ្រោះដល់ខ្ញុំ ថាជាកូនសិស្សផ្ទាល់ ខ្ញុំនឹងរក្សាសីលឲ្យល្អមិនឲ្យសៅហ្មងឡើយ ៗ មហាបុរសឲ្យសីលចប់សព្វគ្រប់ហើយឈប់នៅស្ងៀម ទេវតាទាំងឡាយក៏ស្រែកឲ្យពរស័ព្ទសាធុការលាន់រំពងខ្ទរខ្ទារ នន្ទិយក្ខសូមអារាធនា ឲ្យសំដែងមលតរធម៌តទៅទៀត ៗ ព្រះពោធិសត្វពោលថា ម្នាលនន្ទិយក្ខ បើដូច្នោះចូរអ្នកប្រកាសឃោសនា ព្រះបាទទេវព្យាកជព្រមទាំងរាជបរិសទ្យទាំងអស់ឲ្យស្ដេចយាងមកស្ដាប់ធម៌ផងចូរប្រ–កាសដល់ទេវតាទាំងឡាយឲ្យមកស្ដាប់ផង ៗ នន្ទិយក្ខក៏ស្ទុះក្លាមទៅនាំយកព្រះរាជាព្រហមទាំងបរិវារ ដាក់លើស្មាមកដំកល់ទុកក្នុងទីនេះមួយរំពេច រួចប្រកាសដល់ទេវតាឲ្យចូលមកសន្និបាតឆាប់ទាន់ចិត្ត ៗ ព្រះ-ពោធិសត្វ កាលបើឃើញព្រះរាជាព្រហមទាំងបរិសទ្យនឹងទេវតាទាំងឡាយ មកជួបជុំមីរដែរជាសពាសពេញជុំវិញ ហើយក៏តាំងពោលថ្លែងជាបទព្រះគាថាយ៉ាងនេះថា

ទិដ្ឋុទ្ធច្ច ទោសន្ធ កិចំ ថីនមិទ្ធ
អហិរិកំ អនោតប្បំ លោភនាសយុត្ត នេតេ
កិលេសា ចិត្តក្លេសគោ មលតវេធម្មា នាម ៗ

ប្រែថា៖ ធម៌ទាំងឡាយ ១០ យ៉ាងនេះគឺ ទិដ្ឋិ សេចក្ដីយល់ខុសប្រកាន់ឡើងថាត្រូវ ១ ឯជា បង់បានទ្រព្យហួសពេក ១ ឧទ្ធច្ច ចិត្តរាយមាយ ១ ទោសោ ខឹងប្រទុស្សរ៉ាយព្យាបាទអាឃាតចងពៀរ ១ អន្នោ លង់វង្វេងហើយនាំគេឲ្យលង់តាមផង ១ កង្ខា សន្ទិះ សង្ស័យនឹងគុណព្រះរតនត្រ័យ ១ ថីនំ ធុញទ្រាន់ងងុយងោកងក់ ១ ឧទតិ ឡើងធំនោះហើយប្រកាន់មានះ ១ អហិរិកំ មិនខ្មាសបាប ១ អនោតប្បំ មិនព្រឺ

ស្រេចអំពើបាប ១  ធម៌ទាំង ១០  យ៉ាងនេះឈ្មោះថា មលគរធម៌  ព្រោះជាធម៌នាំសត្វឲ្យមន្ទិលសៅហ្មងក្រៃលែង  តែងនាំសត្វឲ្យធ្លាក់ទៅក្នុងអបាយភូមិ ៤  នរក តិរច្ឆាន,  អសុរកាយ,  ប្រេត  បិទទ្វារទៅស្ថានសួគ៌ និងព្រះនិព្វាន ។  បុគ្គលបើបានលះបង់នូវមលគរធម៌ នេះជ្រះស្រឡះហើយ  ទៀងតែបានត្រាស់ដឹងនូវសួគ៌ និងព្រះនិព្វានពុំខានឡើយ ។  លុះចប់ធម៌ទេសនាហើយ សំឡេងពរសព្ទសាធុការនៃទេវតានិងមនុស្សទាំងឡាយ ក៏លាន់ឮផ្សាយឡើងបីដូចជាទំរង់ទុះនៃមហាប្រថពី ។ នខ្ញុំយកក្តីទុនសិរសាក្រាបក្រោមបាទានៃមហាបុរស ហើយពោលថា  សុន្ទរ៍  បពិត្រលោកអ្នកប្រាជ្ញមាន ពីព្យាយាមដ៏ប្រសើរចាប់ដើមពីថ្ងៃនេះទៅ  ខ្ញុំម្ចាស់សូម ជ្រកកោនជាកូនសិស្សជាទីពឹងស្មើដោយជីវិត ។ គ្រា-នោះ  សម្ដេចព្រះបរមចក្រាធិបតីកោរព្យរាជ  ទ្រង់ទុន ទុបទ្រថ្នាក់ថ្នមព្រះធនញ្ជ័យបរមពោធិសត្វលើកចេញ ចាកត្រៃគធ្មាសនៈ  ទ្រង់មានព្រះរាជឧត្ដរថា  ចាប់ ដើមតាំងពីពេលនេះទៅ  មានតែធនញ្ជ័យកុមារនេះ ហើយជាទីពឹងរបស់យើង  ហើយទ្រង់ឱបប្រកៀកព្រះ មហាបុរសឡើងជិះលើខ្នងដំរីដ៏ប្រសើរ  បិទបាំងដោយ ស្វេតច្ឆត្រដង្ហែដោយចតុរង្គសេនា  ត្រឡប់ចូលព្រះន-គរវិញ ។  លុះបានដល់ព្រះនគរហើយ  ព្រះរាជាទ្រង់ ឲ្យអាមាត្យទៅអញ្ជើញនាងសុខុមាលី  និងធនញ្ជយ-សេដ្ឋី  ព្រមទាំងនាហ្មឺនសព្វមុខមន្ត្រីមកជួបជុំហើយ ព្រះអង្គប្រកាសតាំងធនញ្ជ័យកុមារមានអាយុ ៧ ឆ្នាំ ឲ្យ

ជាព្រះរាជបុត្រច្បង  ជាធំជាងព្រះរាជវង្សានុវង្សទាំង អស់ ។  ឯមាតាពោធិសត្វក៏ព្រមថ្វាយ ។  ព្រះរាជា ប្រគល់ប្រាសាទខាងមុខបុរីស្ថានដ៏ប្រសើរ  ហើយអភិ-សេកលើកព្រះពោធិសត្វជាបុត្របង្កើតទ្រង់ប្រទានរង្វាន់ ១ ថ្ងៃ ១ សែនកហាបណៈ ។  និងយសដ៏ធំ  ព្រមទាំង ពលពាហនៈច្រើនរយពាន់  ហើយធ្វើស្រុកទាំងនោះឲ្យ ជាស្រុកនាំសួយសារាករឡើងសម្រាប់ធនញ្ជយសេដ្ឋី ។ តមកព្រះពោធិសត្វបានប្រកបដោយលាភសក្ការៈនិង សេចក្ដីរាប់អាននៃពួកមនុស្សនិងទេវតានិងឥស្សរភាព ដ៏ឧត្តុង្គឧត្តមថ្កើងថ្កានល្បីល្បាញសុសសាយពេញខ្ទរខ្ទាយ ដល់ដែនកុរុរដ្ឋទាំងមូល  ដោយបុញ្ញានុភាពនៃធនញ្ជ័យ បរមពោធិសត្វកុមារនោះឯង ។  ( នៅមានត )

* * *

## ពុទ្ធឃោសប្រវត្តិ (សង្ខេប)

ចាកវិសុទ្ធិមគ្គភាគ ៣ ទំព័រ ១៤៥១

៧  ខ្ញុំសូមបង្គំព្រះសម្ពុទ្ធ

ព្រះធម៌ព្រះសង្ឃអង្គពិសុទ្ធ  មកុដពិសេសត្រៃលោកា ។ រួចខ្ញុំសូមថ្លែងសំដែងបទ  ប្រវត្តិព្រះពុទ្ធឃោសាចារ្យ លោកជាអ្នកប្រាជ្ញក្នុងសាសនា  នៃព្រះសាស្ដានាមគោ តម ។

អតីតសម័យបានឮថា  ព្រះមហារាជាដ៏ជាធំ សោយរាជ្យសម្បត្តិបុរីមួយ  លង្កាទ្វីបធំជាអស្ចារ្យ ។ ព្រះនាមព្រះបាទមហានាម  ស្តេចធ្វើសង្គ្រាមលើកសា-សនា

ក្នុងពុទ្ធសករាជព្រះវស្សា បានប្រាំមួយរយហាសិបមួយៗ
កាលនោះមានព្រាហ្មណ៍មាណព រៀនសព្វវេទមន្ត
ឥតមានព្រួយ
កើតក្នុងត្រកូលនៃព្រាហ្មណាមួយ ក្បែរជ្រួយព្រះពោធិ
មណ្ឌល ៗ

ក្នុងជម្ពូទ្វីបភាគកណ្ដាល មាណពពិសាលជាចមពល
បេះសព្វត្រៃវេទគ្មានទើសទាល់ គ្មានធ្ងល់ពិផលកិច្ចត្រង់
ណា ៗ

ដើរត្រាច់រង្គាត់ក្នុងទិសទី ធានីខណ្ឌរៃត្រាដសីមា
ដើម្បីសាកសួរអាថ៌ប្រស្នា នឹងបញ្ញាផងទាំងឡាយៗ
បញ្ហាមាណពនោះសួរទៅ តឹងជ្រៅពុំអាចនឹងបរិយាយ
បើសួរគាត់វិញអាចអធិប្បាយ ដោះស្រាយដោយធូរ
ឥតមានទាល់ ៗ

មាណពកម្លោះតែងផ្គាញ់ផ្គាល ប្រាជ្ញជាន់កណ្ដាលសព្វ
មណ្ឌល
សួរស្ដីបង្អាប់ជនសាកល ថ្ងៃមួយបានដល់វត្តពិហារៗ
ព្រះខីណាស្រពរេវតៈ លោកជាបដិសម្ភិទា
បានជ្រាបជាក់ច្បាស់ក្នុងអាត្មា ថាព្រាហ្មណ៍កុមារមក-
ដល់ហើយ ៗ

លុះដល់រាត្រីអាធ្រាត្រស្ងាត់ សព្វសត្វដេកលក់គ្មាន
សល់ឡើយ ៗ
ព្រាហ្មណ៍ក្រោកអំពីពូកខ្នល់ខ្នើយ ភ្ញាក់ហើយតាំងសូត្រ
មន្តវិជ្ជា
ឈ្មោះថាបាតញ្ជលិមន្ត សម្បូណ៌ដោយបទល្អសោភា

រេវតជ្រាបក្នុងព្រះទ័យា ថាគួរទូន្មានមាណពបាន ៗ
ទើបហៅមាណពមកសួរថា សួរជាប្រស្នាសត្វតិរច្ឆាន
អ្នកណាមានប្រាជ្ញក្នុងសន្តាន ស្រែកបានដូចជាសម្លេង
ណា ៗ

មាណពតបថាលោកម្ចាស់ដឹង ខ្ញុំពុំដំណឹងសម្លេងវា
រេវតឆ្លើយប្រាប់ឆាប់ម្ល៉ឹមម្លា អាត្មាជាក់ជាស្គាល់ប្រាកដៗ
សេចក្ដីសរសើររេវតៈ លោកជាពិទគ្គចាំបែបបទ
រៀនចប់ត្រៃវេទពិតប្រាកដ គេសន្មតថា "បារគូ" ៗ
ហើយជាព្រះខីណាស្រព បេះចប់ហាក់ដូចសព្វញ្ញូ
នឹងបដិសម្ភិទាវិទូ លោកត្រាស់យូរណាស់មកហើយផងៗ
ដូច្នេះបានជាព្រាហ្មណ៍មាណព សួរសត្វក្បួនគេច្រើន
កន្ទង

លោកឆ្លើយឥតទើសឥតទាល់ម្ដង សាសង់ប្រាយប្រាប់
ទៅមាណព ៗ

មាណពសួរលោកជាច្រើនដង ទើបលោកឆ្លើយឆ្លងថា
ព្រាហ្មណ៍ឈប់
អ្នកសួរអាត្មាច្រើនលើសលប់ត្រូវឈប់អាត្មាសួរអ្នកម្ដងៗ
ព្រះថេរតាំងផ្ដើមជាបញ្ហា ធ្វើជាប្រស្នាតាមពួកគង
ត្រង់ចិត្តយមកៈជ្រៅកន្ទង តាំងសង់សួរទៅមាណពថាៗ
ចិត្តអ្នកណាកើតមិនរលត់ ចិត្តផុតមិនកើតមិនសាវ៉ា
ចិត្តផុតមិនកើតតាមធម្មតា ចិន្តាកើតហើយមិនរលត់ ? ៗ
កាលព្រាហ្មណ៍កម្លោះបានស្ដាប់ជាក់ ភ្ញាក់ភ្ញាក់ក្នុងចិត្ត
ញ័ររន្ធត់

សួរព្រះថេរៈដោយគក់ស្មុគ ថាបទនេះឯងឈ្មោះមន្តអ្វី?ៗ
ថេរតប្រាប់ថាឈ្មោះពុទ្ធមន្ត ព្រោះដ៏មានបុណ្យអនន្តជិនស្រី
ទ្រង់សំដែងប្រាប់ដោយសេរី ដល់សត្វលោកិយសព្វរូបា ។

មាណពសួរថារៀនបានទេ សូមតាថេរៈដោយត្តា
ដាក់ទានដល់ខ្ញុំករុណា ធ្វើជាតាសាព្រះសម្ពុទ្ធៗ
ថេរថាបើចង់សិក្សា បួសដូចអាត្មាទើបបរិសុទ្ធ
អាត្មាប្រៀនបានតែកុលបុត្រ ពិសុទ្ធប្រាសចាកគ្រឿងសៅហ្មងៗ

ក្រោយមកមាណពបានចូលបួស ដោយផ្នួសភិក្ខុស្រេចហើយហោង
សិក្សាព្រះត្រៃបិដកផង កិត្តិស័ព្ទគឹកកងពេញលោកា ។
ទើបមាននាមថ្មីល្បីប្រាកដ ថា "ពុទ្ធឃោសៈ" មានប្រាជ្ញា
ជានាមលេចឮដោយវាចានៃលោកលោហាជនប្រុសស្រីៗ
លោកគង់ក្នុងវត្តមហាពិហារ បានតែងវណ្ណនាជាបាលី
ឈ្មោះថាគម្ពីរញាណោទ័យ អធិប្បាយមានន័យដ៏វិចិត្រៗ
ហើយរៀបរៀងអដ្ឋកថា ធម្មសង្គណី យ៉ាងប្រណីត
ទាំងអដ្ឋកថាព្រះបរិត្ត ពិសិដ្ឋពិសេសឯកអនគ្ឃ ។
ឈ្មោះថាអដ្ឋសាលិនី គម្ពីរលោកគ្រូពុទ្ធឃោសៈលោក
ជាអ្នកប្រាជ្ញភាចពិទិត្ថបេះដាក់តាមគម្ពីរពីបូរាណ ។
ឯព្រះរេវតជាឧបជ្ឈាយ៍ បានឃើញបុទ្ធប្រាជ្ញចំណាន
នៃពុទ្ធឃោសៈដែលតែងបាន ត្រឹមត្រូវតាមជានគម្ពីរបាលី ។

លោកមានថេរដីកាថា នៃពុទ្ធឃោសាប្រាជ្ញថ្លៃ
ឯអដ្ឋកថាជាបាលី នៅលើដែនដីពុំមានទេ ។
វីអដ្ឋកថាសីហឡៈ ថេរៈសារីបុត្រលោកវិះរេ
ជាមួយព្រះមហិន្ទត្ថេរ វិះរៀបចំសង្គាយនា ។
ដូច្នេះលោកទៅសីហឡទ្វីប តែងរៀបជាមគធភាសា
ទុកជាប្រយោជន៍សព្វសត្តា អ្នកមានបញ្ញាអន់ជាន់ក្រោយ ។

ព្រះពុទ្ធឃោសចមរិទ្ធ លុះបានឮត្រូវបើកផ្ទៀង
កើតបីតិប្រមោទ្យដូចបានសោយ ព្រះស្ងោយយ៉ាងឆ្ងាញ់ដ៏ពិសេស ។

ទើបថ្វាយបង្គំព្រះឧបជ្ឈាយ៍ លុតលាលោកសង្ឃក្នុងប្រទេស
ចេញចាកវិហារថានទិវេសន៍ ឡើងទេសនាវាចរយាត្រាៗ
លុះដល់ពាក់កណ្ដាលសាគរ ចួបនាវាចរល្អរសោភា
ចួបតាំងពុទ្ធទត្តជាថេរ បានថ្លែងវាចាគួរសមៗ
រួចបែកចូលទៅកោះលង្កា ក្នុងដែនរដ្ឋដោយមានោរម្យ
ចូលអនុរាធបុរីថ្វាយបង្គំ សង្ឃបាលជាធំទៅអាវាស ។
ថ្លែងប្រាប់ហេតុការណ៍ដូចពណ៌នា ពីព្រះឧបជ្ឈាយ៍បានប្រកាស

សង្ឃបាលត្រេបានជ្រាបច្បាស់ ត្រេកអរសោមនស្សឥតឧបមា ។

ព្រះភិក្ខុសង្ឃនៅក្នុងវត្ត បេះស្គាល់ចាំច្បាស់ក្បួនដីកា
ចង់ល្បងបញ្ញាពុទ្ធឃោសា ទើបចេញវាចាថាសប្បុរសៗ

សូមលោកជកស្រង់ធម៌ត្រង់ណា ដែលមានខ្លឹមសារ
យ៉ាងពិរោះ
តុបតែងរៀបរៀងឲ្យយ៉ាងស្រស់ ទុកជារបស់ព្រះ
សាសនា ។
ព្រះពុទ្ធឃោសៈអ្នកប្រាជ្ញឡើយ តាំងផ្ដើមប្រមូលអដ្ឋកថា
តែងសីលសមាធិបញ្ញា ឈ្មោះជាគម្ពីរវិសុទ្ធិមគ្គ ។
ធ្វើចប់កន្លងប្រថមយាម ឥតពាក់ពាមដោយឧបស័គ្គ
សឹងលក់ទេវតាក៏លួចធក់ វិលហក់ទៅបានសួគ៌ាល័យ ។
ឯលោកឃើញបាយករណ៍លោកបាត់ តាំងចាត់តែងទៀត
ដោយប្រពៃ
ទេវតាក៏មកធក់វិលវៃ ទៅបានសួគ៌ស្រីប្រកាសគុណ ។
វារៈទី ៣ លោកតែងចប់ ដោយប្រាជ្ញប្រសប់លោកមាន
បុណ្យ
ឯគម្ពីរ ២ អំពីមុន បាត់ស៊ិនសូន្យឈឹងស្រាប់ឃើញ
វិញ ។
ទើបលោកនាំយកសំណាដៃ លោកតែងថ្មីៗ ពីយប់មិញ
ប្រគេនសង្ឃបាលឲ្យទតវិញ តើពេញព្រះទ័យឬយ៉ាង
ណា ? ។
ព្រះសង្ឃបាលនឹងពួកសង្ឃ សុទ្ធតែជាអគ្គមានប្រាជ្ញា
ប្រជុំគ្នាផ្ទៀងតាមដីកា ឥតពាស់អក្ខរាត្រង់ណាសោះ ។
សូម្បីដោយបទពញ្ជន អត្ថៈ គណ្ឋៈ មិនពិរោះ
រៀបរៀងត្រឹមត្រូវល្អឥតខ្ចោះ សប្បុរសនេះហៅថាចេះ
មែន ។
តាំងពួកទេវតាក៏ឲ្យពរ សាទរពប់គោជ័យលានមុឺនសែន

ព្រះសង្ឃច្រើនអង្គប្រជុំណែន ថាមែនហ្នឹងហើយព្រះសិ
ការ្យ ។
គ្រានោះមហានាមព្ទសម្រេក ទេវតាស្រែកថ្វាយពរជយា
ទ្រង់ព្រះសណ្ដាប់ស្ដេចយាត្រា ព្រមដោយសេនាទៅ
គាល់ហៅ ។
ទៅថ្វាយបង្គំពុទ្ធឃោសៈ ពប់គានពក់ពាក់ស្នួរស្នួរខុស
ត្រូវ
ស្គាល់ច្បាស់ថាប្រាជ្ញអាចចេះជ្រៅ ទើបនៅថ្វាត់ថ្វាយ
ភិក្ខាហារ ។
ព្រះពុទ្ធឃោសៈចមវិញ លោកមិនគិតគួរកិច្ចសាព
ចូលទៅប្រាសាទពជប្រាង្គណ៍ប្រា ឈ្មោះជាប្រធាន
ឃក ។
ចាប់ប្រែអដ្ឋកថាបិដក ជាមគធៈមូលភាសា
ពីសីហលដ្ឋកថា ជានិរុត្យាគឺបាលី ។
គឺប្រែកុរុដ្ឋកថា តាមដោយប្រាជ្ញាដ៏ប្រិមប្រិយ
វិនយដ្ឋកថាខែសេចក្ដី នាមឈ្មោះនោះនៃហៅសមន្ត ។
ហើយប្រែមហាអដ្ឋកថា តាមភាសាដែលនៅគង់សុត្តន្ត
រៀបរៀងពាល់តែបានគ្រប់គ្រាន់ ប្រាំមុឺនបួនពាន់ធម្ម
ក្ខន្ធ ។
ព្រមទាំងកថាផងទាំងឡាយ បរិយាយសុទ្ធសឹងតែសំ
ខាន់
សេចក្ដីជ្រៅឆ្ងាយអត្ថអនន្ត អានេកពេកពន់ល្អក្នុង ។
រៀបរៀងមួយឆ្នាំទើបបានចប់ លោកឡប់វិលវិញឥត
សៅហ្មង

តាមពុទ្ធដីកាទុកឲ្យយ៍ផង មិនឲ្យគង់សត្យសំដី ។

ប្រវត្តិព្រះពុទ្ធឃោសៈ អ្នកប្រាជ្ញវចនៈជាសេចក្តី
មានតាំងសៀមខ្មែរប្រែបាលី ទុកដើម្បីប្រកាសកិត្តិគុណ។
នៃព្រះថេរៈជាអ្នកប្រាជ្ញ ដែលលោកអង់អាចក្នុងកាល
មុន
យើងគេចេះដឹងដោយសារបុណ្យ បញ្ញាធិគុណពុទ្ធឃោ
សា ។

ឱ‌ៈឱ ! ព្រះគុណពុទ្ធឃោសៈ លោកមានវីរយៈដ៏ហាន
ក្លា
ចុះមកប្រោសសត្វក្នុងលោកា ឲ្យមានបញ្ញាចេះយ៉ាង
វែង ។

ខ្ញុំគិតពុំទាន់យល់គន្ត្រា យល់តែសំណាដៃដែលតែង
សូមលើកម្រាមដៃផប់ប្រសព្វវែង ចាត់ចែងថ្វាត់ថ្វាយ
កាយវន្ទា។

សូមសុខសួស្តីមានដល់ខ្ញុំ បំណាច់បានចំតែងពណ៌នា
ដកស្រង់រឿងនេះមកលាតលា ពណ៌នាសង្ខេបបែប
យ៉ាងខ្លី ។

ស្រង់ចាកគម្ពីរវិសុទ្ធិមគ្គ វចនៈតាមលោកឃោតសេចក្តី
សូមទាន់សាសនាព្រះជិនស្រី សិក្សាប្រមេត្រីឯក្រោយ
ហោង ។

ចប់ថ្ងៃទី ១–៨ ៩៨

ភិក្ខុ ម. ប្តូវី

★

★ ★



# ពុទ្ធសាសនា ក្នុងប្រទេសជប៉ុន

កាលព.ស. ១០៩៥ ពុទ្ធសាសនាបានផ្សាយចូលទៅ ក្នុងប្រទេសជប៉ុន ហើយមានសេចក្តីចំរើនរុងរឿងណាស់ ព្រោះព្រះរាជវង្សានុវង្សជាន់ខ្ពស់របស់ជប៉ុនជាច្រើនអង្គបាននាំគ្នាចេញបួសជាភិក្ខុក្នុងព្រះពុទ្ធ–សាសនា ។ ក៏បានជ្រៀតជ្រែកចូលក្នុងចិត្តរបស់ជាតិជប៉ុនទួទៅពេញប្រទេសតាំងមូល ពាល់តែក្លាយទៅជាសាសនាតាមផ្លូវរាជការ ក្នុងរាជ្យពុទ្ធសកពជ ១១៣៦។

ក្នុងសៀវភៅពុទ្ធសាសនា ដែលអ្នកប្រាជ្ញបានតែងហើយ លោកបានពណ៌នាថ្វេងអំពីគុណវិសេសនៃពុទ្ធសាសនាទុកជាយ៉ាងធំថា "ពុទ្ធសាសនា បានដឹកនាំបើកផ្លូវឲ្យប្រជាជនជប៉ុន ដើរចូលទៅកាន់វិធីនៃសេចក្តីចំរើនរុងរឿងយ៉ាងវិសេសជាងសាសនាដទៃ ។ គឺជាតិជប៉ុនបានគ្រេបផ្តាច់យកអក្សរ និងភាស្រ័យពាក្យប្រដៅរបស់ពុទ្ធសាសនាក្នុងផ្លូវគំនិត ផ្លូវគ្រប់គ្រងប្រទេស និងផ្លូវប្រជាគម" ។

អ្នកកាន់ពុទ្ធសាសនា ដែលចូលទៅផ្សាយលទ្ធិ

ព្រះសមណៈគោតមក្នុងប្រទេសអាទិត្យទុទ័យ បាន ពន្យល់បំភ្លឺឲ្យជាតិជប៉ុនរកផ្លូវចេញពីទីងងឹតឃើញ ហើយ បានប្រដៅឲ្យអ្នកនគរជប៉ុនចេះកសាងតាំងខ្លួនឯងឡើង។ សាសនាព្រះគោតមអាចបណ្ដុះបណ្ដាលឲ្យកើតសេចក្ដី ចំរើនខាងផ្លូវសេដ្ឋកិច្ច និង សិល្បកម្ម ក្នុងប្រទេស ជប៉ុនជាអនេកទៀតផង ។

ហេតុនេះ អ្នកដែលកាន់ពុទ្ធសាសនាក្នុងកម្ពុជរដ្ឋ យើង ត្រូវតែយកចិត្តទុកដាក់ក្នុងពុទ្ធសាសនាឲ្យមុតមាំ ដើម្បីនឹងធ្វើឲ្យកើតប្រសិទ្ធិភាពមែនទែនឡើង ទើប– ប្រទេសជាតិបានលឿនទៅកាន់សេចក្ដីចំរើន ដោយ សារបណ្ដារាស្ត្រក្នុងប្រទេសបានទទួលសេចក្ដីសុខ ក្សេមក្សាន្ត ឲ្យសមជាការប្រទេស ។

ម្យ៉ាងទៀត កិច្ចសិក្សាជាធ្នឹមខ្នងរបស់ប្រទេស សាលាបង្រៀនជាកន្លែងសម្រាប់ប្រដៅមនុស្សដែលមិន បានការ ឲ្យក្លាយទៅជាមនុស្សបានការ ប្រទេសនឹង បានចំរើនលឿនទៅមុខដូចការប្រទេសទាំងឡាយដែល គេបានចំរើនមកហើយនោះក៏ទៅលើរូបមនុស្ស បើមាន មនុស្សចេះដឹងច្រើនប្រឹងប្រែងធ្វើការចិញ្ចឹមជីវិតនិងមាន សីលធម៌គ្រប់គ្នាហើយ ប្រទេសក៏នឹងបានចំរើន ប្រាកដ តួយ៉ាងដូចជាប្រទេសជប៉ុនជាដើម ។

ចប់

នាមសញ្ញា

ព្រះសមុហ៍–សៅ–ចេស

★ ★ ★

# ព្រះពុទ្ធសាសនាក្នុងដែនកម្ពុជា

មនុស្សជាន់ដើមក្នុងកម្ពុជា គេមិនអាចដឹងប្រាកដ ថាកាន់សាសនាអ្វីឡើយ តែគេស្មានថា គ្មានសាសនា អ្វីកាន់ទេ គ្រាន់តែគោរពរាប់អានកោតខ្លាច អារក្ស អ្នកតា និងខ្មោចបិសាចផ្សេងៗប៉ុណ្ណោះ ។

តមកប្រហែលជាក្នុងរវាង គ.ស. ៤០០ (១) ឆ្នាំ ទើបមានមនុស្សអាគន្តុកជាតិហិណ្ឌូ នាំយកលទ្ធិសាស-នាព្រាហ្មណ៍ពីប្រទេសឥណ្ឌាមកផ្សាយដឹកនាំប្រជាជន ឲ្យកាន់តាម ហើយចែកបណ្ដារាស្ត្រទៅជា ៤ ពួក ដែល ហៅថា "វណ្ណៈ" ទៅតាមរបៀបឥណ្ឌាគឺ:

ខត្តិយៈ ១, ព្រាហ្មណៈ ១, វេស្សៈ ១, សុទ្រៈ ១ ។

ឯព្រះពុទ្ធសាសនាសព្វថ្ងៃនេះ ដែលផ្សាយចូល មកក្នុងសតវត្សរ៍ទី ៣ នៃពុទ្ធសករាជ គឺ ព. ស. ២៣៦ ក្នុងសម័យដែលអសោកមហារាជ និងព្រះមោគ្គលីបុត្ត-តិស្សត្ថេរ បានបញ្ជូនសមណទូតឲ្យដើរប្រកាសផ្សាយ ព្រះពុទ្ធសាសនា ។ ព្រះសោណត្ថេរនិងព្រះឧត្តរត្ថេរ បានមកប្រកាសក្នុងដែនសុវណ្ណភូមិ ។ ប្រទេសកម្ពុជា យើងក៏បានទទួលនិងគោរពក្នុងសម័យនោះ ។

លើកទី ២ លទ្ធិអាចារ្យវាទ បានផ្សាយចូលមក ក្នុងសតវត្សរ៍ទី ១២ នៃពុទ្ធសករាជ គឺ ព. ស. ១.១៥០ (តែន័យខ្លះថាក្នុងទី ៩ និងទី ១០) ។ លទ្ធិអាចារ្យវាទ នេះ បានចំរើនរុងរឿងយ៉ាងខ្លាំង ក្នុងសម័យមហានគរ

---

(១) យោបល់ខ្ញុំថា: សាសនាព្រាហ្មណ៍ផ្សាយចូលមកមុន គ- ស- ទៅទៀត ។

តាំងពីសតវត្សរ៍ទី ១៤ ដល់ទី ១៨ ដូចមានបុរាណវត្ថុនៅនគរវត្តជាតឹកតាងស្រាប់ ។

លើកទី ៣ លទ្ធិថេរវាទ ឬ ហីនយាន របស់លង្កាវង្សបានផ្សាយចូលមកក្នុងសតវត្សរ៍ទី ១៨ ដោយបានព្រះត្រៃបិដករបស់លង្កាដ៏ជារបស់ត្រឹមត្រូវមកផង ។ លទ្ធិនេះបានតាំងនៅស្ថិតស្ថេររហូតមកដល់សព្វថ្ងៃនេះសូម្បីរៀវរាយជាច្រើនលើកច្រើនគ្រា ក៏មិនរលាយរលុបទៅឡើយ ហើយដល់មកចុងសតវត្សរ៍ទី ២៥ (ព. ស. (២៤៧៤) បានលើកសង្គាយនាទៀត ឲ្យឈ្មោះថា “ ឧត្តមសង្គីតិ ” ។

ព្រះពុទ្ធសាសនា ក៏បានរុងរឿងតាំងពីលើកឧត្តម-សង្គីតិនោះ រហូតដល់សព្វថ្ងៃនេះ ។

ភិក្ខុ ម. ប៊ូច្រី សិស្សចាស់សាលាបាលីជាន់ខ្ពស់

* * *

## ប្រវត្តិក្មេងកំព្រា (ត)

ព្រួញមួយហើពីចម្ងាយមកដោតចំក្បាលពលសាហាវនេះបណ្ដាលឲ្យសត្វកំណាចរមួលខ្លួនធ្លាក់ពីលើ-ដើមឈើធំ មកដល់ដីមួយរំពេចមួយសន្ទុះក្រោយមក សត្វនោះក៏ស្លាប់បាត់បង់ជីវិតទៅ ។

ក្នុងពេលជាបន្ទាន់នេះក៏មានសំឡេងមួយជ្រៀតចេញពីគុម្ពោតមួយជុំជិត បង្គាប់ដល់អ្នករង គ្រោះថា “ មេច! នៅដល់ណាទៀត មិនចុះមកដីក្មាមមក ”

សំណាងនឹកឆ្ងល់ជាខ្លាំង ដោយសំឡេងនោះជាសំឡេងនារីមួយរូបដែលអ្នកធ្លាប់ស្គាល់ច្បាស់, តែអ្នកនៅមិនទាន់ទុកចិត្តនៅឡើយ, កាលបើអ្នកបានសំរូតខ្លួនចុះមកដល់ដីហើយ សំឡេងសើចក្អាកក្អាយដែល-លាយឡំនឹងសំឡេងនារីម្នាក់ផងក៏បានផុសចេញពីគុម្ពោតព្រៃនោះម្ដងទៀត តែម្ដងនេះគេឃើញទាំងរូបអ្នកជួយសង្គ្រោះចេញមកខាងក្រៅផង ។

នារីម្នាក់ ដែលមានធោមធេតធាយ មានសំលៀកបំពាក់ជារបៀបបុរស រត់សំដៅមករកអ្នក ហើយឱបចង្កេះអ្នកជាប់ ពោលដោយការរអាក់រអួលថា “ ខ្ញុំស្មានថា បងបាត់បង់ជីវិតទៅហើយ ”

“ បងមិនស្លាប់ទេ បងរស់នៅដោយសារគុណព្រះរតនត្រ័យ ” សំណាងឆ្លើយហើយសួរវិញថា “ហេតុម្ដេចក៏អូនឯងមកនៅក្នុងទីនេះ ”

“ ដោយហេតុតែលោកឪពុកមកតាមរកបង, ហើយខ្ញុំត្រូវខ្យល់ព្យុះក្នុងចំណាក់ក្នុងទឹក បានរស់ជីវិតដោយបង . . . ជួយសង្គ្រោះ ” ហើយក៏លើកដៃចង្អុលទៅគាត់ . . . ” ជីវិតខ្ញុំបានរស់នៅជាសុខក្នុងក្រុមនេះអស់វេលា ៦ ខែមកហើយខ្ញុំបានដាក់ធុរៈក្នុងចិត្តថា ដរាបណាតែខ្ញុំមិនបានទទួលដំណឹងពីបង ខ្ញុំនឹងមិនត្រឡប់វិញដោយដាច់ខាត ” អ្នកទាំងពីរនិយាយបណ្ដើរបង្ហូរទឹកភ្នែកបណ្ដើរ ដែលជាហេតុនាំឲ្យនាយ . . . ច្រណែនក្នុងចិត្តខ្លះៗ នេះជាធម្មតានៃបុរសទូទៅ កាលបើអ្នកមានចិត្តកួចកាន់លើស្ត្រីណាហើយ ។ ចំណែកសំណាងវិញ នឹកសរសើរនឹងរីករាយក្នុងចិត្តយ៉ាងក្រៃលែង

ដោយសង្ឃឹមថា អ្នកជួយសង្គ្រោះប្អូនរបស់ខ្លួននេះក៏ស័ក្តិសមគ្នាណាស់ដែរ អ្នកសង្ឃឹមថាទាំងពីរអ្នកនាក់នេះ សមជាគូនឹងគ្នាទៅអនាគត ហើយនឹងផ្សំផ្គុំគ្នា ពេលដែលបានត្រឡប់ទៅកាន់ស្រុកកំណើតវិញ ។

## ការយល់ផ្ទុយតែរៀងខ្លួន

ជម្រំខ្ទមមួយតាំងនៅចំកណ្តាលកោះ ដែលមានដើមឈើធំៗ ជាច្រើនដុះជាម្ចប់, ក្នុងជំរំនេះមានមនុស្ស៣នាក់អង្គុយរម្មតមួយ ។

គេបានដឹងច្បាស់ហើយថា មនុស្សទាំង៣នាក់នេះគឺនាយវិន្ទោ, សំណាងនិងនាងនារី តែសុទ្ធសឹងមានគំនិតខុសគ្នាទាំងអស់ចំពោះរឿងស្នេហា ។ ចំពោះនាយវិន្ទោពីដើមអ្នកពុំមានសេចក្តីប្រតិព័ទ្ធលើនារីទេ តែពេលក្រោយមក នាយបានដោតទឹកចិត្តជាប់លើលំអរបស់នារីទៅហើយ ។ នាយមិនអាចនឹងដកទឹកចិត្តវិញបានផង ។ ចំណែកនាងនារីវិញ ភ្លេចសេចក្តីស្នេហាខ្លះដែលនាងបានសន្យាពីមុនមកដែរ នាងអរកើកពយហាក់ដូចជានាងនឹងត្រូវសម្រេចបំណងក្នុងពេលឆាប់ៗនេះ ហើយនាងសង្ឃឹមថាជាប់ជាសំណាងនឹងទទួលយកនាងជាគូប្រចាំជីវិតមិនខាន ។ ចុះសំណាងវិញមិនដូចគំនិតដែលនារីគិតនោះទេ អ្នកមិនមានអ្វី សូម្បីបន្តិចបន្តួចឡើយដែលជាប់ទាក់ទងនឹងសេចក្តីស្នេហា — លើរូបនារី អ្នកស្ម័គ្រចិត្តស្រឡាញ់នាងទុកជាប្អូនបង្កើតរបស់អ្នកទៅវិញ ហើយអ្នកនឹងជួយលើកឋានៈនាងឲ្យខ្ពស់ទៅអនាគតដោយផ្សំផ្គុំឲ្យជាគូនឹងនាយវិន្ទោ ។ នេះហើយជាគំនិតផ្ទុយនៃជនបីរូបដែលយើងត្រូវចាំមើល — ផលទៅអនាគត ។

តាំងពីសំណាងចូលមកដល់ជម្រំនាយវិន្ទោវេលាណា សភាពនៃការស្ងប់ស្ងាត់នឹងក្រៀមក្រំក៏ចេះតែកើត — ឡើងជាលំដាប់ដោយនាយវិន្ទោប្រាសចាកការរីករាយ — ហើយ ចុះសភាពបែបនេះមកពីអ្វី ? កាលដើមនារីនាងបានចរចារជាមួយនឹងនាយវិន្ទោ គ្រប់ពេលវេលាដែលជាសំដីលាយឡំដោយការស្នេហា តែថាតាំងពីសំណាងបានមកដល់ភ្លាមនាងក៏ហាក់ដូចជាភ្លេចនាយ — វិន្ទោទៅហើយ នាងស្ម័គ្រចិត្តនិយាយលេងតែជាមួយនឹងសំណាងប៉ុណ្ណោះ ហើយនាងសប្បាយចិត្តក្នុងពេលដែលនាងដាក់បញ្ហាស្នេហា ទៅ សំណាងខ្លះផង, ចំពោះសំណាងវិញមិនមានចាប់ភ្លឹកដល់ទឹកចិត្តរបស់នាងឡើយ អ្នកចាំបានតែទឹកមុខដ៏មូលក្រឡង់នៃនារីធន — សារឿនតែម្យ៉ាង ។

សំណាងនឿងឆ្ងល់យ៉ាងខ្លាំងដោយឃើញនាយវិន្ទោមិនសូវទទួលកែមុខរកខ្លួន ការឆ្ងល់នេះនាំឲ្យអ្នកចំបែងក្នុងចិត្តយ៉ាងក្រៃលែង ដោយពុំដឹងហេតុអ្វី តែងព្យាយាមសួរនាយចំពោះអាការៈបែបនោះ តែពុំបានផលអ្វីឡើយក្រៅពាក្យថា “ ពុំជាកង្វល់ ” មួយម៉ាត់ប៉ុណ្ណោះ

ករណីយរបស់នាយវិន្ទោក៏ចេះតែកើនឡើងជាពលថ្ងៃ ។ សមាជិករបស់អ្នកទាំងប៉ុន្មាននាក់ចំហុកហាត់យ៉ាងមុងម៉ាត់ ការរស់នៅនៃក្រុមនេះក៏ចេះតែចំរើនឡើង

តទៅទំព័រទី ៤៨





ពិធីបើកពិពណ៌អន្តរជាតិក្រោមព្រះរាជាធិបតីភាព ដែលកាំជ្រួចកំពុងតែបញ្ចេញ

ផ្ចិតពលផល់ពិធីនេះ



កញ្ញា ទាំងបីរូបត្រូវមានកិត្តិយសខ្ពស់ជាងគេ ក្នុងពេលដែលចប់ការប្រឡងប្រជែងនោះប្រទេសកម្ពុជា



ព្រះករុណាទ្រង់យាងទតនៅទីតាំងនៃជាតិភ្លៀង





រូបភាព ខាងលើ ទេវីសោភា សង្កាត់ លេខ១

ឯ. ឧ. ចៅក្រុង ព្រមនឹង លោកហេម-ចំរើន មានសោមនស្ស ក្នុងពេលជ្រើស រើសទេវីសោភា សង្កាត់លេខ ៣



ទេវីសោភានៅសង្កាត់លេខ ២ នេះដូចជានឹកបារម្ភដល់ពេលប្រឡងយក

កញ្ញាឯកកម្ពុជា



ទេវីសោភាសង្កាត់លេខ ៤ និងលេខ ៦




នេះជាព្រះរាជទស្សនកិច្ចនៅទីតាំងជាតិយៀកណាម



ឯ. ឧ. ចៅហ្វាយក្រុង និងលោក ហែម - ចំរើន លោកកំពុងតែទទួលសោមនស្សយ៉ាងក្រៃលែងជាមួយនឹងទេវីសោភាសម្គាល់លេខ ៧ ដែលលំអរបស់នាងបានទៀងសង្ឃឹមដល់ការប្រឡងប្រជែងយកឋានៈជាកញ្ញាឯកកម្ពុជា



នាងកញ្ញាកាន់ផ្កានៅដៃហើយញញឹមទទួលកិត្តិយស

អ្នកមើលពិធីប្រឡងប្រជែង   រូបនៃកញ្ញា កំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំងទាំងឥស្សរជននឹងជនសាមញ្ញដោយទឹកចិត្តដែលកំពុងតែរំភើបញាប់ញ័រយ៉ាងខ្លាំង ...





កញ្ញាឯកកម្ពុជាមានសំលៀកបំពាក់ប្លែក ដែលបំរុងទុកបំពាក់នាងដើម្បីទទួលកិត្តិយស ហើយនាងកំពុងតែញញឹមទទួលអំណរ

## ប្រវត្តិក្មេងកំព្រា (តពីទំព័រ៤០មក)

ជារាល់ថ្ងៃ ៗ សភាពនៃការចាប់ចងអ្នកនយោបាយក្នុងរដ្ឋក៏បានស្បើយទៅវិញ ៗ តើនាយវិន្នាប្រុងនឹងត្រឡប់មកកាន់សង្គមជាតិវិញទេ ? រឿងនេះមានន័យពីរយ៉ាង ព្រោះថាកាលមុនសំណាងចូលមកដល់ជម្រំនេះ នាយវិន្នាមានបំណងនឹងត្រឡប់មកកាន់ សង្គមជាតិវិញ នាយបានតាំងចាត់ក្រុមស៊ើបការសម្ងាត់មកអង្កេតយក - ការពីរដ្ឋាភិបាលអាណានិគមទៀតចំពោះដំណើរវិលត្រឡប់របស់នាយ ៗ តែថាដល់សំណាងចូលមកកាន់ជម្រំវេលាណា ការនឿយណាយក្នុងជីវិតក៏ចេះតែកើតមានឡើងដល់គំនិតរបស់នាយរាល់ថ្ងៃ, សព្វថ្ងៃនេះគេអាចដឹងបានថា នាយមិនមានបំណងនឹងរស់នៅក្នុងសង្គមជាតិតទៅមុខទៀតទេ បើសិនជាសេចក្ដីស្នេហារបស់អ្នកមិនបានសម្រេច ៗ

រឿងនេះនាយនឹងបន្ទោសអ្នកណាឬខឹងអ្នកណាខ្លះដែរ ! ទេ ! បើតាមពិតនាយមិនមានគុំចិត្តប្អាក់អន់លើរូបអ្នកណាមួយសោះឡើយ

នាយវិន្នា បានបណ្ដោយឲ្យការរស់នៅរបស់ខ្លួនប្រែ-កបដោយទុក្ខក្រៀមក្រំ ព្រោះនាយបានដឹងច្បាស់ហើយថា បញ្ហាដែលកើតឡើងថ្មី ៗ នេះជាបញ្ហាដែលនាំឲ្យនាយអស់សង្ឃឹម តែនាយគង់មានធូចិត្តខ្លះដោយពេលដោយខណៈដែរ ក្នុងពេលដែលនាយបានសរសេរខ្លួនចូលទៅជិត ដើម្បីស្ដាប់ការពិភាក្សារឿងសំណាងនឹងនាងនារី ហើយក៏បានដឹងច្បាស់ថា សំណាងមិនមានសេចក្ដីស្នេហាលើរូបនាងឡើយ តែចំណែកនារីវិញសរកាមទេពកំពុងតែចាក់ចុចចំលើបេះដូងនាងជារាល់ថ្ងៃ

ឱ ! មិត្តអ្នកអានជួយពិចារណាមើលចុះ ហេតុម្ដេចក៏ទេវតានៃសេចក្ដីស្នេហាមកបណ្ដាលឲ្យមនុស្ស — ទាំងបីនាក់នេះខ្វែងគំនិតគ្នាយ៉ាងនេះ

នាយវិន្នា, ដើម្បីបំពេញបំណងរបស់ខ្លួនលុះណាតែអ្នកបានឃ្លាតចេញពីនាងនារី, ម្ល៉ោះហើយចិត្តនាយដែលធ្លាប់តែអប់រំល្អពីដើមមកក៏ក្លាយទៅជាចិត្តវិប្បល្លាសមានព្យាបាទមកលាយឡំផង, តែការព្យាបាទនេះញែកទៅជាពីរចំណែកថា តើនាយនឹងប្រហារជីវិតខ្លួនឯងឬប្រហារជីវិតនាងនារី, បើខ្លួនលួចប្រហារជីវិតនាងនារីពេលទៅ ខ្លាចសំណាងគេមានសង្ស័យលើខ្លួនព្រោះសំណាងគេគ្មានបំណងអ្វីនឹងធ្វើអាក្រក់ដល់ខ្លួនឡើយ ហើយគេក៏គ្មានបំណងអ្វីនឹងបំពារបំពានលើសេចក្ដីស្នេ-ហារបស់ខ្លួនដែរ, បើសិនជាសម្លាប់ខ្លួនឯងវិញនាំឲ្យខ្មាសដល់សហការីទាំងអស់ថាជាមនុស្សខ្វះសេចក្ដីក្លា — ហាន ៗ ម្ល៉ោះហើយគំនិតរបស់នាយតែងតែសាំញ៉ាំស្មុគស្មាញគ្រប់ពេលវេលា ជួនកាលអ្នកចង់តែប្រហារជីវិតទាំងបីនាក់ឲ្យស្លាប់រួមគ្នាតែម្ដង តែទឹកចិត្តដ៏ល្អដែលអ្នកធ្លាប់បំពេញពីមុនមក បានមកឃាត់ហាមក្លាមមួយរំពេច ៗ

រវាងជាមួយអាទិត្យក្រោយមក នៅក្នុងជម្រំកណ្ដាលកោះមានភ្លៀងធ្លាក់ជោគជាំយ៉ាងខ្លាំង មនុស្ស

ម្នាតាំងឡាយចូលកាន់ជម្រំរៀងខ្លួនដើម្បីនិទ្រា ។ តែគេគង់ស្មានបានថា ជនអ្នកចូលនិទ្រាទាំងនេះ គង់មានខ្លះមិនទាន់លក់នៅឡើយ ចំពោះជនណាដែលមានការត្រិះរិះច្រើន ។

រាត្រីនេះស្ងាត់ណាស់ ស្ងាត់ខុសប្រក្រតី ដែលអ្នកផងទាំងពួងគេចាំបានថាជារាត្រីប្រកបដោយការភិតភ័យច្រើន តែទោះបីដូចម្ដេចក៏ដោយ អ្នកដែលចូលនិទ្រារួចហើយនោះក៏ចេះតែលក់ស៊ប់ទៅជាលំដាប់ មិនមានអ្នកណាមួយនឹកភ្ញាក់ដល់ហេតុអ្វីមួយឡើយ ។

ជម្រំមួយដែលនៅជ្រុងខាងលិចជាប់នឹងជើងភ្នំ ហើយឃ្លាតពីជម្រំដទៃប្រហែល ១០០ម ក្នុងជម្រំនេះមានពន្លឺចង្កៀងតូចមួយឲ្យពន្លឺព្រិមៗ ដែលជាសញ្ញាឲ្យដឹងថា អ្នកម្ចាស់ជម្រំនិទ្រាលក់ស៊ប់ហើយ ។

តែគួរឲ្យឆ្ងល់ណាស់ នៅខាងក្រោយជម្រំនេះគេឃើញស្រមោលខ្មៅមួយអណ្ដែតទៅបន្តិចម្ដងៗ ដែលមានទាំងស្បូវមែកឈើបន្តិចៗ ហាក់ដូចជាសត្វដើរៗ ស្បូវបែបនេះពុំមាននរណាមួយដឹងឮសោះឡើយ ក្រៅពីនារីដែលកំពុងតែមានអារម្មណ៍ បណ្ដែតចេញតែឯកឯង ហើយគេងមិនលក់ ។ ឮភ្លាមនាងក៏ស្ទុះតាមមួយរំពេច ដើម្បីពិនិត្យហេតុនោះដោយការចាប់រហ័សទន់វាងវៃរបស់នាង ក៏បណ្ដាលឲ្យសម្លឹងឃើញច្បាស់ទៅវត្ថុខ្មៅដែលកំពុងតែថយចេញពាក់ជម្រំនេះ, នាងដើរសន្សឹមៗ បន្តិចៗ ដោយហាក់ខ្លាចមុខខ្លាចក្រោយ ដើម្បីនឹងតាមមើលហេតុការណ៍នោះ ។ ពេលនេះនាងបានដឹងច្បាស់ហើយថា ស្រមោលខ្មៅនោះគឺនាយវិទ្ធោកំពុងដកខ្លួនថយចេញពីជម្រំទៅកាន់ព្រៃជ្រៅតែពុំដឹងជាហេតុគេធ្វើដូចម្ដេចឡើយ ។ ដើម្បីបញ្ជាក់នូវហេតុការណ៍នេះត្រូវនាងធ្វើដំណើរលួចតាមក្រោយគេជានិច្ច

( នៅមានត )

★ ★ ★

# បុណ្ណកុមារ

(ត)

បុណ្ណមាណពអង្គុយគិតនៅលើជើងម៉ាប្ញតែម្នាក់ឯង ប្រយោគចុងបំផុតដែលនាងកុសលាពោលចំពោះគេនោះ ធ្វើឲ្យគេគិតអស់ពេលដ៏យូរ ។ ចួនកាលដូចជាភ័យ ចួនកាលដូចជាអរ ។ បុណ្ណមាណពដូចជាមានសេចក្ដីស្នេហាជាប់ចិត្តកើតឡើងហើយ ។ កំពុងតែត្រូវការខុការនៃសេចក្ដីស្នេហាចូលមកប្រយុទ្ធយ៉ាងខ្លាំងនៃតទឹកចិត្ត —

របស់គេក៏នៅតែនឹករលឹកចំពោះសេចក្ដីកតញ្ញូកតវេទីជានិច្ច ទើបបុណ្ណមាណពទំកំចាត់នូវការនឹកគិតក្នុងរឿងស្នេហាឲ្យរសាយរលាយចេញពីទឹកចិត្តតែក៏ជាការកំ–ចាត់ដ៏លំបាកសែនលំបាក ។ បុណ្ណមាណពចេះតែស្រមៃឃើញនូវរូបទ្រង់មុខដ៏ផូរផង់នៃនាងកុសលាដែលត្រូវពន្លឺព្រះចន្ទសាចជះមកត្រូវ ហើយធ្វើឲ្យលំអរពិតតែលេចឡើងទៀតជាប់នៅក្នុងមនោភាពជានិច្ច សូម្បីតែក្នុងពេលដេកលក់ក៏នៅតែយល់សប្ដិឃើញទៀត ។

លុះព្រឹកព្រលឹមឡើង ព្រះលានមុខព្រះរាជវាំងក៏ណែនណាន់តាន់តាប់ទៅដោយប្រជាជន ព្រោះជាថ្ងៃដ៏សំខាន់បំផុត ដោយការប្រឡងប្រជែងជ្រើសរើសរកបុរសក្លាហាន ដែលបានតស៊ូមានជ័យមកពីការប្រឡងជ្រើសរើសក្នុង ៣ ថ្ងៃមុនតាំងអស់ ។

នៅក្នុងព្រះបារំពិធីការ ព្រះបាទទេវរាជព្រះរាជានៃទេវគិរីនគរទ្រង់ស្ដេចប្រថាប់ព្រមដោយព្រះមហេសី–ពទ្ធពទ្ធដោយសេនាអាមាត្យមុខមន្ត្រីតូចធំដែលអង្គុយ–រៀបរៀង ៗ គ្នាតាមតំណែងយសស័ក្ដិនៃខ្លួន ។ លោកមេទ័ពទសយុទ្ធអង្គុយនៅជិតទីប្រថាប់នៃព្រះរាជា ហើយនាងកុសលាក៏អង្គុយបន្ទាប់ក្រោយជិតឪពុកនាង ។

ការតស៊ូគ្នាវគ្គដំបូង ៗ ក៏បានចាប់ផ្ដើមឡើងហើយ ព្រះបាទទេវរាជទ្រង់ទះព្រះហស្ដដោយការពេញព្រះទ័យដែលទ្រង់បានទតឃើញបុរសដែលមានថ្វីដៃពូកែចំនួនជាច្រើន មកអាសាស្មគ្រជាទាហានក្នុងកងទ័ព ។

“ បានការហើយលោកមេទ័ព ” ទ្រង់ត្រាស់នឹងលោកមេទ័ព “ ប្រឡងជ្រើសរើសហើយនឹងចាត់ការឲ្យហាត់អាវុធ ៣ ខែទៀត ហើយនឹងផ្ដើមចាត់ក្បួនកងទ័ពលើកទៅវាយកល្យាណីបុរៈបានក្លាយ បើទាហានរបស់យើងមានសេចក្ដីក្លាហានយ៉ាងនេះ កល្យាណីបុរៈមុខជានឹងតទល់ជាមួយនឹងយើងមិនដល់មួយខែទេ–មើលទៅ . . . ”

កល្យាណីបុរៈ ដែលព្រះរាជាមានព្រះបន្ទូលដល់នេះ ជានគរមួយទៀតតាំងនៅទិសខាងលិចនៃទេវគិរីនគរ ជានគរមួយដែលមានឯករាជរឹងប៉ឹងមិនព្រមចំណុះទេវគិរីនគរ ជានគរដែលរឹងប៉ឹងក្នុងការសង្គ្រាមក្នុងដងស្ទឹងគោតាវក្នុងសម័យនោះ

“ ជាការពិតក្រាបទូល ” លោកមេទ័ពក្រាបទូល “ ទាហានយើងមានកម្លាំងសម្បូរ ល្មមនឹងវាយយក–កល្យាណីបុរៈនគរឲ្យបាន ”

“ មែនលោកមេទ័ព . . . អើ ! ចុះអ្នកណានោះស្លៀកពាក់ក្រហមដំណើរទំនងអង់អាច ? ” ទ្រង់ត្រាស់សួរព្រមទាំងលើកព្រះហស្ដចង្អុលទៅរកបុរសម្នាក់ក្នុងបណ្ដាបុរសច្រើនរូប ដែលកំពុងតែដើរចូលមកថ្វាយបង្គំនៅមុខព្រះបាទ ។

“ ឈ្មោះបុណ្ណៈ កូនចិញ្ចឹមរបស់ទូលព្រះបង្គំ ” លោកមេទ័ពក្រាបទូល

“ អើ ! មានកូនចិញ្ចឹមផង ខ្ញុំមិនដែលដឹង ហើយមានថ្វីដៃដល់ទៅបានទទួលនូវការជ្រើសរើសឲ្យចូល –

មកដណ្ដើមតំណែងជានាយទាហានទឹងគេបានក៏ពប់ជាជាបុណ្យក៏សនាណាស់ហើយ កូនចិញ្ចឹមលោកដូចជាមិនអន់ប៉ុន្មានទេណា ទ៊ុះ... ទ៊ុះ... ឈ្នះម្នាក់ទៅហើយ " ទ្រង់ត្រាស់ក្នុងកាលដែលទ្រង់បានទតឃើញបុណ្ណមាណពតស៊ូនឹងបុរសម្នាក់ទៀត នាកណ្ដាលសម្រែងហ៊ោកញ្ជ្រៀវរបស់អ្នកមើលទាំងឡាយ ។

មេប្រយោគប្រកាសគឹកកងថា " បុណ្ណមាណពបានតំណែងជាមេក្រុមទាហានសេះហើយមានបំណងទឹងដណ្ដើមយកតំណែងជាមេកងទ័ពសេះទៀត សូមឲ្យមេកងទ័ពសេះដែលដណ្ដើមតំណែងបានកាលពីថ្ងៃម្សិលមិញចេញមក ... "

បុរសម្នាក់ទៀតក៏ដើរចេញមក ។ ក្រោយពីការថ្វាយបង្គំព្រះរាជារួចហើយ ក៏គុណជាវគ្គារ ៨ ចូលមករកបុណ្ណមាណពភ្លាម ។

" កូនចិញ្ចឹមលោកមានប៉ូដែលល្អណាស់ " ព្រះរាជាមានព្រះបន្ទូលនឹងលោកមេទ័ពទសយុទ្ធ " ទ៊ុះ... ទ៊ុះ ហ៊្ន... ឃើញទេ ! ម្នាក់ទៀតរបួសជាវពីដៃទៅហើយលោកមេទ័ព ឃើញទេ ! កូនលោកបានជាប់ជាមេកងទាហានសេះទៅហើយ ។

លោកមេទ័ពទសយុទ្ធញញឹមបែរទៅមើលនាងកុសលាដែលអង្គុយនៅក្រោយខ្នងកំពុងតែទះដៃដោយទឹក–មុខញញឹមញញែម ។

ខណៈនោះ អ្នកមើលទាំងឡាយក៏ស្ងប់ស្ងៀមស្ងួចជាបានណាត់គ្នាទុកក្នុងកាលដែលមេប្រយោគប្រ–កាសថា បុណ្ណមាណពដណ្ដើមយកតំណែងមេកងទា–ហានសេះបានហើយនោះមានបំណងទឹងដណ្ដើមយកតំណែងជាមេបញ្ជាការកងទ័ពសេះទៀត ។ លុះប្រកាសចប់ភ្លាម អ្នកមើលទាំងឡាយកស្រែកហ៊ោឡើងទៀតដោយសេចក្ដីត្រេកអរ ហើយឲ្យពរជ័យដល់បុណ្ណ–មាណពដែលមានសេចក្ដីក្លាហាន ហ៊ានសុំតស៊ូប្រឡងជាមួយនឹងវិស្សុកៈ មេបញ្ជាការកងទ័ពសេះរូបធំធំបងដែលមានឈ្មោះល្បីល្បាញ... ។

វិស្សុកៈ បុរសដែលបានកាត់ស្មាទមកពីមុខមកមិនខុស ក៏បានកាន់លំពែងនៅដៃទាំងពីរចេញមកថ្វាយបង្គំព្រះរាជាដោយដំណើរដ៏អង់អាច ។ គេតែងខ្លួនដោយសម្លៀកបំពាក់ពណ៌ខៀវ ។ សម្រែងស្រែកហ៊ោនៃពួកអ្នកកាន់ជើងខាងវិស្សុកៈក៏លាន់ឮឡើង ។ បុណ្ណមាណពហុចដាវឲ្យមេប្រយោគ ហើយរើសយកលំពែង–ដែលខ្លួនពេញចិត្ត ហើយក៏ចូលមកថ្វាយបង្គំព្រះរាជាដែរ តែលុះងើបមុខឡើង ភ្នែកទាំងពីរក៏បានឃើញផ្លូវមុខរបស់នាងកុសលា នារីដែលខ្លួនសង្ឃឹម ញញឹមដាក់ស្រស់បំព្រង ហើយក្នុងខណៈនោះបុប្ផជាតិនានាក៏ត្រូវបាចសាចចេញមកពីពួកស្រី ។ នៅលើព្រះបាក់ជ័យអណ្ដែតចេញតម្រង់ទៅរកបុណ្ណមាណពដូចគ្រាប់ភ្លៀងបុណ្ណមាណពក្រាកឈរឡើងលុះឃើញផ្កាអសោកមួយដ៏ធំដែលហើរចេញមកពីដៃនៃនាងកុសលា បុណ្ណ-មាណពក៏លោតឡើងហើយយកដៃទាំងពីរចាំទទួលចាប់ទុកយ៉ាងរហ័សត្រង់កណ្ដាលចំណោមនៃសម្រែង

ឲ្យពរជ័យនិងសម្តែងទះដៃ ។

វីរស្រុកៈបានឃើញយ៉ាងជាក់ច្បាស់ៗ គេខាំធ្មេញណែនដែលជាអាការៈនៃការអាឃាតព្យាបាទ ។ លុះមេប្រយោគបក់កន្ទុយក្រអើកដែលជាសញ្ញានៃការចូលប្រយុទ្ធគ្នា វីរស្រុកៈស្ទុះចូលទៅរកបុណ្ណមាណពភ្លាម ហើយលើកលំពែងផ្ទួនព្រមទាំងនិយាយតិច ៗ ល្មមតែឮពីរនាក់ថា

“អាកូនអ្នកសូមទាន! អាឯងកុំមានជីវិតរួមនៅលើផែនដីជាមួយនឹងអញឡើយ ”

លុះបានឮដូច្នោះ បុណ្ណមាណពក៏ខឹងយ៉ាងខ្លាំងតែមិនបានឆ្លើយថាអ្វីចេះតែខំកាត់កងទប់ការរុកចូលរបស់វីរស្រុកៈដោយប្រុងប្រយ័ត្ន ។

លំពែងដែលប្រើក្នុងការប្រឡងថ្ងៃនោះធ្វើពីឈើមិនមានមុខស្រួចមុតដូចលំពែងដែកក៏ពិតមែន តែប្រសិនៈបើជាភ្លាត់ស្នៀតឲ្យគេចាក់ត្រូវក៏ឈឺខ្លាំងណាស់ដែរ រហូតដល់ជួនកាលគ្រាំសាច់បាក់ឆ្អឹងឬស្លាប់ក៏មាន ។

បុណ្ណមាណពដឹងថា វីរស្រុកៈមានកម្លាំងខ្លាំងដូចដំរីសារ ពួយលំពែងមកម្តងៗ មានទម្ងន់កម្លាំងយ៉ាងខ្លាំង ហើយមានសន្ទុះយ៉ាងរហ័ស តែក៏ចេះតែខំព្យាយាមកាត់ពឹងពា ហើយផ្ទួនថយបញ្ចោតបណ្តោយឲ្យវីរស្រុកៈដេញឲ្យទាល់តែហត់អស់កម្លាំង ទើបរុកចូលទៅវិញខ្លះៗ ។

ឯវីរស្រុកៈនោះមានទឹកចិត្តពេញទៅដោយការគំនុំអាឃាតព្យាបាទ ក៏គិតតែពីរុកចូលទៅមុខជានិច្ច ទាល់តែភ្លេចគិតដល់ស្នៀតក្នុងការប្រយុទ្ធ ព្រោះមានបំណងចង់ចាក់បុណ្ណមាណពសម្លាប់ក្នុងពេលឆាប់ៗនោះ ទើបមិនបានជាគិតប្រមាណដល់កម្លាំងខ្លួន គឺមានប៉ុន្មានក៏ខំប្រើទៅទាំងអស់ ។

ការបញ្ចោតធ្វើជាថយហើយគ្រាន់តែការពារខ្លួននៃបុណ្ណមាណពនោះ បានធ្វើឲ្យអ្នកមើលទាំងឡាយរួមទាំងព្រះរាជាផងយល់ថា វីរស្រុកៈដែលជាអ្នករុកដេញនោះនឹងមានជ័យជំនះយ៉ាងពិតប្រាកដ ព្រោះបុណ្ណមាណពមានថ្វីដៃគ្រាន់តែការពារ ហើយថយការពារខ្លួន — ប៉ុណ្ណោះ ៗ មានតែលោកមេទ័ពទសយុទ្ធមួយទេដែលលោកធ្លាប់ចេះស្គាល់ជំនាញក្នុងពិជ័គុណអាវុធនេះលោកយល់យ៉ាងជាក់ច្បាស់ថា នឹងមិនប៉ុន្មាននាទីទៀតទេ ជ័យជំនះនឹងត្រូវធ្លាក់ទៅលើកូនរបស់គាត់ជាមិនខាន ។

ឯនាងកុសលាមានទឹកមុខសស្លាំង ព្រោះនាងឃើញទេវបុត្រជាទីស្នេហារបស់នាងចេះតែថយក្រោយ — ក្រោតដូចជាគ្មានសង្ឃឹមសោះជាទីបំផុតនាងយកដៃបិទភ្នែកលែងចង់មើល ព្រោះនាងមិនចង់ឃើញការបរាជ័យរបស់បុរសដែលនាងហៅថា “ បង ” នោះសោះឡើយ

សម្លេងហោកញ្ជ្រៀវនៃពួកមនុស្សដែលកាន់ជើងខាងវីរស្រុកៈក៏ចេះតែលាន់ឮឡើងមិនដាច់សូរ ឯពួកដែលកាន់ជើងខាងបុណ្ណមាណពនោះក៏នៅសម្ងំស្ងាត់ស្រៀប បេះដូងញ័ររន្ធុក ៗ តែរៀង ៗ ខ្លួន ។

បុណ្ណមាណពខំកាត់បិទការពារខ្លួនមិនមានភ្លេសប្រហែស ហើយចេះតែខំល្បងបញ្ចោតវីរស្រុកៈដោយទំនងដែលក្លែងធ្វើជាគេសគាំសក្រោតក្រោត ដើម្បីនឹង

ឲ្យវិស្សុកៈខំសម្រុកចូលបន្ថែមឲ្យពាល់តែអស់កម្លាំងមែនខែន តែលុះសង្កេតឃើញថា លំពែងដែលវិស្សុកៈពួយមកនោះមានកម្លាំងខ្សោយចុះ ហើយការរុកសម្រុក–ចូលក៏ដូចជាយឺតជាងមុនបន្តិចទៅហើយនោះ ពុណ្ណមា-ណពក៏ឈប់ថយភ្លាម ហើយពួយលំពែងទៅរកវិស្សុកៈវិញរហាស់ដូចជាអណ្ដាតពស់ ឯវិស្សុកៈក៏មិនទាន់ជាបានប្រុងស្មៀតគាត់នៅឡើយ ព្រោះរវល់តែរុកសម្រុកដេញគេ ក៏ត្រូវទងលំពែងរបស់ពុណ្ណមាណពត្រង់ដើមទ្រូងយ៉ាងខ្លាំងដួលស្រូសទាំងដំហារ ។

សម្លេងស្រែកហ៊ោកញ្ជ្រៀវក៏ស្ងប់ស្ងាត់ភ្លាម អ្នកមើលទាំងឡាយនាំគ្នាក្រោកឈរឡើងមើលដោយសេចក្ដីស្ញុតរន្ធត់ ព្រះរាជាទ្រង់បើកព្រះនេត្រាយ៉ាងធំដោយការប្លែកព្រះទ័យ លោកមេទ័ពទសយុទ្ធញញឹមឆាកទៅរកនាងកុសលាកូនក្រមុំរបស់លោក លុះឃើញផ្ទៃមុខនាងក្រហមដោយសេចក្ដីបីតិ លោកក៏បែរទៅទីដទៃទៀត ហើយក៏បង្កប់នូវការញញឹមនោះទៅក្នុងពុកមាត់ស្រមូមរបស់លោកទៅវិញទៅ ។

ឯវិស្សុកៈ កាលបើត្រូវលំពែងដួលដូច្នោះ ក៏ខឹងអៀនខ្មាសជាខ្លាំង ខំញេញណែនក្រោកឈរឡើងវិញ ហើយប្រកាសថា

« បពិត្រព្រះករុណាថ្លៃវិសេស ព្រមទាំងលោកអ្នកមើលទាំងឡាយ ការដែលទូលព្រះបង្គំ–ខ្ញុំបាទដួល–នេះ ក៏ដួលដោយគប់ចនទេ សូម្បីកុំគាល់វិនិច្ឆ័យគាត់សេចក្ដីថា ទូលព្រះបង្គំ–ខ្ញុំបាទចាញ់ ប្រសិនបើព្រះរាជាទ្រង់នឹងអនុញ្ញាតឲ្យចូលប្រយុទ្ធគ្នាម្ដងទៀត ទូលព្រះបង្គំ–ខ្ញុំបាទនឹងសំដែងឲ្យឃើញថា គូប្រយុទ្ធរបស់ទូលព្រះបង្គំ - ខ្ញុំបាទនេះគ្មានថ្វីដៃពូកែអ្វីសោះឡើយ ។

សម្លេងស្រែកហ៊ោបំអកឡូកឡំក៏ឮឡើងពីអ្នកមើលទាំងឡាយ ដែលគាំទ្រខាងពុណ្ណមាណព ជាពាក្យឆ្ងួយនឹងពាក្យពោលរបស់វិស្សុកៈ តែព្រះរាជាទ្រង់ចង់ទតថ្វីដៃរបស់ពុណ្ណមាណពតទៅទៀត ទើបទ្រង់ត្រាស់សួរបញ្ជាក់ពុណ្ណមាណពដោយព្រះសូរសៀងថា

« មើ៉ល អ្នកប្រយុទ្ធពាក់អាវក្រហម ខ្ញុំសូមឲ្យឯងកាត់សេចក្ដីខ្លួនឯងថា នឹងព្រមឲ្យវិស្សុកៈដំណាស់នឹងរបៀបបែបផែនដែលបានតាំងទុកមករួចហើយដែរឬអ្វី »

« កុំព្រម ! កុំព្រម ! » សម្លេងស្រែកប្រាប់នៃពួកមនុស្សដែលគាំទ្រ « វិស្សុកៈចាញ់ហើយ ! វិស្សុកៈចាញ់ហើយ ! »

« ទូលព្រះបង្គំពេញចិត្តនឹងប្រយុទ្ធម្ដងទៀត » ពុណ្ណមាណពក្រាបទូល « ប្រសិនបើគេចង់ »

លុះផុតពាក្យពុណ្ណមាណព សម្លេងស្រែកហ៊ោ-សរសើរ-ឲ្យពរដល់ពុណ្ណមាណពដែលមានចិត្តក្លាហានក៏លាន់ឮឡើងទៀត ។ វិស្សុកៈមិនបង្អង់ឲ្យយឺតយូរសោះឡើយ គេក៏ស្ទុះចូលទៅប្រយុទ្ធម្ដងទៀតភ្លាម ។

ពុណ្ណមាណពអែនខ្លួនគេចចុះឡើងនឹងចុងលំពែងរបស់វិស្សុកៈយ៉ាងរហាស់ កម្លាំងដែលវិស្សុកៈខំពួយលំពែងទៅនោះ ក៏ធ្វើឲ្យកាយរបស់វិស្សុកៈទ្រេតទោរ

ទៅមុខ បុណ្ណមាណពឃើញចន្លោះដូច្នោះ ក៏ពួយលំពែង ពេញទំហឹងចំថ្ពាល់របស់ស្រុក: ធ្វើឲ្យស្រុក:ដួលដេក សន្លប់លែងដឹងខ្លួនប្រាណ ។

បុណ្ណមាណពបានឈ្នះយ៉ាងដាច់ខាត ។ គេ ដូចជាទឹកព្រឺខ្លួនមិនតិច ក្នុងខណៈដែលលុតជង្គង់ទទួល គ្រឿងឥស្សរិយយសជាមេបញ្ជាការកងទ័ពទាហានសេះ ពីព្រះហស្តព្រះបាទទេវកដ នាកណ្តាលសម្រែកស្រែក ឲ្យពរជ័យនៃប្រជាជនយ៉ាងគឹកកង ។ បុណ្ណមាណព ចោលភ្នែកក្រឡេកមើលចំទៅនាងកុសលាដែលកំពុងតែ សម្លឹងខ្លួនព្រមទាំងញញឹមដ៏ស្រស់ប្រិមប្រិយ៍គួរស្រឡាញ់នោះ ដោយមិនចង់ព្រិចភ្នែក ។ ដោយសារទឹក មុខដ៏មានស្នេហ៍របស់នាងកុសលានេះ សេចក្តីហត់ នឿយក្នុងការប្រយុទ្ធ ក៏ដូចជាសាបរលាបហើររលាយ ចេញអស់ពីកាយរបស់បុណ្ណមាណព ។

ហើយក្នុងយប់នោះឯង លោកមេទ័ពទសយុទ្ធ នឹងលោកស្រី ក៏បានហៅបុណ្ណមាណពនឹងនាងកុសលា ទៅនិយាយលេងពីនេះខ្លះនោះខ្លះ ទីបំផុតក៏និយាយថា

“ បុណ្ណ: ! ! ឪពុកដឹងច្បាស់ថា ឯងពេញចិត្ត នឹងកុសលាណាស់ តែដោយសារឯងជាមនុស្សថ្នាក់ បន្ទាបខ្លួន ទើបឯងខំព្យាយាមអត់សង្កត់ចិត្ត ព្រោះខ្លាច ក្រែងថោកទាបដល់វង្សត្រកូល នឹងកើតមានការគរហា- និន្ទាដល់ឪពុក-ម្តាយ តែណ្ហើយចុះបុណ្ណ: ឪពុក-ម្តាយ នឹងឲ្យរង្វាន់ដល់ឯងក្នុងឋានៈនៃឯងជាមនុស្សមានសម្មា- គារវ: នឹងខំឧស្សាហ៍ព្យាយាមកសាងខ្លួនឯងល្មមធ្វើជា ទីពឹងរបស់កុសលាបាន ឪពុក-ម្តាយនឹងលើកកុសលា ឲ្យឯងតើឯងថាម៉េច ? ”

បុណ្ណមាណពនឹកត្រេកអរជាទីបំផុត ទាល់តែមិន អាចនឹងពោលស្តីចេញមកបាន ។ គេចេះតែក្រាបទៅ ជិតលោកឪពុក-ម្តាយអស់ពេលដ៏យូរ ទីបំផុតទើប ពោលឡើងថា

“ ខ្ញុំបាទនឹងចងចាំនូវព្រះគុណដ៏ធ្ងន់នេះដរាបដល់ ថ្ងៃស្លាប់ ខ្ញុំបាទគ្រាន់តែជាក្មេងសូមទានម្នាក់ មិន សម-មិនគួរនឹង . . . . ”

“ ឈប់ ! ឈប់ ! កុំនិយាយអញ្ចឹងបុណ្ណ: ! លោកមេទ័ពរាំងហាម ” ឯងមិនមែនក្មេងអ្នកសូមទាន ទេ ឯងជាកូនរបស់ទសយុទ្ធ មេទ័ពដ៏ល្បីឈ្មោះនៃ ទេវនគរ ហើយឯងជាមេបញ្ជាការកងទ័ពទាហានសេះ ឪពុក-ម្តាយនឹងលើកកុសលាឲ្យឯង ចូលឯងខំបង្ហាត់ បង្រៀនទាហានរបស់យើងឲ្យបានពូកែឡើង រដូវប្រាំង ក្រោយនេះយើងនឹងលើកទ័ពទៅវាយកល្យាណីបុរៈនគរ លុះផុតពេលសឹកសង្គ្រាមហើយ ឪពុក-ម្តាយនឹងរៀប មង្គលឲ្យឯង បើនឹងគិតពីឥឡូវនេះទៅ យ៉ាងយូរ ៥ ខែទៀតប៉ុណ្ណោះ ”

ឯព្រះរាជាក៏ទ្រង់បានប្រទានសេះចម្បាំងរបស់ព្រះអង្គ មួយជារង្វាន់ឲ្យដល់បុណ្ណមាណព ជាសេះមានពណ៌ខ្មៅ មានកម្លាំង-ល្បឿននឹងការអត់ធន់ជាពិសេស សម្រាប់ ធ្វើជាសេះចេញច្បាំងទៅរដូវប្រាំងខាងមុខនេះ ។

មិនបាច់ពោលឡើយថា បុណ្ណមាណពមាន

សេចក្ដីសប្បាយរីករាយយ៉ាងណា សេចក្ដីសង្ឃឹមរបស់គេក៏បានសម្រេចដូចប្រាថ្នា ហើយនៅពេល ៥ ខែទៅមុខទៀតប៉ុណ្ណោះ គេក៏នឹងក្លាយខ្លួនទៅជាបុគ្គលដែលមានសេចក្ដីសុខសប្បាយរីករាយជាទីបំផុតក្នុងលោក ។

ចំណែកខាងវិស្សុកៈ បុគ្គលដែលធ្លាប់បានចូលប្រយុទ្ធប្រឡងដណ្ដើមយកតំណែងជាមេបញ្ជាការ កងទ័ពសេះជាមួយនឹងបុណ្ណមាណពនោះ ឥឡូវនេះក៏ក្លាយទៅជាបុគ្គលដែលនៅក្រោមបង្គាប់បញ្ជារបស់បុណ្ណ–មាណពមនុស្សដែលខ្លួនស្អប់ខ្ពើម ហើយក្រៅពីការមានជ័យជំនះក្នុងការប្រយុទ្ធប្រឡងថ្វីដៃចេញហើយ នៅមានជ័យជំនះក្នុងរឿងស្នេហាទៀតផង ដូច្នោះ វិស្សុកៈដូចជាខឹងអៀនខ្មាស់អាមាសមុខ ហើយក៏តាំងរេះចងគំនុំគុំគួនចំពោះបុណ្ណមាណពជានិច្ច អ្នកតែងគិតថា ប្រសិនបើមិនអាចនឹងកំចាត់បុណ្ណមាណពចេញបានទេនោះ ខ្លួនក៏មិនគួរនឹងកើតមកជាកូនប្រុសជាតិជាទាហានដែរ ហើយចេះតែចាំឆ្លៀតរកឱកាសជានិច្ច ដើម្បីនឹងកែកំហឹងឲ្យបាន ។

(នៅមានត)

★ ★ ★

## ដំណឹងពិសេស

ក្រុមល្ខោនភាពយន្តខ្មែរនឹងចាប់ផ្ដើមបង្ហាត់បង្រៀនសាធារណជនទូទៅ តាំងពីចាស់តាំងក្មេង ស្រី–ប្រុសចាប់តាំងពីអាយុ ៧ ឆ្នាំ ដល់ ៥០ ឆ្នាំ ។

ដើម្បីឲ្យវឌ្ឍធម៌ភាពយន្តប្រទេសយើងដើរទាន់នឹងប្រទេសសេរីនានា សូមយុវជន–យុវនារីទាំងឡាយអញ្ជើញដោយឆាប់រួសរាន់ទៅចុះឈ្មោះ នឹងបានបង្វឹកខ្លួនឲ្យទៅជាតួក្នុងភាពយន្តខ្មែរ ។

សូមប្រញាប់អញ្ជើញទៅជួបលោក ហួត–ហៀម នៅអធិការដ្ឋានការងារជាប់នឹងការិយាល័យចៅហ្វាយក្រុង ជ្រុងខាងលិច ស្ដួរតាតិមានផ្ទះ ១ នាយកសហគ្រាសបណ្ដោះអាសន្ន ។

អ្នកស្រី កាតុក



កញ្ញា ទេពគន្ធីរ៍ឈរកណ្ដាល បានជាប់ជាទេវីសោភាក្រុងភ្នំពេញ កញ្ញា ហុក-ស៊ុនលី ជាប់កញ្ញាកិត្តិយសខាងស្ដាំ នារីហែមចំរើនជាប់កញ្ញាកិត្តិយសខាងឆ្វេង, កញ្ញា ទាំងបីនេះធ្វើឲ្យគណៈកម្មការពិបាកយ៉ាងខ្លាំង ព្រោះមានលំអប្រហាក់ប្រហែលគ្នា

នេះហើយនារី ហៃម-ចិរេន ដែលបានឈ្នះបានជ័យជា កញ្ញា
មានការអប់រំទៅតាមសម័យរបស់ប្រទេស ,  នាងកាចៈ របៀបនាងឡើង
ទៅជាកញ្ញាជប៉ុនមួយរូបបានទេ ដែលរាយ  ព្រោះនាងមានសិល្ប
កំល្បាំជប៉ុន  ដែលនារីជាតិខ្មែរយើងគួរចេះ





ទស្សនកិច្ចនៃ ឯ. ឧ. ឧបនាយករដ្ឋមន្ត្រី



គណៈកម្មការកំពុងតែពិនិត្យមើលរៀងខ្លួន




កញ្ញាជាតិលាវពីររូបនេះ  កំពុងធ្វើគារវកិច្ចចំពោះ

ព្រះករុណា ជាម្ចាស់ជីវិតលើត្បូង

កញ្ញាសោភាក្រុងភ្នំពេញកំពុងទទួលអំណរ

យ៉ាងស្មោះស្ម័គ្រពីកញ្ញាសោភាប៉ារិស





កញ្ញាទេពគន្ធរីមានកិត្តិយសទទួលឋានៈជាទេវី
សោភាប្រចាំរាជធានីភ្នំពេញ ទេវីសោភាប៉ារីស



សោភានារីទាំងឡាយគ្រប់សង្កាត់ដែលបាន
រើសរួចមកហើយ នាងត្រូវប្រឹងប្រៀបខ្លួន
នឹងដណ្ដើមយកដំណែង ទេវីសោភាភ្នំពេញ
តែទោះបីដូចម្ដេចក៏ដោយកញ្ញាទេពគន្ធរីជាកញ្ញា
សោភាសង្កាត់លេខ ១៧ នាងញញឹមចំលើឋានៈ
ជាទេវីសោភាក្រុងភ្នំពេញ

បានមកឈរទន្ទឹមនាងដើម្បីជូន
មិត្តវិនិច្ឆ័យនូវលំអនៃនារីទាំងពីរ
រូបនេះ តើនាងគួរដល់ការជាប់
ឋានៈជាទេវីសោភាមែនឬទេ...







កញ្ញាទាំងនេះសុទ្ធតែជាប់រៀនសាលាប្រចាំខេត្តរួចហើយ ។ ត្រូវមកប្រណាំង
ប្រជែងរូប ដណ្ដើមឋានៈកញ្ញាឯក







កញ្ញាគ្រប់ខេត្តចំនួន ៧.៤ រូបក្រុមទេវីសោភាភ្នំពេញផង ក្នុងរាត្រីទី២នេះទោះបីដូចម្តេចក៏ដោយ ក៏ការសង្ឃឹមតែង
មានជានិច្ចដល់នាងខ្លះមិនលែង

កញ្ញានេះហើយដែលបានជ្រើសរើសជាទេវីសោភានៅក្នុងសង្កាត់លេខ ៩ ហើយប្រុងប្រៀបខ្លួនជាកញ្ញាឯកសម្រាប់ប្រទេសកម្ពុជា





នាងញញឹមស្រស់បំព្រងដាក់មហាជនហើយមហាជនប្រជ្រៀតគ្នាអើតកមើល





ការពិនិត្យនៃនារីមួយរូប

នារីទាំងឡាយបានបង្ហាញខ្លួនម្នាក់ម្ដងដល់គណៈកម្មការ













នាងកំពុងតែបង្ហាញចរិយា

ដល់គណៈកម្មការ



បើបេះតែស៊ីវិល្ល័យ
ពេកនាំឲ្យចោល
ទំនៀមទម្លាប់ប្រទេស
ហេតុនេះ បានជា
កញ្ញាចូលចិត្តតែងកាយ
យ៉ាងនេះ ដែលយើង
ចាត់ទុកថា គួរដល់
ការពិនិត្យទឹងគយគន់





នារីខ្មែរគួរតែ

មានឫកពារថ្លៃថ្នូរ

ក្នុងទីប្រជុំ






ទីតាំងវត្ថុមួយបែបដែលគួរតែយើងចូលមើល






ខាងលើ ទីតាំងវត្ថុជាតិឥណ្ឌៀ    ខាងក្រោម ស.ហ.រ.អា.



នារីកំពុងចេញពីខាងក្នុងឆាក

កញ្ញាឯកកម្ពុជាបានសម្រេចហើយ ទេពកិន្នរីឈរកណ្ដាលជាប់កញ្ញាឯកកញ្ញាកិត្តិយសកម្ពុជា លេខ១ កាន់លេខ១៩ ឈ្មោះនាងស្រីពៅ នៅខែត្រពោធិសាត់ លេខ២ កាន់លេខ២ ឈ្មោះ ហុក-ស៊ិន-លី ភ្នំពេញ លេខ៣ កាន់លេខ៣ ឈ្មោះ គុល-ស៊ីសុផា កំពត ទីចុងក្រោយបំផុតនាងគ្មានកាន់លេខសោះជាប់លេខ៤ គឺនារី ហម-បំរើន នាងស្រណោះណាស់ម្ដងនេះនាំឲ្យអ្នកមើលស្ដាយខ្លាំង បើសិនជានាងញញឹមបន្តិច គេនឹងចាត់ទុកថា នាងមានជ័យជំនះមួយក្នុងការប្រឡង






នេះជាកញ្ញាសមសួនដែលមានសិទ្ធិប្រឡងតាំងកញ្ញា  តាំងលោកស្រី,  អ្នកស្រី




កញ្ញាសមសួនបួនន់ទួនទទួល

រង្វាន់ពីព្រះហស្តសម្តេច

កញ្ញាខាងក្រោមកំពុងតែញញឹម

អរជាមួយនឹងរង្វាន់






សម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណាទ្រង់បំ

ពាក់ម្កុដមាសនឹងផ្តល់ជូនវត្ថុវិសេស ជា

ច្រើនដល់កញ្ញាឯកកម្ពុជា នាងនឹង

មានកិត្តិយសជាងនារីសាមញ្ញចាប់តាំងពី-

ថ្ងៃនេះទៅ

រោងពុម្ព អ៊ុក-អ៊ុំ-កុល វិថីប៉ាស្ទ័របត្ត ភ្នំពេញ